00504308

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
12 / 05 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

No. D250/3/2/1/5

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៤៧ និងអបជ ៤៨)

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
12 / 05 / 2010
ម៉ោង (Time/Heure): 13:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ២៧ ខែ មេសា ឆ្នាំ ២០១០

---

**សាធារណៈ:(ដោយកោសលុប)**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនត្រូវចោទ**
អៀង ធីរិទ្ធ
អៀង សារី
ខៀវ សំផន
នួន ជា

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
គីម ម៉េងឃី
ម៉ុច សុវណ្ណារី

**សហមេធាវីការពារក្តីជនត្រូវចោទ**
ផាត់ ពៅសៀង
Diana ELLIS

Martine JACQUIN
Philippe CANNONE
Fabienne TRUSSES-NAPROUS
Elizabeth-Joelle RABESANDRATANA
Annie DELAHIE

នី ចាន់ឌី

ឡោ ជុនធី

Silke STUDZINSKY

គង់ ពិសី

ហុង គីមសួន

Pierre-Olivier SUR

យុង ផានិត

ស៊ិន សុវ៉ន

Mahdev MOHAN
NGUYEN Lyma
Marie GUIRAUD
Patrick BAUDOIN
Olivier BAHOUGNE
Julien RIVET
Emmauel ALTIT
Maria Stefania CATALETA

គង់ ហេង

សំ សុខគង់

សុក សំអឿន

Charlotte PLANTIN
Jan Ernest RASSEK

ជេត វណ្ណលី

ពេជ្រ អង្គ

Isabelle DUMAS
Laure DESFORGES
Laurel E. FLETCHER
Bradley KRACK
Lynn TA
Sari AZIZ

អាង ឧត្តម

Michael G. KARNAVAS

ស សុវ៉ាន

Jacques VERGES

សុន អរុណ

Michiel PESTMAN
Victor KOPPE

**សហមេធាវីការពារក្តីជនត្រូវចោទ**

យូ ប៊ុនឡេង

Marcel LEMONDE



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

# មាតិកា

I. ប្រវត្តិនីតិវិធី ........................................ 7

II. សេចក្តីពិចារណាបឋម ........................................ 13

III. ភាពអាចទទួលបាននៃបណ្តឹងឧទ្ធរណ៍ ........................................ 16

IV. អង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ទីពីរ ........................................ 21

ក. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលជាខ្មែរក្រោម និងវៀតណាម ចោទប្រកាន់ថា ព្យសនកម្មទាំងឡាយកើតចេញពីផលវិបាកនៃឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក។ ........................................ 26

ខ. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនជាតិខ្មែរក្រោមមួយចំនួន និងរបស់ជនជាតិវៀតណាមទាំងអស់ស្ថិតនៅក្រោមវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ........ 29

១. ខេត្តតាកែវ ........................................ 29

២. ការជម្លៀសមនុស្សចេញពីភូមិភាគបូព៌ា ........................................ 31

៣. តើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបានរឹតត្បិតហួសហេតុចំពោះបទឧក្រិដ្ឋនានាដែលបានចោទប្រកាន់ប្រឆាំងនឹងជនរងគ្រោះជនជាតិខ្មែរក្រោម និងជនជាតិវៀតណាមតែក្នុងទីតាំងដែលដីកានោះបានចែងដែរឬទេ? ........................................ 37

៤. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិវៀតណាមនានាមិនស្ថិតនៅក្រោមវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះទេ ........................................ 40

៥. ថាតើកិច្ចស៊ើបសួរដែលត្រូវបានបំពេញនៅខេត្តកំពង់ឆ្នាំង បានដាក់ជនរងគ្រោះជាជនជាតិវៀតណាមនៅក្នុងវិសាលភាពនៃអង្គហេតុដែលកំពុងស៊ើបអង្កេតដែរឬយ៉ាងណា... 42

គ. តើដីកាទី២នេះបានចេញមុនពេលកំណត់ដែរឬទេ? ........................................ 44

ឃ. តើដីកាទី២បានរំលោភគោលការណ៍ស្ទួលរបស់ អ.វ.ត.ក ឬ តើដីកានេះគ្មានមូលហេតុដែរឬទេ? ........................................ 46



ECCC • CETC PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

១. ការចោទប្រកាន់លើការរំលោភគោលការណ៍ស្វ័លរបស់ អ.វ.ត.ក ទាក់ទិននឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ...... 46

២. ការចោទប្រកាន់ថា ការប្រកាសមិនទទួលយកដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលស្គាល់រួចហើយធ្វើឡើងដោយគ្មានមូលហេតុ...... 50

ង. ការចោទប្រកាន់ថា ដីកាទី២ មិនបានពិចារណាទៅលើរាល់គ្រប់ព័ត៌មានទាំងអស់ ...... 52

ច. តើដីកាទី២ដែលមានការជំទាស់ ធ្វើឱ្យប៉ះពាល់ដល់សំណុំរឿងរបស់ អ.វ.ត.ក ទាំងមូលស្តីពីអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម ដែរឬទេ?...... 53

<u>ឯកសារភ្ជាប់</u>

មតិយោបល់របស់ចៅក្រម ន័យ ថុល ចៅក្រម MARCHI-UHEL និងចៅក្រម ហួត វុទ្ធី ស្តីពីការប្រកាសមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលស្គាល់រួចហើយ...... 56

មតិយោបល់របស់ចៅក្រម ប្រាក់ គឹមសាន និងចៅក្រម ROWAN DOWNING ស្តីពីការប្រកាសមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលស្គាល់រួចហើយ...... 64



E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“**អ.វ.ត.ក**”) បានទទួលបណ្តឹងឧទ្ធរណ៍ដែលពាក់ព័ន្ធចំនួនពីរ។ បណ្តឹងឧទ្ធរណ៍ទី១ គឺ “បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរួមលើសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនពីររបស់សហព្រះរាជអាជ្ញាទាក់ទិននឹងខ្មែរក្រោម និងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យធ្វើការស៊ើបអង្កេតបន្ថែមទាក់ទិននឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មកលើខ្មែរកម្ពុជាក្រោម និងជនជាតិវៀតណាម” (“បណ្តឹងឧទ្ធរណ៍ទីមួយ”)[១] ដែលដាក់នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រុមខ្មែរក្រោមចំនួនប្រាំបួននាក់[២] ក្រុមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណីចំនួនដប់ប្រាំពីរនាក់ដែលកំណត់អត្តសញ្ញាណខ្លួនឯងថាស្ថិតនៅក្នុងក្រុមជនជាតិភាគតិចខ្មែរក្រោម[៣] និងក្រុមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដប់ប្រាំមួយនាក់ទៀតដែលកំណត់អត្តសញ្ញាណខ្លួនឯងថាជាជនជាតិវៀតណាមមកពីខេត្តកំពង់ឆ្នាំង[៤] (“ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី”) បាន

---

[១] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរួមលើសំណើសុំបំពេញកិច្ចស៊ើបសួរពីររបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងខ្មែរក្រោម និងសំណើរបស់ដើម្បបណ្តឹងរដ្ឋប្បវេណីសុំឲ្យធ្វើការស៊ើបសួរបន្ថែមទាក់ទិននឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ចំពោះខ្មែរកម្ពុជាក្រោម និងជនជាតិវៀតណាម ចុះថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១០ ឯកសារ D274/4/1-1 (“បណ្តឹងឧទ្ធរណ៍ទីមួយ”)។

[២] [redacted] 01[redacted] 02[redacted]; [redacted] 04, [redacted] 06, [redacted]; [redacted] 07, [redacted] 08, [redacted] 25, [redacted]; [redacted] 12, [redacted] 27, [redacted] (អ្នកទាំងអស់នេះត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃទី១៤ ខែមករា ឆ្នាំ ២០១០)។

[៣] [redacted] 03, [redacted] 05, [redacted]; [redacted] 10, [redacted]; [redacted] 11, [redacted]; [redacted] 13, [redacted] 14, [redacted] 15, [redacted] 19, [redacted]; [redacted] 20, [redacted] 21, [redacted]; [redacted] 22, [redacted]; [redacted] 23[redacted] 24, [redacted]; [redacted] 26 [redacted]។

[៤] [redacted] 01, [redacted]; [redacted] 02, [redacted]; [redacted] 03, [redacted]; [redacted] 04, [redacted]; [redacted] 05, [redacted]; [redacted] 06, [redacted] 07, [redacted]; [redacted] 08, [redacted] 09, [redacted] 10, [redacted] 11, [redacted] 12, [redacted] 13, [redacted]; [redacted] 14[redacted] 15, [redacted] 16, [redacted] (អ្នកដាក់ពាក្យសុំចុងក្រោយនេះបានទទួលមរណភាពទៅហើយ។ *សូមមើលបណ្តឹងសាលដីកាលើបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី*

ប្ដឹងនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ ប្រឆាំងចំពោះ "ដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនពីររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងខ្មែរក្រោម និងការសម្លាប់រង្គាលនៅស្រុកបាកាន (ពោធិ៍សាត់) ព្រមទាំងសំណើសុំឱ្យមានកិច្ចស៊ើបសួរបន្ថែមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើខ្មែរក្រោម និងលើជនជាតិវៀតណាម" ("ដីកាទីមួយដែលត្រូវបានជំទាស់")[៥]។ បណ្ដឹង ឧទ្ធរណ៍ទីពីរគឺ "បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹង រដ្ឋប្បវេណីពាក់ព័ន្ធនឹងសំណើសុំលេខ D250/3" ("បណ្ដឹងឧទ្ធរណ៍ទីពីរ")[៦] ដែលសហមេធាវីតំណាង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដប់ប្រាំមួយ ដែលកំណត់អត្តសញ្ញាណខ្លួនឯងថាជាជនជាតិវៀតណាមមកពីខេត្តកំពង់ឆ្នាំង[៧]

---

ឧទ្ធរណ៍ប្រឆាំងនឹងដីកាទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសំណើសុំលេខ D250/3 ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ D250/3/2/1/1 ("បណ្ដឹងឧទ្ធរណ៍ទីពីរ") ជើងទំព័រទី១)។

[៥] ដីកាសម្រេចរួមលើសំណើសុំបំពេញកិច្ចស៊ើបសួរពីរ របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងខ្មែរក្រោម និងការសម្លាប់រង្គាលនៅស្រុកបាកាន (ខេត្តពោធិ៍សាត់) ព្រមទាំងសំណើសុំឱ្យមានកិច្ចស៊ើបសួរបន្ថែមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើខ្មែរក្រោម និងលើជនជាតិវៀតណាម ចេញថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០, ឯកសារ D250/3/3 ("ដីកាទីមួយដែលត្រូវបានជំទាស់")។

[៦] បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹង រដ្ឋប្បវេណីពាក់ព័ន្ធនឹងសំណើសុំលេខ D250/3 ("បណ្ដឹងឧទ្ធរណ៍ទីពីរ")។ បណ្ដឹងឧទ្ធរណ៍ទីមួយ និងបណ្ដឹងឧទ្ធរណ៍ទីពីរ ទំព័រ៤ ដែលកត់សម្គាល់ផងដែរថា បណ្ដឹងឧទ្ធរណ៍ និងដើមបណ្ដឹងរដ្ឋប្បវេណីបានប្ដឹងប្រឆាំងនឹងដីកាសម្រេចលើភាពអាចទទួលយកបាននៃសំណើសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី គឺបានចូលរួមប្ដឹងដោយសហមេធាវីអន្តរជាតិតំណាងឲ្យ "ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានទទួលស្គាល់រួចហើយ ក៏ដូចជាអ្នកដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងឡាយ ដែលស្ថិតក្នុងហានិភ័យស្រដៀងគ្នាដែលថា ឋានៈជាដើមបណ្ដឹងរបស់ពួកគេអាចត្រូវបានដកហូត ឬពួកគេអាចត្រូវបានគេបដិសេធឱកាសក្លាយជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ពួកគេ ក្នុងករណីដែលពួកគេត្រូវបានវិនិច្ឆ័យថា ស្ថិតនៅក្រៅវិសាលភាពនៃការស៊ើបអង្កេតដូចដែលបានកំណត់ដោយ ស.ច.ស នោះ"។

[៧] [redacted] 01, [redacted] 02, [redacted] 03, [redacted] 04, [redacted] 05, [redacted] 06, [redacted] 07, [redacted] 08, [redacted] 09, [redacted] 10, [redacted] ; [redacted] 11, [redacted] ; [redacted] 12, [redacted] 13, [redacted] ; [redacted] 14, [redacted] ; [redacted] 15, [redacted]

និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចំនួនដប់ប្រាំពីរនាក់ដែលកំណត់អត្តសញ្ញាណខ្លួនឯងថាស្ថិតនៅក្នុងក្រុមជនជាតិភាគតិចខ្មែរក្រោម[8] បានប្តឹងប្រឆាំងនឹង "ដីកាសម្រេចទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹង សំណើសុំលេខ D250/3" ("ដីកាទីពីរដែលត្រូវបានជំទាស់")[9]។

## I. ប្រវត្តិនីតិវិធី

១. ក្នុងអំឡុងឆ្នាំ២០០៩ និងរហូតដល់ថ្ងៃទី១២ ខែមករា ឆ្នាំ២០១០ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះ ដែលបានកំណត់អត្តសញ្ញាណខ្លួនឯងជា "ជនជាតិវៀតណាមនៅខេត្តកំពង់ឆ្នាំង" និង "ខ្មែរក្រោម" ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង[10]។

២. នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៩ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ "សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមទាក់ទងនឹងអំពើប្រល័យពូជសាសន៍ទៅលើខ្មែរក្រោម និងជនជាតិវៀតណាម" ("សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី")[11] ដោយមានគោលបំណង (១) ឱ្យសហ

---

[redacted] 16, [redacted] (អ្នកដាក់ពាក្យសុំចុងក្រោយនេះបានទទួលមរណភាពទៅហើយ។ សូមអានបណ្តឹងឧទ្ធរណ៍ទីពីរ លេខយោងទីមួយ ១)។

[8] [redacted] 03 [redacted]; [redacted] 05, [redacted] 10, [redacted]; [redacted] 11, [redacted] 13, [redacted]; [redacted] 14, [redacted]; [redacted] 15, [redacted]; [redacted] 16, [redacted]; [redacted] 17, [redacted]; [redacted] 18, [redacted] 19, [redacted]; [redacted] 20, [redacted]; [redacted] 21, [redacted]; [redacted] 22, [redacted]; [redacted] 23, [redacted] 24, [redacted]; [redacted] 26 [redacted]។

[9] ដីកាសម្រេចលើភាពអាចទទួលបាននៃសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលពាក់ព័ន្ធនឹងសំណើសុំ D250/3, ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០, ឯកសារលេខ D250/3/2, ("ដីកាទីពីរដែលត្រូវបានជំទាស់")។

[10] បញ្ជីឈ្មោះនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់មាននៅក្នុងដីកាទីពីរដែលត្រូវបានជំទាស់ មាននៅក្នុងទំព័រទី ២ ដល់ ទំព័រទី៤។

[11] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមទាក់ទងនឹងអំពើប្រល័យពូជសាសន៍ទៅលើខ្មែរក្រោម និងជនជាតិវៀតណាម ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D250/3 ("សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី")។



PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

ចៅក្រមស៊ើបអង្កេតយកចិត្តទុកដាក់ទៅលើភស្តុតាងថ្មីៗ ដែលបញ្ជាក់អំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងក្រុមជាតិភាគតិចខ្មែរក្រោមនៅខេត្តពោធិសាត់ និងខេត្តតាកែវ ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ("សម័យកម្ពុជាប្រជាធិបតេយ្យ") និង (២) ផ្តល់បន្ថែមដល់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ") របស់សហព្រះរាជអាជ្ញានូវភស្តុតាងបញ្ជាក់ ថាការបោសសម្អាតតាមដែនដីដែលជាអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានប្រព្រឹត្តទៅលើក្រុមជាតិភាគតិចវៀតណាម ពិតជាបានលាតសន្ធឹងទៅដល់ខេត្តកំពង់ឆ្នាំងនាអំឡុងសម័យនោះ ហើយស្នើសុំឱ្យដាក់បញ្ចូលឧក្រិដ្ឋកម្មទាំងនេះបញ្ចូលទៅក្នុងសំណុំរឿងលេខ ០០២[១២]។

៣. នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ និងនៅថ្ងៃទី៦ ខែមករា ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានដាក់សំណើដែលពាក់ព័ន្ធដូចខាងក្រោម៖

i. "សំណើសុំឱ្យបំពេញកិច្ចស៊ើបសួររបស់សហព្រះរាជអាជ្ញាទាក់ទិននឹងខ្មែរក្រោម និងការសម្លាប់រង្គាលនៅស្រុកបាកាន (ខេត្តពោធិសាត់)" ("សំណើទីមួយរបស់សហព្រះរាជអាជ្ញា")[១៣] និង "បំណងបន្ថែមបង្គ្រប់ទៅលើការចោទប្រកាន់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ទាក់ទិននឹងប្រព្រឹត្តកម្មទៅលើជនជាតិវៀតណាម (កថាខណ្ឌ ៦៩ ដល់ កថាខណ្ឌ ៧០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ) ការជម្លៀសប្រជាជនដោយបង្ខំចេញពីភូមិភាគបូព៌ា (កថាខណ្ឌ ៤២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ) និងការបោសសម្អាតនៅភូមិភាគបូព៌ា (កថាខណ្ឌ ៧១ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ)"[១៤] ដោយស្នើសុំឱ្យ ស.ច.ស លើកឡើងពីអង្គហេតុ និងភស្តុតាងថ្មីៗទាក់ទិននឹងប្រព្រឹត្តកម្មទៅលើខ្មែរក្រោម និង

---

[១២] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១។

[១៣] សំណើសុំឱ្យបំពេញកិច្ចស៊ើបសួររបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងខ្មែរក្រោម និងការសម្លាប់រង្គាលនៅស្រុកបាកាន (ពោធិ៍សាត់) ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D274 ("សំណើទីមួយរបស់សហព្រះរាជអាជ្ញា")។

[១៤] សំណើទីមួយរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ការសម្លាប់រង្គាលនៅក្នុងស្រុកបាកានខេត្តពោធិ៍សាត់ក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ[១៥] ហើយស្នើសុំឱ្យដាក់ឧក្រិដ្ឋកម្មទាំងនេះ[១៦]បញ្ចូលទៅក្នុងសំណុំរឿង០០២[១៧]។ និង

ii. "សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទិននឹងខ្មែរក្រោម" ("សំណើទីពីររបស់សហព្រះរាជអាជ្ញា")[១៨] និង"បំណងបញ្ជាក់បំភ្លឺអំពីកិច្ចស៊ើបសួរបន្ថែមលើបញ្ហាអង្គហេតុទាក់ទិននឹងខ្មែរក្រោម និងការសម្លាប់រង្គាលនៅស្រុកបាកាន (D274) ដូចបានលើកឡើងនៅក្នុង[សំណើទីមួយ] ដែលសហព្រះរាជអាជ្ញាជឿថាចាំបាច់"[១៩]។

៤. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ស.ច.ស បានចេញដីកាទីមួយដែលត្រូវបានជំទាស់ ដោយបានច្រានចោលផ្នែកខ្លះ ពោលគឺ (i) សំណើទីមួយរបស់សហព្រះរាជអាជ្ញា ដែលស្នើសុំឱ្យពង្រីកលើការស៊ើបអង្កេត ដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម (ii) សំណើទីពីររបស់សហព្រះរាជអាជ្ញា ដែលពាក់ព័ន្ធទៅនឹងអង្គហេតុដែលស្ថិតនៅក្រៅវិសាលភាពនៃកិច្ចស៊ើបសួរ និង (iii) សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានលើកបញ្ហាដូចគ្នានឹងសហព្រះរាជអាជ្ញា ដែលបញ្ហាទាំងនេះស្ថិតនៅក្រៅវិសាលភាពនៃកិច្ចស៊ើបសួរដូចគ្នា។

៥. នៅថ្ងៃដដែលនេះ ស.ច.ស បានចេញដីកាទីពីរដែលត្រូវបានជំទាស់ ដែលនៅក្នុងផ្នែកពាក់ព័ន្ធមួយនោះបានប្រកាសមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អ្នកដាក់

---

[១៥] សំណើទីមួយរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១។

[១៦] អង្គហេតុ និងឯកសារសម្ភារៈគាំទ្រ បានរៀបរាប់នៅក្រោមចំណងជើងនៃផ្នែកស្តីពី "ឧក្រិដ្ឋកម្ម" ត្រង់កថាខណ្ឌ ៣ ដល់ កថាខណ្ឌ ៦ នៅក្នុងសំណើ។ ការកំណត់ឈ្មោះបទចោទតាមផ្លូវច្បាប់ និងការកំណត់ទម្រង់នៃការទទួលខុសត្រូវ ដែលសហព្រះរាជអាជ្ញាបានចោទប្រកាន់លើឧក្រិដ្ឋកម្មទាំងនេះ និងដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿងលេខ ០០២ ត្រូវបានរៀបរាប់នៅក្រោមចំណងជើងនៃផ្នែកស្តីពី "ការកំណត់ឈ្មោះបទចោទ" ត្រង់កថាខណ្ឌ ៧ ដល់ កថាខណ្ឌ ៨ នៅក្នុងសំណើទីមួយរបស់សហព្រះរាជអាជ្ញា។

[១៧] សំណើទីមួយរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១។

[១៨] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមស្តីពីខ្មែរក្រោម ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០១០, ឯកសារ D274/2 ("សំណើទីពីររបស់សហព្រះរាជអាជ្ញា")។

[១៩] សំណើទីពីររបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១។

ពាក្យសុំចំនួនដប់ប្រាំមួយនាក់ ដែលអ្នកទាំងនេះបានកំណត់អត្តសញ្ញាណខ្លួនឯងថាជាជនជាតិវៀតណាមមកពីខេត្តកំពង់ឆ្នាំង និងអ្នកដាក់ពាក្យចំនួនដប់ប្រាំពីរនាក់ទៀត ដែលបានកំណត់អត្តសញ្ញាណខ្លួនឯងថាស្ថិតនៅក្នុងក្រុមជនជាតិភាគតិចខ្មែរក្រោម[២០]។ សហចៅក្រមស៊ើបអង្កេតបានបដិសេធចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីខាងលើដោយឈរលើមូលដ្ឋានថា "អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនបានបង្ហាញអំពីទំនាក់ទំនងហេតុ និងបច្ច័យរវាងព្យសនកម្មដែលអះអាង និងអង្គហេតុដែលជាកម្មវត្ថុនៃការស៊ើបសួរ"[២១]។

៦. ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឱ្យដាក់បណ្តឹងឧទ្ធរណ៍ទីមួយ និងបណ្តឹងឧទ្ធរណ៍ទីពីរបញ្ចូលគ្នា ហើយក៏បានស្នើសុំឱ្យអង្គបុរេជំនុំជម្រះបើកសវនាការជាសាធារណៈ ពីព្រោះ (i) បណ្តឹងឧទ្ធរណ៍ទាំងនេះជាប្រភេទបណ្តឹងដែលមិនធ្លាប់មានពីមុនមក[២២] (ii) បណ្តឹងឧទ្ធរណ៍ទាំងនេះលើកឡើងនូវបញ្ហាផលប្រយោជន៍សាធារណៈ[២៣] (iii)សវនាការជាសាធារណៈអាចចាក់ផ្សាយរូបភាពជូនដើមបណ្តឹងរដ្ឋប្បវេណីនិងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលនៅឆ្ងាយពីទីរួមខេត្ត[២៤] (iv) សេចក្តីសម្រេចរបស់អង្គជំនុំជម្រះនឹងកំណត់ច្បាស់លាស់អំពីតួនាទីរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២[២៥] និង (v) សវនាការជាសាធារណៈមួយនេះមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬ វិធានការការពារណាមួយដែលរៀបចំដោយដោយតុលាការឡើយ[២៦]។

[២០] សូមអានលេខយោង ៧ និង លេខយោង ៨ ខាងលើ និងដីកាទីពីរដែលត្រូវបានជំទាស់ ត្រង់ទំព័រទី ៤។

[២១] ដីកាទីពីរដែលត្រូវបានជំទាស់ កថាខណ្ឌ១៩។

[២២] បណ្តឹងឧទ្ធរណ៍ទីមួយ និងបណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក I (ក)។

[២៣] បណ្តឹងឧទ្ធរណ៍ទីមួយ និងបណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក I (ខ)។

[២៤] បណ្តឹងឧទ្ធរណ៍ទីមួយ និងបណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក I (គ)។

[២៥] បណ្តឹងឧទ្ធរណ៍ទីមួយ និងបណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក I (ឃ) និង (ង)។

[២៦] បណ្តឹងឧទ្ធរណ៍ទីមួយ និងបណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក I(ច)។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

៧. បណ្ដឹងឧទ្ធរណ៍ទីមួយបានលើកឡើងនូវមូលដ្ឋានចំនួនបួនប្រឆាំងនឹងដីកាទីមួយ ដែលដីកានេះបានចោទប្រកាន់ថា (i) សំណើទីមួយ និងសំណើទីពីររបស់សហព្រះរាជអាជ្ញា សំណើនេះនីមួយៗ និង/ឬ សំណើទាំងពីរនេះបង្កើតជាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[២៧] (ii) សំណើទីមួយ និងសំណើទីពីររបស់សហព្រះរាជអាជ្ញា រួមទាំងសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ[២៨] (iii) ស.ច.ស អាចស៊ើបអង្កេតលើអង្គហេតុទាំងឡាយដែលដាក់ជូននៅក្នុងសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី[២៩] និង (iv) "តាមរយៈការកម្រិតចំពោះការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក អ.វ.ត.ក នឹងបំពាននូវគោលការណ៍ជាមូលដ្ឋានរបស់ខ្លួន"[៣០]។

៨. បណ្ដឹងឧទ្ធរណ៍ទីពីរស្នើសុំឱ្យអង្គបុរេជំនុំជម្រះច្រានចោលដីកាទីពីរ និងបង្គាប់ឱ្យផ្ដល់ឋានៈ ឬទទួលស្គាល់អ្នកដាក់ពាក្យសុំជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងលេខ ០០២ វិញ។ បណ្ដឹងឧទ្ធរណ៍ទីពីរនេះចោទប្រកាន់ថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីខ្មែរក្រោម និងជនជាតិវៀតណាមទាំងអស់នេះ ស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក[៣១] និងវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ហើយកិច្ចស៊ើបសួរដែលបានបំពេញដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងខេត្តកំពង់ឆ្នាំង បានដាក់ឱ្យជនជាតិវៀតណាមស្ថិតនៅក្នុងវិសាលភាពនៃអង្គហេតុដែលស្ថិតនៅក្រោមការស៊ើបអង្កេត[៣២]។ បណ្ដឹងឧទ្ធរណ៍ទីពីរនេះក៏បានចោទប្រកាន់ផងដែរថា (i) ដីកាទីពីរបានចេញមុនកាលបរិច្ឆេទកំណត់ ពីព្រោះទំហំនៃ

[២៧] បណ្ដឹងឧទ្ធរណ៍ទីមួយ ផ្នែក II កថាខណ្ឌ ២ (ខ)។

[២៨] បណ្ដឹងឧទ្ធរណ៍ទីមួយ ផ្នែក II កថាខណ្ឌ ២ (ក)។

[២៩] បណ្ដឹងឧទ្ធរណ៍ទីមួយ ផ្នែក II កថាខណ្ឌ ២ (គ)។

[៣០] បណ្ដឹងឧទ្ធរណ៍ទីមួយ ផ្នែក II កថាខណ្ឌ២ (ឃ)។

[៣១] បណ្ដឹងឧទ្ធរណ៍ទីពីរ ផ្នែក II កថាខណ្ឌ ១ (ក) ៣ (ក) និង ៣ (គ)។

[៣២] បណ្ដឹងឧទ្ធរណ៍ទីពីរ ផ្នែក II កថាខណ្ឌ ១ (ខ), ៣ (ខ) និង ៣ (ឃ)។

កិច្ចស៊ើបសួរនៅមិនទាន់បានកំណត់ពេញលេញនៅឡើយ[៣៣]។ (ii) ដីកាទីពីរបានធ្វើឡើងផ្ទុយពីគោលការណ៍ជាសារវន្តរបស់ អ.វ.ត.ក ទាក់ទងនឹងការចូលរួមរបស់ជនរងគ្រោះ ហើយបានធ្វើឡើងដោយគ្មានមូលហេតុ[៣៤]។ (iii) ដីកាទីពីរមានកំហុសអង្គច្បាប់ នៅពេលដែលសហចៅក្រមស៊ើបអង្កេតប្រកាសមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលខ្លួនបានទទួលស្គាល់រួចហើយ[៣៥]។ (iv) ដីកាទីពីរមិនពិចារណាព័ត៌មានពាក់ព័ន្ធទាំងអស់ ហើយបានបដិសេធអ្នកដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីវៀតណាម រួមគ្នាតែម្តង (*en masse*)[៣៦] ហើយ (v) បានប៉ះពាល់ដល់រឿងក្តីទាំងមូលរបស់អ.វ.ត.ក លើបទប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម[៣៧]។

៩. សហព្រះរាជអាជ្ញាមិនបានដាក់សេចក្តីសន្និដ្ឋានតបទៅនឹងបណ្តឹងឧទ្ធរណ៍ទីមួយឡើយ។

១០. នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានចេញ "សេចក្តីសម្រេចអំពីការចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរ និងសេចក្តីអញ្ជើញសហព្រះរាជអាជ្ញាឱ្យបំភ្លឺអំពីជំហររបស់ខ្លួន" ("សេចក្តីសម្រេចសុំអញ្ជើញការឆ្លើយបំភ្លឺ) ដោយក្នុងនោះបានអញ្ជើញសហព្រះរាជអាជ្ញាឱ្យឆ្លើយបំភ្លឺថាតើសំណើសុំទីមួយរបស់ខ្លួននោះមានបំណងធ្វើជាដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដែរឬយ៉ាង[៣៨]។

---

[៣៣] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក II កថាខណ្ឌ ១ (គ) ។

[៣៤] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក II កថាខណ្ឌ ១ (ឃ) និង ១ (ង) ។

[៣៥] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក II កថាខណ្ឌ ៣ (ង)។

[៣៦] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក II កថាខណ្ឌ ៣ (ច)។

[៣៧] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក II កថាខណ្ឌ ៣ (ឆ)។

[៣៨] សេចក្តីសម្រេចអំពីការចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរ និងសេចក្តីអញ្ជើញសហព្រះរាជអាជ្ញាឱ្យបំភ្លឺជំហររបស់ខ្លួន ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១០ ឯកសារ D250/3/2/1/2 ("សេចក្តីសម្រេចអញ្ជើញឱ្យបំភ្លឺ")។

១១. នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់ "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើសុំបំភ្លឺរបស់អង្គបុរេជំនុំជម្រះលើឯកសារដាក់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីខ្មែរក្រោម" ("សេចក្តីបំភ្លឺរបស់សហព្រះរាជអាជ្ញា")[៣៩]។

១២. នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១០ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីខ្មែរក្រោម បានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសេចក្តីបំភ្លឺរបស់សហព្រះរាជអាជ្ញា (sic) លើឯកសារដាក់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីខ្មែរក្រោម[៤០]។

## II. សេចក្តីពិចារណាបឋម

១៣. អង្គបុរេជំនុំជម្រះសង្កេតឃើញថា សហព្រះរាជអាជ្ញាបានបញ្ជាក់ថាសំណើទីមួយរបស់ខ្លួនគឺ "មានបំណងធ្វើជាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ហើយសហចៅក្រមស៊ើបអង្កេតទទួលបានអង្គហេតុទាក់ទិននឹងខ្មែរក្រោម ដូចដែលបានរៀបរាប់នៅក្នុងឯកសារនោះត្រូវបានប្តឹងមកខ្លួន"[៤១]។ ទោះបីជាយ៉ាងនេះក្តី សហព្រះរាជអាជ្ញាបានបំពេញលក្ខណៈដល់សំណើទីមួយរបស់ខ្លួន ដោយបញ្ជាក់ថា សំណើទីមួយរបស់ខ្លួននេះមានបំណងធ្វើជាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ហើយបានពន្យល់បន្ថែមថា ហេតុផលតែមួយគត់ដែលសំណើទីមួយរបស់ខ្លួនមិនបានដាក់បញ្ចូលពាក្យនៅក្នុងចំណងជើងថាជា "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម" [redacted] ស.ច.ស បានទទួលអង្គហេតុទាក់ទិននឹងខ្មែរក្រោមដូចដែលបានរៀបរាប់នៅក្នុងឯកសារនោះ ត្រូវបាន

---

[៣៩] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើសុំបំភ្លឺរបស់អង្គបុរេជំនុំជម្រះលើឯកសារដាក់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីខ្មែរក្រោម ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១០ ឯកសារ D274/4/3 ("សេចក្តីបំភ្លឺរបស់សហព្រះរាជអាជ្ញា")។

[៤០] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីខ្មែរក្រោម និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសេចក្តីបញ្ជាក់របស់សហព្រះរាជអាជ្ញា ចំពោះពាក្យសុំរបស់ខ្លួន ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីខ្មែរក្រោម ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១០ ឯកសារ D250/3/2/1/4 ("ចម្លើយតបរបស់ភាគីបណ្តឹងឧទ្ធរណ៍")។

[៤១] សេចក្តីបំភ្លឺរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣។

ប្ដឹងមកខ្លួនរួចហើយ[៤២]។ ដោយពិចារណា[redacted]ដែលបានលើកឡើងខាងលើថាតើ ស.ច.ស បានទទួលអង្គហេតុទាក់ទិននឹងខ្មែរក្រោម ដូចដែលបានរៀបរាប់នៅក្នុងសំណើទីមួយហើយឬនៅ និងដោយពិចារណាថាតើសហព្រះរាជអាជ្ញាត្រូវឬមិនត្រូវចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម មុនពេលខ្លួនឈានដល់ការសម្រេចគោលបំណងរួមពោលគឺយល់ព្រមធ្វើការស៊ើបអង្កេតបន្ថែមលើអង្គហេតុដែលខ្វែងយោបល់គ្នានោះ សហព្រះរាជអាជ្ញាមានវិធីសាស្ត្រដទៃទៀតក្រៅពីវិធីសាស្ត្រដែលខ្លួនបានជ្រើសរើសនេះ ដូចជា (i) ដាក់សំណើសុំបំពេញកិច្ចស៊ើបសួរលើអង្គហេតុដែលទាក់ទិននឹងខ្មែរក្រោម អនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ដោយបញ្ជាក់ឱ្យច្បាស់ថា ក្នុងករណីដែល ស.ច.ស ពិចារណាឃើញថា អង្គហេតុនេះស្ថិតនៅក្រៅវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះសំណើសុំបំពេញកិច្ចស៊ើបសួរនេះត្រូវចាត់ទុកជា "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម" ជាផ្លូវការ (ii) ដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម "ត្រង់ៗតែម្ដង" ដើម្បីជៀសវាងបញ្ហា (iii) [redacted] ឬ (iv) ដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ ហើយក្នុងករណីនេះ ប្រសិនបើ ស.ច.ស បដិសេធ ដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ចំពោះជម្រើសដែលសហព្រះរាជអាជ្ញាប្រកាន់យក និងពាក្យពេចន៍នៅក្នុងដីកាទីមួយ

[៤២] សេចក្ដីបំភ្លឺរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤។ សូមមើលផងដែរ ចម្លើយតបរបស់ដើមបណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៧ និង កថាខណ្ឌ ៨។ យោងតាមកថាខណ្ឌទាំងពីរនេះ និងក្រោយពីពិចារណាលើសេចក្ដីបំភ្លឺរបស់សហព្រះរាជអាជ្ញា ភាគីបណ្ដឹងឧទ្ធរណ៍ស្នើសុំអង្គបុរេជំនុំជម្រះឱ្យអញ្ជើញ ស.ច.ស *"ផ្ដល់ចំណាប់អារម្មណ៍លើ*ធ្មានុសិទ្ធិរបស់ខ្លួនដែលចៅក្រមមានកំហុសនៅពេលខ្លួនជៀសវាងមិនចង់បានសិទ្ធិអំណាចនេះ។ ភាគីបណ្ដឹងឧទ្ធរណ៍ក៏បញ្ជាក់ផងដែរថា ការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលជាខ្មែរក្រោមមកពីស្រុកបាកានជាដើមបណ្ដឹងរដ្ឋប្បវេណី មានសារសំខាន់ក្នុងការបញ្ជាក់ការពិត និងជាវិធានការលាតត្រដាងការពិតដល់ជនរងគ្រោះខ្មែរក្រោមនៃឧក្រិដ្ឋកម្មធំៗ។



E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

ជម្រើស និងពាក្យពេចន៍នេះនៅតែបើកលទ្ធភាពឱ្យសហព្រះរាជអាជ្ញាដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ឬដាក់បណ្តឹងឧទ្ធរណ៍ចំពោះដីកាទីមួយ ។

១៤. សហព្រះរាជអាជ្ញាមិនបានចាត់ការតាមនីតិវិធីខាងលើឡើយ ហើយបានពន្យល់ថា ខ្លួនមិនបានពិចារណាអនុវត្តតាមបែបនីតិវិធីទីមួយឡើយ ពីព្រោះ "វាមិនសមស្របក្នុងការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ក្រោយពេល ស.ច.ស បានចេញដីកាជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ អនុលោមតាមវិធាន ៦៦(១)នៃវិធានផ្ទៃក្នុង"[៤៣]។ អនុលោមតាមវិធានដែលបានលើកឡើងខាងដើមនេះ នៅពេល ស.ច.ស ជូនដំណឹងដល់ភាគីថា ខ្លួនបានពិចារណាបញ្ចប់កិច្ចស៊ើបសួរហើយនោះ វានៅផ្តល់ការពន្យារពេលមួយរយៈដល់ភាគីក្នុងការស្នើសុំការបំពេញកិច្ចស៊ើបសួរបន្ថែម។ វិធានផ្ទៃក្នុងមិនបានប្រមើលមើលឱ្យបានច្បាស់លាស់អំពីលទ្ធភាពទុកសម្រាប់សហព្រះរាជអាជ្ញា ដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនៅក្នុងដំណាក់កាលនោះ ប៉ុន្តែវិធានផ្ទៃក្នុងក៏មិនបានដកលទ្ធភាពដូច្នេះដែរ។ សហព្រះរាជអាជ្ញាមិនបានពន្យល់ឱ្យបានពេញលេញថា ហេតុផលអ្វីបានជាខ្លួនមិនដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ដីកាទីមួយ ពីព្រោះ (i) ខ្លួនមានបំណងឱ្យ ស.ច.ស ទទួលយកអង្គហេតុដែលទាក់ទិននឹងខ្មែរក្រោមដូចបានរៀបរាប់នៅក្នុងសំណើទីមួយ ហើយ (ii) ខ្លួនយល់ឃើញថា ការកំណត់របស់ ស.ច.ស ថា ស.ច.ស មិនត្រូវបានប្តឹងអំពីអង្គហេតុទាំងនោះ ដែលទាក់ទងទៅនឹងការសម្លាប់រង្គាលខ្មែរក្រោមនៅក្នុងស្រុកបាកាន គឺជាការមិនត្រឹមត្រូវ[៤៤]។ សហព្រះរាជអាជ្ញាបញ្ជាក់បំភ្លឺថា ខ្លួនយល់ឃើញថា វានឹងមានការសម្រេចយ៉ាងល្អបំផុតលើសុពលភាពនៃដីកាទីមួយនៅក្នុងបណ្តឹងឧទ្ធរណ៍ទីមួយ ដែលដើមបណ្តឹងរដ្ឋប្បវេណីខ្មែរក្រោមបានប្តឹង[៤៥]។ នៅក្នុងផ្នែកបន្ទាប់នៃសាលដីកានេះនឹងមានការបង្ហាញថា ករណីនេះមិនអាចកើតឡើងដូច្នេះឡើយ។

[៤៣] សេចក្តីបំភ្លឺរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០។

[៤៤] សេចក្តីបំភ្លឺរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៨។

[៤៥] សេចក្តីបំភ្លឺរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០។

## III. ភាពអាចទទួលបាននៃបណ្តឹងឧទ្ធរណ៍

១៥. ស.ច.ស បានចេញដីកាទីមួយកាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ហើយនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ ស.ច.ស បានជូនដំណឹងអំពីដីកានេះ ដល់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ ស្របតាមវិធាន ៧៥(១) នៃវិធានផ្ទៃក្នុង។ ក្រោយមក បណ្តឹងឧទ្ធរណ៍ទីមួយ បានដាក់ប្តឹងនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ ដូច្នេះវាស្ថិតនៅក្នុងរយៈពេលកំណត់ដូចមានចែងនៅក្នុងវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង។

១៦. បណ្តឹងឧទ្ធរណ៍ទីមួយបានដាក់ប្តឹងស្របតាមវិធាន ៧៤(៤)(ក) នៃវិធានផ្ទៃក្នុង។ វិធាននេះបើកផ្លូវឱ្យដើមបណ្តឹងរដ្ឋប្បវេណីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ ស.ច.ស ចំពោះការបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ ដែលអនុញ្ញាតឱ្យធ្វើឡើងស្របតាមវិធានផ្ទៃក្នុង។ បណ្តឹងឧទ្ធរណ៍នេះក៏បានប្តឹងស្របតាមវិធាន ៥៥(១០)នៃវិធានផ្ទៃក្នុង ដែលចែងថា នៅគ្រប់ពេលវេលានៃការស៊ើបសួរ ដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬបំពេញកិច្ចស៊ើបសួរណាមួយ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា វិធានទាំងនេះអនុវត្តចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណី លើកលែងចំពោះតែជនដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន ត្រូវបានប្រកាសមិនទទួលស្គាល់ តាមអានុភាពនៃសេចក្តីសម្រេចជាស្ថាពរ។ ដីកាទីមួយបានពិចារណាឃើញថា ដរាបណាមានសំណើសុំ ស.ច.ស ឱ្យពិចារណាលើភស្តុតាងថ្មីដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ចំពោះខ្មែរក្រោមនៅខេត្តពោធិសាត់ និងខេត្តតាកែវ និងចំពោះជនជាតិវៀតណាមនៅខេត្តកំពង់ឆ្នាំង នោះសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លើកឡើងនូវខ្លឹមសារសំខាន់ដូចគ្នានឹងសំណើទីមួយ និងសំណើទីពីររបស់សហព្រះរាជអាជ្ញាដែរ (ពោលគឺ ការស៊ើបអង្កេតលើការប្រព្រឹត្តលើខ្មែរក្រោម និងជនជាតិ



PRE-TRIAL CHAMBER • E.C.C.C • C.E.T.C • CHAMBRE PRÉLIMINAIRE

វៀតណាមនៅក្នុងតំបន់ភូមិសាស្ត្រ ដែលមិនស្ថិតនៅក្នុងវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម)។ ដូច្នេះ ក.ស.ច.ស បានបដិសេធសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រង់ចំណុចនេះ ដោយឈរលើមូលដ្ឋានដូចគ្នា ដែលបានសម្រេចនៅក្នុងសំណើរបស់សហព្រះរាជអាជ្ញា[៤៦]។

១៧. អង្គបុរេជំនុំជម្រះរំលឹកឡើងវិញថា សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានគោលបំណង (១) ឱ្យសហចៅក្រមស៊ើបអង្កេតយកចិត្តទុកដាក់ទៅលើភស្តុតាងថ្មីៗ ដែលបញ្ជាក់អំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងក្រុមជាតិភាគតិចខ្មែរក្រោមនៅខេត្តពោធិសាត់ និងខេត្តតាកែវ ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ("សម័យកម្ពុជាប្រជាធិបតេយ្យ") និង (២) ផ្តល់បន្ថែមដល់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ") របស់សហព្រះរាជអាជ្ញានូវភស្តុតាងបញ្ជាក់ថាការបោសសម្អាតតាមដែនដីដែលជាអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងក្រុមជាតិភាគតិចវៀតណាម ពិតជាបានលាតសន្ធឹងទៅដល់ខេត្តកំពង់ឆ្នាំងនាអំឡុងសម័យនោះ ហើយស្នើសុំឱ្យដាក់បញ្ចូលឧក្រិដ្ឋកម្មទាំងនេះបញ្ចូលទៅក្នុងសំណុំរឿងលេខ ០០២[៤៧]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញទៀតថា ខណៈដែលបណ្តឹងឧទ្ធរណ៍ទីមួយបានចោទប្រកាន់ថា សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ[៤៨] ភាគីបណ្តឹងឧទ្ធរណ៍មិនបង្ហាញជំហរនេះជាក់លាក់នៅ

---

[៤៦] ដីកាទីមួយដែលត្រូវបានជំទាស់ កថាខណ្ឌ ៩។ ស.ច.ស បានកំណត់មូលដ្ឋានទីពីរនៅក្នុងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្តល់ទឡ្ហីករណ៍ថា ខ្មែរក្រោមត្រូវបានចារីយល់ឃើញជាអត្តនោម័តថាជាជនជាតិវៀតណាម ហើយ ស.ច.ស បានលើកឡើងលើករណីនេះថា ខ្លួន"នឹងមិនធ្វើការបញ្ជាក់អំពីការសម្រេចចិត្តទាក់ទងនឹងច្បាប់ដែលត្រូវអនុវត្តនោះទេ ព្រោះការកំណត់បទល្មើសបែបនេះនឹងត្រូវបានលើកឡើងនៅក្នុងដីកាដោះស្រាយ ស្របទៅតាមបញ្ញត្តិនៃវិធាន ៦៧(២)នៃវិធានផ្ទៃក្នុង" (ដីកាទីពីរដែលត្រូវបានជំទាស់ កថាខណ្ឌ ១០)។

[៤៧] សំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១។

[៤៨] បណ្តឹងឧទ្ធរណ៍ ផ្នែក II កថាខណ្ឌ ២ (ក)។

00504325



ចំពោះមុខ ស.ច.ស នៅពេលខ្លួនធ្វើសំណើនេះឡើង។ តាមពិត ដើមបណ្តឹងរដ្ឋប្បវេណីបានតវ៉ានៅពេលក្រោយមកថា ទោះបីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបានលើកឡើងថា បក្សកម្មុយនីស្តកម្ពុជាបានអនុវត្តគោលនយោបាយកំចាត់ប្រជាជនវៀតណាមទាំងស្រុងនៅខេត្តព្រៃវែងតាមរយៈការប្រហារជីវិតក៏ដោយ[៤៩] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ"ពុំបានចាប់អារម្មណ៍ដល់វិសាលភាពនៃឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តមកលើជនជាតិភាគតិចវៀតណាម ឬឧក្រិដ្ឋកម្មទាំងឡាយណា ដែលត្រូវបានប្រព្រឹត្តមកលើជនជាតិភាគតិចខ្មែរក្រោម ដោយផ្អែកតាមមូលដ្ឋាននៃការជាប់ពាក់ព័ន្ធខាងជាតិសាសន៍ និង/ឬ ជាតិពន្ធុ ជាមួយវៀតណាមពិតប្រាកដ ឬតាមការយល់ឃើញឡើយ"[៥០]។ សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងយ៉ាងច្បាស់ថា "ប្រាថ្នាចង់ឱ្យមានការបំពេញចន្លោះប្រហោងទាំងនេះ"។[៥១] ដោយមិនផ្តល់ទម្ងន់ហួសហេតុលើចំណងជើងនៃសំណើនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សំណើនេះបានប្រើពាក្យ "កិច្ចស៊ើបសួរបន្ថែម" ដែលវាក៏ស្របនឹងវិធីសាស្ត្រដែលបានលើកឡើងខាងលើផងដែរ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនបានបំពេញលក្ខណៈសម្បត្តិជាសំណើសុំបំពេញកិច្ចស៊ើបសួរឡើយ អនុលោមតាមវិធាន ៥៥(១០)នៃវិធានផ្ទៃក្នុង។ នៅពេលអានវិធាន៥៥(៣) និងវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុងរួមគ្នា វិធានទាំងពីរនេះបង្ហាញថា ទោះបីជាដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំ ស.ច.ស ឱ្យចេញដីកា ឬបំពេញកិច្ចស៊ើបសួរបែបនេះ ដែលខ្លួនពិចារណាឃើញថាមានភាពចាំបាច់សម្រាប់ការស៊ើបអង្កេតក៏ដោយ វិសាលភាពនៃការស៊ើបអង្កេតត្រូវបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ អង្គបុរេជំនុំជម្រះយល់ឃើញថា យោងតាមវិធាន ៥៥(៣) នៃវិធានផ្ទៃក្នុង លក្ខខណ្ឌកម្រិតលើ ស.ច.ស អនុវត្តដូចគ្នាចំពោះដើម

---

[៤៩] សំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៧ និងជើងទំព័រទី ១៣ យោងទៅលើដីកាបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៦៩។

[៥០] សំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៧។

[៥១] សំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៨។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

បណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ អ្នកទាំងនេះអាចជំរាបអង្គហេតុថ្មីជូន ស.ច.ស ឬ សហព្រះរាជអាជ្ញាបាន ប៉ុន្តែខ្លួនពុំមានសិទ្ធិស្នើសុំបំពេញកិច្ចលើអង្គហេតុថ្មីទាំងនេះឡើយ លើកលែងតែសហព្រះរាជអាជ្ញាបានបញ្ចូលអង្គហេតុទាំងនេះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ចំពោះស.ច.ស ខ្លួនអាចត្រឹមតែស៊ើបអង្កេតលើអង្គហេតុថ្មីណាដែលជាស្ថានទម្ងន់ទោស ដូចមានចែងស្រាប់នៅក្នុងដីកាសន្និដ្ឋានដ្ឋានតែប៉ុណ្ណោះ។ នៅពេលពិនិត្យមើលមូលដ្ឋាននានានៅក្នុងបណ្តឹងឧទ្ធរណ៍ ដែលបើកផ្លូវឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្តឹង តាមវិធាន ៧៤(៤)នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍ទីមួយមិនអាចទទួលយកបានឡើយ។

១៨. មុនពេលធ្វើការពិនិត្យថាតើអាចទទួលយកបណ្តឹងឧទ្ធរណ៍ទីពីរបានឬមិនបាននោះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាសង្ឃឹមទុក[៥២]ថា អង្គបុរេជំនុំជម្រះនឹងពិចារណាលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ដែលគេប្តឹង ហើយនឹងសម្រេចបណ្តឹងឧទ្ធរណ៍នេះជាប្រយោជន៍ដល់ដើមបណ្តឹងឧទ្ធរណ៍ ដោយរកឃើញថា ស.ច.ស មានកំហុសនៅពេលខ្លួនចាត់ទុកសំណើទីមួយជាដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរបន្ថែម។ សហព្រះរាជអាជ្ញាបានចង្អុលបញ្ជាក់ទៀតថា ដោយសារការស្តាប់ចម្លើយនានា ដែលត្រូវបានធ្វើឡើងដោយ ស.ច.ស ទាក់ទិននឹងខ្មែរក្រោមនៅឃុំរំលេចនៅក្នុងអំឡុងពេលនៃការបំពេញកិច្ចស៊ើបសួរលើសំណុំរឿងលេខ ០០២ ព្រមទាំងមានការបំពេញកិច្ចស៊ើបសួរបន្ថែមទៀតកំពុងត្រូវបានដំណើរការ អនុលោមតាមដីកាសម្រេចរបស់ ស.ច.ស កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០[៥៣] នោះ សហព្រះរាជអាជ្ញាពុំជឿថា នឹងត្រូវមានកិច្ចស៊ើបសួរបន្ថែមដ៏សំខាន់ណាមួយ ដែលតម្រូវឱ្យអង្គបុរេជំនុំជម្រះធ្វើការសម្រេចថា សំណើទីមួយរបស់ខ្លួនមានលក្ខណៈសម្បត្តិជាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យ

---

[៥២] សេចក្តីបំភ្លឺរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០ និងកថាខណ្ឌ ១១។

[៥៣] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទិននឹងស្រុកបាកាន និងការទទួលយកភាគីដើមបណ្តឹងរដ្ឋប្បវេណីខ្មែរក្រោម ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០ D351/1។



PRE-TRIAL CHA... E.C.C.C • C.E.T.C ...AMBRE PRÉLIMINAIRE

00504327



ស៊ើបសួរ បន្ថែមឡើយ[៥៤]។ សហព្រះរាជអាជ្ញាក៏បានពិចារណាផងដែរថា នៅក្នុងសេណារីយ៉ូបែបនេះ វាអាស្រ័យលើ ស.ច.ស ជាអ្នកសម្រេចថាតើកិច្ចស៊ើបសួរបន្ថែមត្រូវធ្វើឡើងដែរឬយ៉ាងណា។ ដូចបានបញ្ជាក់ខាងលើ ហើយនឹងត្រូវលើកឡើងបន្ថែមនៅខាងក្រោមទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ទីពីរ ការទទួលខុសត្រូវលើការសម្រេចពង្រីកការស៊ើបអង្កេតលើសពីវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដែលមានស្រាប់នៅ ចំពោះមុខ អ.វ.ត.ក ជាបន្ទុកទាំងស្រុងរបស់សហព្រះរាជអាជ្ញា។ ចំពោះជំហរដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងសេចក្តីបំភ្លឺរបស់ខ្លួន អង្គបុរេជំនុំជម្រះបានជូនដំណឹងដល់ភាគីទាំងអស់ថា អង្គបុរេជំនុំជម្រះមិនទទួលយកបណ្តឹងឧទ្ធរណ៍ទីមួយឡើយ ដោយមិនចាំបាច់ឱ្យភាគីរង់ចាំការចេញសាលដីកានេះ និងការផ្តល់សម្អាងហេតុឡើយ[៥៥]។ សហព្រះរាជអាជ្ញា (និង ស.ច.ស ក្នុងករណីពាក់ព័ន្ធនឹងការបំពេញកិច្ចស៊ើបសួរបន្ថែម) ជាការិយាល័យដែលមានលក្ខណៈសមស្របជាងអង្គបុរេជំនុំជម្រះនៅក្នុងការវាយតម្លៃលើផលប៉ះពាល់ចំពោះពេលវេលា ដែលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមអាចមានលើការបញ្ចប់កិច្ចសំណុំរឿងលេខ ០០២ និងនៅក្នុងការថ្លឹងថ្លែងទំនាស់ផលប្រយោជន៍នីមួយៗដែលអាចកើតមានឡើងចំពោះភាគី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធ។ អង្គបុរេជំនុំជម្រះដឹងថា វាពិបាកកំណត់វិធីសាស្ត្រនេះ ហើយនៅពេលមិនដឹងថាសហព្រះរាជអាជ្ញានឹងសម្រេចនៅពេលចុងក្រោយថានឹងធ្វើអ្វីខ្លះទាក់ទិននឹងករណីនេះផងនោះ អង្គបុរេជំនុំជម្រះសូមពិចារណាលើករណីថាតើបណ្តឹងឧទ្ធរណ៍ទីពីរនេះទទួលយកបាន ឬមិនបាន។

១៩. ស.ច.ស បានចេញ ដីកាទីពីរនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ហើយដីកានេះបានជូនដំណឹងដល់សហមេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០។ សហមេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

[៥៤] សេចក្តីបំភ្លឺរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១១។

[៥៥] សេចក្តីជូនដំណឹងរបស់ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ ជូនទៅគ្រប់ភាគី ផ្ញើជូននៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១០។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

បានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ ស្របតាមវិធាន ៧៥(១)នៃវិធានផ្ទៃក្នុង។ ក្រោយមក បណ្ដឹងឧទ្ធរណ៍ទីពីរបានដាក់នៅទី១២ ខែកុម្ភៈ ឆ្នាំ២០១០ ស្របតាមពេលវេលាកំណត់ដូចមានចែងនៅក្នុងវិធាន ៧៥(៣)នៃវិធានផ្ទៃក្នុង។

២០. បណ្ដឹងឧទ្ធរណ៍ទីពីរបានដាក់ស្របតាមវិធាន ៧៤(៤)(ខ)នៃវិធានផ្ទៃក្នុង ដែលអនុញ្ញាតឱ្យដើមបណ្ដឹងរដ្ឋប្បវេណីប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ ស.ច.ស ចំពោះការប្រកាសមិនទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ អង្គបុរេជំនុំជម្រះរលឹកថា លើកលែងតែមួយករណីតែប៉ុណ្ណោះ[៥៦] ក្រៅពីនេះភាគីបណ្ដឹងឧទ្ធរណ៍នៅក្នុងបណ្ដឹងឧទ្ធរណ៍ទីពីរ គឺជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលពាក្យសុំរបស់ខ្លួនត្រូវបានដីកាទីពីរប្រកាសមិនទទួលស្គាល់[៥៧]។ ហេតុដូច្នេះ បណ្ដឹងឧទ្ធរណ៍ទីពីរនេះអាចទទួលយកបានដោយមិនមានអ្វីត្រូវជំទាស់។

## IV. **អង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍ទីពីរ**

២១. ដូចដែលបានកត់សម្គាល់ជាបឋមរួចហើយ អង្គបុរេជំនុំជម្រះរំលឹកអំពីបទដ្ឋាននៃការពិនិត្យឡើងវិញ ដែលអនុវត្តនៅចំពោះមុខអង្គបុរេជំនុំជម្រះ។ ភាគីបណ្ដឹងឧទ្ធរណ៍ដែលមានបំណងសុំឱ្យច្រានចោលសេចក្ដីសម្រេចណាមួយរបស់ ស.ច.ស ត្រូវបង្ហាញថា (១) សេចក្ដីសម្រេចដែលខ្លួនតវ៉ានោះ ផ្អែកលើការបកស្រាយមិនត្រឹមត្រូវលើច្បាប់ជាធរមាន (២) ផ្អែកលើការសន្និដ្ឋានមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែតលើអង្គហេតុ ឬ (៣) សេចក្ដីសម្រេចនោះ ធ្វើឡើង

---

[៥៦] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់គឺ [redacted]16 បានទទួលមរណភាព។ ដីកាទីពីរដែលត្រូវបានជំទាស់ កថាខណ្ឌ ២ ជើងទំព័រ ២។ *សូមមើលផងដែរ* បណ្ដឹងឧទ្ធរណ៍ទីពីរ ជើងទំព័រ១ លើកឡើងថា នៅពេលដាក់ដីកាទីពីរដែលត្រូវបានជំទាស់ មានការព្យាយាមសុំឱ្យគ្រួសារ [redacted]16 បញ្ចេញមតិយោបល់ថាតើគេចង់ចាត់ការយ៉ាងដូចម្ដេចចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ក្រោយមកការព្យាយាមនេះបានលុបចោលវិញ ក្រោយពេលចេញដីកាទីពីរដែលត្រូវបានជំទាស់។

[៥៧] *សូមមើល* កថាខណ្ឌ៥ និងជើងទំព័រ ២០ *កថាខណ្ឌខាងលើ*។



E.C.C.C • C.E.T.C PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

តាមឆន្ទានុសិទ្ធិ ហើយមានភាពអយុត្តិធម៌ ឬមិនសមហេតុផល ដូច្នេះវាបង្កើតជាការរំលោភលើឆន្ទានុសិទ្ធិរបស់ ក.ស.ច.ស [៥៨]។

២២. អង្គបុរេជំនុំជម្រះយល់ឃើញថា ខ្លួនអាចទាត់ចោលទឡ្ហីករណ៍របស់ភាគីណាដែលមិនមានសក្តានុពលនាំដល់ការច្រានចោល ឬកែប្រែសេចក្តីសម្រេចដែលត្រូវបានជំទាស់ ដោយមិនចាំបាច់ពិនិត្យដល់អង្គសេចក្តី[៥៩]។ ចំពោះលក្ខខណ្ឌនៃទម្រង់វិញ ភាគីបណ្តឹងឧទ្ធរណ៍ត្រូវផ្តល់សេចក្តីយោងឱ្យបានច្បាស់លាស់លើទំព័រនៃប្រតិចារឹក ឬ កថាខណ្ឌទាំងឡាយដែលពាក់ព័ន្ធនៅក្នុងសេចក្តីសម្រេចដែលខ្លួនតវ៉ា[៦០]។ អង្គបុរេជំនុំជម្រះនឹងមិនផ្តល់សេចក្តីពិចារណារបស់ខ្លួនពិស្តារចំពោះសារណាទាំងឡាយណាដែលបានលើកឡើងមិនច្បាស់លាស់ ផ្ទុយគ្នា ឬស្រពិចស្រពិលឡើយ ឬ សារណាទាំងឡាយណាដែលដកស្រង់ចេញពីសារណាផ្លូវការដទៃដែលមិនមានលក្ខណៈគ្រប់គ្រាន់[៦១]។ ដូច្នេះ ជាគោលការណ៍ អង្គបុរេជំនុំជម្រះនឹងបដិសេធចោលសារណាទាំងឡាយណាដែលគ្មានមូលដ្ឋានហើយមិនចាំបាច់ផ្តល់សម្អាងហេតុពិស្តារ[៦២]។

---

[៥៨] សាលដីកាជាសារណៈលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ២៥-២៧ បានយកលំនាំតាមលក្ខខណ្ឌសាកល្បងដែលបានបង្កើតឡើងនៅអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃ ICTY នៅក្នុងបណ្តឹងឧទ្ធរណ៍បន្ទាន់បង្អួចក្នុងរឿងក្តី *Slobodan Milosevic ទល់នឹង រដ្ឋអាជ្ញា* IT-02-54-AR73.7 ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៤។

[៥៩] សូមអានបរិបទនៅក្នុងសាលដីកានៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY និង ICTR លើរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Blaskic* រឿងក្តី ICTY IT-95-14 "សាលដីកា" ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ ("សាលដីកា Blaskic") កថាខណ្ឌទី ១៥ យោងលើរឿងក្តី Rutaganda ទល់នឹង រដ្ឋអាជ្ញា សាលដីកា រឿងក្តី ICTR-96-3-A "សាលដីកា" ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣ ("សាលដីកា Rutaganda") កថាខណ្ឌទី ១៨។

[៦០] សាលដីកា Blaskic កថាខណ្ឌទី ១៥ និងសាលដីកា Rutaganda កថាខណ្ឌទី ១៩។

[៦១] សូមអានបរិបទនៅក្នុងសាលដីកានៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY និង ICTR *រដ្ឋអាជ្ញា ទល់នឹង Dragoljub Radomir Kovac និង Zoran Vukovic* រឿងក្តី IT-96-23 & IT-96-23/1-A "សាលដីកា" ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ សាលដីកា កថាខណ្ឌទី ៤៣។

[៦២] សូមមើលសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ *Rutaganda* កថាខណ្ឌ ១៩។



PRE-TRIAL CHAMBER • E.C.C.C • C.E.T.C • CHAMBRE PRELIMINAIRE

២៣. បណ្ដឹងឧទ្ធរណ៍ទីពីរចោទប្រកាន់ថា ខ្មែរក្រោម និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជាជនជាតិវៀតណាមទាំងអស់ ស្ថិតនៅក្នុងយុត្តាធិការនៃអ.វ.ត.ក[៦៣] និងវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ហើយកិច្ចស៊ើបសួរដែលបានបំពេញដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងខេត្តកំពង់ឆ្នាំង បានដាក់ឱ្យជនជាតិវៀតណាមស្ថិតនៅក្នុងវិសាលភាពនៃអង្គហេតុដែលស្ថិតនៅក្រោមការស៊ើបអង្កេត[៦៤]។ បណ្ដឹងឧទ្ធរណ៍ទីពីរនេះក៏បានចោទប្រកាន់ដែរថា ដីកាទីពីរ (i) បានចេញមុនកាលបរិច្ឆេទកំណត់ ពីព្រោះវិសាលភាពនៃកិច្ចស៊ើបសួរនៅមិនទាន់បានកំណត់ពេញលេញនៅឡើយ[៦៥] (ii) បានធ្វើឡើងផ្ទុយពីគោលការណ៍ជាសារវន្តរបស់ អ.វ.ត.ក ទាក់ទងនឹងការចូលរួមរបស់ជនរងគ្រោះ ហើយបានធ្វើឡើងដោយគ្មានមូលហេតុ[៦៦] (iii) មានកំហុសអង្គច្បាប់ នៅពេលដែលសហចៅក្រមស៊ើបអង្កេតប្រកាសមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលខ្លួនបានទទួលស្គាល់រួចហើយ[៦៧] (iv) មិនពិចារណាព័ត៌មានពាក់ព័ន្ធទាំងអស់ ហើយបានបដិសេធអ្នកដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីវៀតណាម រួមគ្នាតែម្ដង (*en masse*)[៦៨] ហើយ (v) បានប៉ះពាល់ដល់រឿងក្ដីទាំងមូលរបស់អ.វ.ត.ក លើបទប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម[៦៩]។

២៤. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដីកាទីពីរបានប្រកាសមិនទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួនដប់ប្រាំមួយ ដែលអ្នកទាំងនេះកំណត់អត្តសញ្ញាណខ្លួនឯងថាជនជាតិវៀតណាមមកពីខេត្តកំពង់ឆ្នាំង និងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួនដប់

---

[៦៣] បណ្ដឹងឧទ្ធរណ៍ទីពីរ ផ្នែក II កថាខណ្ឌ ១ (ក) ៣ (ក) និង ៣ (គ)។

[៦៤] បណ្ដឹងឧទ្ធរណ៍ទីពីរ ផ្នែក II កថាខណ្ឌ ១ (ខ) ៣ (ខ) និង ៣ (ឃ)។

[៦៥] បណ្ដឹងឧទ្ធរណ៍ទីពីរ ផ្នែក II កថាខណ្ឌ ១ (គ)។

[៦៦] បណ្ដឹងឧទ្ធរណ៍លើកទីពីរ ផ្នែក II កថាខណ្ឌ ១ (ឃ) និង ១ (ង)។

[៦៧] បណ្ដឹងឧទ្ធរណ៍លើកទីពីរ ផ្នែក II កថាខណ្ឌ ៣ (ង)។

[៦៨] បណ្ដឹងឧទ្ធរណ៍លើកទីពីរ ផ្នែក II កថាខណ្ឌ ៣ (ច)។

[៦៩] បណ្ដឹងឧទ្ធរណ៍លើកទីពីរ ផ្នែក II កថាខណ្ឌ ៣ (ឆ)។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C • C.E.T.C

ប្រាំពីរទៀត ដែលអ្នកទាំងនេះកំណត់អត្តសញ្ញាណខ្លួនឯងថាជនជាតិភាគតិចខ្មែរ[៧០] ដោយផ្អែកលើមូលដ្ឋានថា "អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនបានបង្ហាញអំពីទំនាក់ទំនងហេតុ និងបច្ច័យរវាងព្យសនកម្មដែលអះអាង និងអង្គហេតុដែលជាកម្មវត្ថុនៃការស៊ើបសួរ"[៧១]។

២៥. ការរកឃើញខាងលើដែលត្រូវបានតវ៉ា គឺផ្អែកលើវិធីសាស្ត្រខាងក្រោម៖

- ដើម្បីអាចឱ្យទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន "អ្នកដាក់ពាក្យសុំត្រូវបង្ហាញអំពីព្យសនកម្មដែលកើតចេញតែពីអង្គហេតុទាំងឡាយណាដែលត្រូវបានបើកការស៊ើបអង្កេតរួចហើយ និយាយនៅក្នុងបរិបទនេះគឺ ការប្រព្រឹត្តលើជនជាតិវៀតណាមនៅខេត្តព្រៃវែង និងខេត្តស្វាយរៀង និងក្នុងអំឡុងពេលនៃការចូលលុកលុយនៅក្នុងដែនដីវៀតណាម"។
- "អនុលោមតាមកថាខណ្ឌទី ៦៩ និងកថាខណ្ឌទី ៧០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ [ស.ច.ស] ទទួលបានអង្គហេតុដែលទាក់ទិននឹងការប្រព្រឹត្តលើជនជាតិវៀតណាមនៅខេត្តព្រៃវែង និងខេត្តស្វាយរៀង និងក្នុងអំឡុងពេលនៃការចូលលុកលុយប្រទេសវៀតណាម។ សហព្រះរាជអាជ្ញាមិនទទួលបានអង្គហេតុដែលប្រព្រឹត្តចំពោះប្រជាជនខ្មែរក្រោមនៅខេត្តពោធិសាត់ និងខេត្តតាកែវ និងអង្គហេតុដែលប្រឆាំងចំពោះជនជាតិវៀតណាមនៅខេត្តកំពង់ឆ្នាំងឡើយ"[៧២]។ ហេតុដូច្នេះ ដីកាទីពីរសន្និដ្ឋានថា អង្គហេតុដែលបានប្តឹងនេះ ខុសគ្នាទាំងស្រុងពីអង្គហេតុដែល ស.ច.ស ទទួលបាននាពេលបច្ចុប្បន្ន[៧៣]។

២៦. នៅពេលរកឃើញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់បានផ្តល់ភស្តុតាងគ្រប់គ្រាន់ដែលអាចឱ្យពិចារណាសមហេតុផលថា ពួកគេបានទទួលរងព្យសនកម្ម

[៧០] សូមមើលជើងទំព័រ៧ និង៨ ខាងលើ ក៏ដូចជាដីកាទីពីរដែលត្រូវបានជំទាស់ ទំព័រ ៨។

[៧១] ដីកាទីពីរដែលត្រូវបានជំទាស់ ទំព័រ ១៩។

[៧២] ដីកាទីពីរដែលត្រូវបានជំទាស់ កថាខណ្ឌ ១១។

[៧៣] ដីកាទីពីរដែលត្រូវបានជំទាស់ កថាខណ្ឌ ១៩ (គូសបញ្ជាក់បន្ថែម)។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00504332



ដោយផ្ទាល់លើរូបខ្លួន ស.ច.ស បានធ្វើការផ្ទៀងផ្ទាត់ថាតើព្យសនកម្មដែលបានចោទប្រកាន់នោះមានការពាក់ព័ន្ធនឹង*អង្គហេតុដទៃដែលស្ថិតនៅក្រោមការស៊ើបអង្កេត* ដូចដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដែរឬយ៉ាងណា[៧៤]។ ដោយសារហេតុដូច្នេះ ស.ច.ស បានពិចារណាថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនដប់នាក់ បានផ្តល់ភស្តុតាងគ្រប់គ្រាន់ក្នុងការបង្ហាញ*ជាបឋម* (*prima facie*) ថា ព្យសនកម្មរបស់ពួកគេកើតចេញពីផលវិបាកដោយផ្ទាល់ពីអង្គហេតុដែលស្ថិតនៅក្រោមវិសាលភាពនៃការស៊ើបអង្កេត ដូចដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[៧៥]។ ផ្ទុយមកវិញ ចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនសាមសិបពីរនាក់វិញ ស.ច.ស បានរកឃើញថា មិនមានកាលៈទេសៈណាអនុញ្ញាតឱ្យខ្លួនពិចារណាឃើញថាអាចមានទំនាក់ទំនងផ្ទាល់រវាងព្យសនកម្ម និងឧក្រិដ្ឋកម្មទាំងឡាយ ដែលបានចោទប្រកាន់ និងកំពុងស្ថិតនៅក្រោមការស៊ើបអង្កេតឡើយ[៧៦]។ ប៉ុន្តែ យើងត្រូវកត់សម្គាល់ថា ដីកាទីពីរបានរកឃើញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់បានបញ្ជាក់យ៉ាងត្រឹមត្រូវថា ខ្លួនជារូបវន្តបុគ្គល និងបានផ្តល់ភស្តុតាងអំពីអត្តសញ្ញាណរបស់ខ្លួនរួចហើយ[៧៧]។

---

[៧៤] ដីកាទីពីរដែលត្រូវបានជំទាស់ កថាខណ្ឌ ១១។

[៧៥] ដីកាទីពីរដែលត្រូវបានជំទាស់ កថាខណ្ឌ ១៨ ទាក់ទិននឹងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានបង្ហាញថា ព្យសនកម្មរបស់ពួកគេ គឺជាផលវិបាកដោយផ្ទាល់នៃ (i) ការធ្វើទុក្ខបុកម្នេញលើព្រះសង្ឃនៅលើទឹកដីកម្ពុជាប្រជាធិបតេយ្យ ដែលស្ថិតនៅក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក (កថាខណ្ឌទី ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ) និង/ឬ (ii) ការចូលលុកលុយដោយកងកម្លាំងកម្ពុជាប្រជាធិបតេយ្យនៅក្នុងដែនដីវៀតណាមនៅក្នុងឆ្នាំ១៩៧៨ (កថាខណ្ឌទី ៧០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ) (iii) ការជម្លៀសប្រជាជនភ្នំពេញ (កថាខណ្ឌទី ៣៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ) និង (iv) ការរៀបការដោយបង្ខំ (ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩) និង (v) ការបញ្ជូនដោយបង្ខំពីភូមិភាគបូព៌ា និងជាពិសេសពីខេត្តព្រៃវែង និងខេត្តស្វាយរៀង ទៅខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង (កថាខណ្ឌទី ៤២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ)។

[៧៦] ដីកាទីពីរដែលត្រូវបានជំទាស់ កថាខណ្ឌ ១៩។

[៧៧] ដីកាទីពីរដែលត្រូវបានជំទាស់ កថាខណ្ឌ ១៥។

00504333



២៧. វិធាន ៧៧ ស្ទួន នៃវិធានផ្ទៃក្នុង ដែលបានអនុម័តនៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ ចែងថា ដើមបណ្តឹងឧទ្ធរណ៍ត្រូវផ្តល់ហេតុផលដែលខ្លួនចោទប្រកាន់ថា ស.ច.ស មានកំហុសអង្គហេតុ និង/ឬអង្គច្បាប់ក្នុងការសម្រេចអំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្របតាមវិធាន ២៣ ស្ទួន នៃវិធានផ្ទៃក្នុង។ វិធាននេះបានចូលជាធរមាននៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០ គឺក្រោយថ្ងៃដាក់បណ្តឹងឧទ្ធរណ៍ទីពីរ។ ទោះបីជាយ៉ាងនេះក្តី អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វិធានថ្មីនេះបានត្រឹមតែបញ្ញត្តិអំពីលក្ខខណ្ឌជាក់ស្តែងដែលបានសម្រេចរួចហើយនៅក្នុងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ[៧៨]។ នៅខាងក្រោមនេះ មូលដ្ឋានទាំងឡាយ ឬ មូលដ្ឋានតូចៗស្ទើរតែទាំងអស់នៅក្នុងបណ្តឹងឧទ្ធរណ៍ទីពីរលើកឡើងច្បាស់អំពីហេតុផលអ្វីបានជាមានការចោទប្រកាន់ថា ដីកាទីពីរមានកំហុស។ អង្គបុរេជំនុំជម្រះនឹងពិនិត្យការចោទប្រកាន់ទាំងនេះមួយម្តងៗ ដោយចាប់ផ្តើមពីការចោទប្រកាន់ថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលជាខ្មែរក្រោម និងវៀតណាមទាំងអស់នោះស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក។ ហេតុដូច្នេះ អ្នកទាំងនេះអាចទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីបាន[៧៩]។

**ក. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលជាខ្មែរក្រោម និងវៀតណាមចោទប្រកាន់ថា ព្យសនកម្មទាំងឡាយកើតចេញពីផលវិបាកនៃឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក។**

២៨. ភាគីបណ្តឹងឧទ្ធរណ៍តវ៉ាថា វិធាន ២៣(១)(ក)នៃវិធានផ្ទៃក្នុងចែងអំពីគោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញគឺដើម្បីចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់។ វិធាននេះមិនបានដាក់ដែនកម្រិតចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធី ដែល

---

[៧៨] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ២៥-២៧។

[៧៩] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក II កថាខណ្ឌ ១ (ក) និង ៣ (ក) និង ៣ (គ)។



E.C.C.C • C.E.T.C PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00504334



ស្ថិតនៅក្នុងវិសាលភាពនៃការស៊ើបអង្កេតដែលបានចោទប្រកាន់ឡើយ។ ទោះបីវាជាការលើកឡើងត្រឹមត្រូវថា វិធាន ២៣(១)(ក)នៃវិធានផ្ទៃក្នុង កម្រិតការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រឹមតែជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងឡាយដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ក៏ដោយ ក៏ការលើកឡើងដូច្នេះត្រូវតែច្រានចោល ពីព្រោះវាមិនបានពិចារណាលើលក្ខខណ្ឌបន្ថែមដែលចែងថា ដើម្បីអាចឱ្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទទួលយកបាន អ្នកដាក់ពាក្យសុំត្រូវបង្ហាញថា ខ្លួនបានទទួលរងព្យសនកម្មដោយសារផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋយ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើនដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ។

២៩. តាមពិតទៅ យោងតាមខ្លឹមសារ ទាំងវិធាន ២៣(២) នៃវិធានផ្ទៃក្នុង ដែលនៅជាធរមានចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗដែលត្រូវបានគេដាក់ចូលទៅក្នុងសំណុំរឿង[៨០] ទាំងវិធាន២៣ ស្ទួន (១)(ខ) ដែលបានចូលជាធរមានក្រោយពេលបណ្តឹងឧទ្ធរណ៍ទីពីរបានដាក់ប្តឹង[៨១] ចែងថា ដើម្បីអាចឱ្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទទួលយកបាន អ្នកដាក់ពាក្យសុំត្រូវបង្ហាញ*ក្នុងចំណោមភស្តុតាងទាំងឡាយ*ថា ខ្លួនបានទទួលរងព្យសនកម្មដោយសារផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋយ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើនដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ។

---

[៨០] វិធាន ២៣(២)នៃវិធានផ្ទៃក្នុង (វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៣) បានអនុម័តនៅថ្ងៃទី៦ ខែមីនា ឆ្នាំ២០០៩ ដែលដូចគ្នានៅក្នុងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងវិធាន ២៣(២) នៃវិធានផ្ទៃក្នុង (វិសោធនកម្ម លើកទី៤) បានអនុម័តនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩) ចែងនៅក្នុងបទប្បញ្ញត្តិដែលពាក់ព័ន្ធថា ដើម្បីឱ្យដើម្បីឱ្យពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចទទួលយកបានព្យសនកម្មត្រូវតែជា "ផលវិបាកដោយផ្ទាល់ពីបទល្មើសជាព្យសនកម្មផ្ទាល់ខ្លួន និងបានកើតមានពិតប្រាកដមកទល់បច្ចុប្បន្ន"។

[៨១] វិធាន ២៣ ស្ទួន(២) នៃវិធានផ្ទៃក្នុង (វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៥) បានអនុម័តនៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ បានចូលជាធរមាននៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០ ចែងនៅក្នុងបទប្បញ្ញត្តិដែលពាក់ព័ន្ធថា ដើម្បីអាចឱ្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទទួលយកបាន "ខ្លួនត្រូវបង្ហាញថា ខ្លួនបានទទួលរងព្យសនកម្មដោយសារផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋយ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើនដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ ដែលព្យសនកម្មនេះជាមូលដ្ឋាននៃការទាមទារសំណងជាសមូហភាព និងសំណងផ្លូវចិត្ត។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C • C.E.T.C

៣០. ចំពោះទឡ្ហីករណ៍មួយទៀតដែលថា តុលាការមិនត្រូវបោះបង់ចោលយុត្តាធិការស៊ើបអង្កេតលើភស្តុតាងដែលផ្តល់ជូនដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលជាខ្មែរក្រោម (និងជនជាតិវៀតណាម)[៨២] ស.ច.ស បានលើកឡើងយ៉ាងត្រឹមត្រូវថា ផ្ទុយពីក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា "ជនរងគ្រោះដែលមានបំណងសុំតាំងជាដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើទៅបានតែតាមផ្លូវអន្តរាគមន៍ប៉ុណ្ណោះ ដោយភ្ជាប់ការស្នើសុំរបស់ខ្លួនជាមួយនឹងបណ្តឹងអាជ្ញាដែលកំពុងដំណើរការ"[៨៣]។ វិធាន ៥៥(៣)នៃវិធានផ្ទៃក្នុងកម្រិតវិសាលភាពនៃការស៊ើបអង្កេតទៅតាមការកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ប៉ុន្តែនៅក្នុងករណីនេះ ប្រសិនបើ ស.ច.ស បានដឹងនៅក្នុងអំឡុងពេលស៊ើបអង្កេតអំពីអង្គហេតុថ្មីណាមួយដែលខ្លួនពិចារណាឃើញថាវាហួសពីវិសាលភាពនៃការស៊ើបអង្កេតលើកលែងតែអង្គហេតុដែលជាស្ថានទម្ងន់ទោស ដូចមានស្រាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ស.ច.ស ត្រូវបញ្ជូនអង្គហេតុថ្មីទាំងនេះទៅសហព្រះរាជអាជ្ញា ដែលជាអ្នកមានការទទួលខុសត្រូវតែមួយគត់នៅក្នុងការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ស.ច.ស មិនត្រូវធ្វើការស៊ើបអង្កេតអង្គហេតុទាំងនេះ លើកលែងតែខ្លួនបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើអង្គហេតុទាំងនេះ។ អង្គបុរេជំនុំជម្រះយល់ឃើញថា នៅពេលយើងអានវិធានផ្ទៃក្នុងឱ្យបានសមស្របលើករណីទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងកាតព្វកិច្ចរបស់ ស.ច.ស ចំពោះអង្គហេតុថ្មីដែលខ្លួនបានដឹងក្នុងអំឡុងពេលស៊ើបអង្កេត វិធានផ្ទៃក្នុងនេះមិនផ្តល់ជាមូលដ្ឋានគាំទ្រដល់ទឡ្ហីករណ៍របស់ភាគីបណ្តឹងឧទ្ធរណ៍ឡើយ។

៣១. អង្គបុរេជំនុំជម្រះនៅពេលនេះនឹងពិនិត្យមើលការចោទប្រកាន់ផ្សេងទៀតរបស់ភាគីបណ្តឹងឧទ្ធរណ៍ដែលថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលជាខ្មែរក្រោមមួយ

---

[៨២] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក II កថាខណ្ឌ ៥ និងកថាខណ្ឌ៣៤ ដោយមានសេចក្តីយោង។

[៨៣] ដីកាទីពីរដែលត្រូវបានជំទាស់ កថាខណ្ឌ ៨ យោងទៅលើមាត្រា ១៣៨-១៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ចំនួន[៨៤] និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនជាតិវៀតណាមទាំងអស់[៨៥] ស្ថិតនៅក្នុងវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

**ខ. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនជាតិខ្មែរក្រោមមួយចំនួន និងរបស់ជនជាតិវៀតណាមទាំងអស់ស្ថិតនៅក្រោមវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ**

៣២. ភាគីបណ្តឹងឧទ្ធរណ៍បានបង្កើតនូវមូលដ្ឋានតូចៗចំនួនប្រាំនៅក្នុងមូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍នេះដោយបានលើកឡើងថា: (i) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជនជាតិខ្មែរក្រោមទទួលរងនូវព្យសនកម្មដែលបណ្តាលមកពីឧក្រិដ្ឋកម្មទាំងឡាយ ដែលស្ថិតក្រោមកិច្ចស៊ើបសួរនៅខេត្តតាកែវ។ (ii) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជនជាតិខ្មែរក្រោម ទទួលរងនូវព្យសនកម្មដែលពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មទាំងឡាយនៃការជម្លៀសមនុស្សចេញពីភូមិភាគបូព៌ាដែលស្ថិតក្រោមកិច្ចស៊ើបសួរ។ (iii) ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបានកំណត់ជ្រុលហួសហេតុចំពោះទីតាំងដែលមានការប្រព្រឹត្តិឧក្រិដ្ឋកម្មមកលើជនរងគ្រោះជនជាតិខ្មែរក្រោម និងជនជាតិវៀតណាម។ (iv) ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនជាតិវៀតណាមស្ថិតនៅក្រោមវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ និង (v) កិច្ចស៊ើបសួរទាំងឡាយដែលត្រូវបានធ្វើឡើងនៅខេត្តកំពង់ឆ្នាំងបានធ្វើឱ្យជនជាតិភាគតិចវៀតណាមស្ថិតនៅក្រោមវិសាលភាពនៃអង្គហេតុនានាដែលស្ថិតក្រោមកិច្ចស៊ើបសួរ។ អង្គបុរេជំនុំជម្រះនឹងពិនិត្យលើមូលដ្ឋានតូចៗនៃបណ្តឹងឧទ្ធរណ៍ទាំងអស់នេះមួយម្តងៗ។

**១. ខេត្តតាកែវ**

៣៣. យោងតាមដើមបណ្តឹងរដ្ឋប្បវេណី ដីកាទីពីរដែលមានការជំទាស់ មានវិការៈនៅក្នុងការប្រកាសថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះ [redacted]05[៨៦] មិនអាចទទួលយក

---

[៨៤] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ ៨-១៣។

[៨៥] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ ៣៥-៣៨។



E.C.C.C • C.E.T.C • PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

បាន ពីព្រោះគាត់បានលើកឡើងអំពីព្យសនកម្មដែលជាប់ពាក់ព័ន្ធទៅនឹងអង្គហេតុទាំងឡាយ[៨៧] ដែលស្ថិតក្រោមកិច្ចស៊ើបសួរ នៅឃុំស្រែរនោង ក្នុងខេត្តតាកែវ។

៣៤. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាបានសម្រេចបើកកិច្ចស៊ើបសួរមួយប្រឆាំងនឹងជនត្រូវចោទអំពីអង្គហេតុទាំងឡាយដែលបានគូសបញ្ជាក់នៅក្នុងកថាខណ្ឌទី៣៧ ដល់ទី៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[៨៨] រួមទាំងកថាខណ្ឌទី៤៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរផងដែរ ក្នុងនោះមាន ការឃុំខ្លួនដោយខុសច្បាប់ ការបង្ខំឱ្យធ្វើការជាទម្ងន់ ការផ្តល់អាហារមិនគ្រប់គ្រាន់ ទុរ្ភិក្សទ្រង់ទ្រាយធំ និងការចាប់ចងតាំទំនើងចិត្តដែល បានកើតមានឡើងនៅក្នុងសហករណ៍ដែលស្ថិតនៅក្នុងឃុំស្រែរនោងក្នុងស្រុកត្រាំកក់ ខេត្តតាកែវ នៅភូមិភាគនិរតី។ ដូចដែលបានចង្អុលបង្ហាញយ៉ាងត្រឹមត្រូវពីភាគីបណ្តឹងឧទ្ធរណ៍[៨៩] ពាក្យសុំរបស់គាត់បានសង្កត់ធ្ងន់ថា នៅចុងឆ្នាំ១៩៧៦ រូបគាត់ត្រូវគេចាប់ខ្លួន[៩០] យកទៅដាក់នៅក្នុងគុក ២០៤ ដែលស្ថិតនៅក្នុងភូមិព្រៃមោក ឃុំស្រែរនោង ដែលជាសហករណ៍មួយក្នុងចំណោមសហករណ៍នានាក្នុងស្រុកត្រាំកក់ ក្នុងខេត្តតាកែវ និងត្រូវបង្ខំឱ្យធ្វើការជាទម្ងន់ និងបង្អត់អាហារទៀតផង[៩១]។

៣៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដីកាទីពីរដែលត្រូវបានជំទាស់បានពិចារណាឃើញថា ចំណងទាក់ទងហេតុ និងផលរវាងព្យសនកម្មដែលបានលើកឡើង ជាមួយនឹងអង្គហេតុនានា

---

[៨៦] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ៩ យោងទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី [redacted]

[៨៧] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ៩ យោងទៅលើ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ៤៣។

[៨៨] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ១២២។

[៨៩] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ១០។

[៩០] ទម្រង់ព័ត៌មានស្តីពីជនរងគ្រោះ [redacted] 05 [redacted] ទំព័រ៥ បញ្ជាក់ថា គាត់ត្រូវចោទប្រកាន់ ពីសំណាក់ពួក ខ្មែរក្រហមថាជាទាហាន លន់ នល់។

[៩១] ទម្រង់ព័ត៌មានស្តីពីជនរងគ្រោះ [redacted] 05 [redacted] ទំព័រ៥ និយាយថា គាត់ត្រូវគេបង្ខំឱ្យធ្វើការជាទម្ងន់បង្ខំឱ្យគាស់ឫសឈើ និងថាទទួលបានអាហារតិចតួច ដោយទទួលបានរបបអាហារ២ពេលក្នុងមួយថ្ងៃ និងបញ្ជាក់ទៀតថា គាត់រស់រានមានជីវិតដោយសារ ហូបឫសឈើ និងស្លឹកឈើ។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ដែលស្ថិតក្រោមកិច្ចស៊ើបសួរមិនបានកើតមានឡើងនោះទេ[៥២]។ យោងតាមដីកាទីពីរដែលត្រូវបានជំទាស់បញ្ជាក់ថា អង្គហេតុនានាដែលត្រូវបានរាយការណ៍ គឺខុសប្លែកគ្នាទាំងស្រុងពីអង្គហេតុ នានាដែល ស.ច.ស បានទទួលនាពេលបច្ចុប្បន្ននេះ និងពុំមានកាលៈទេសៈណាមួយដែលត្រូវបានអនុញ្ញាតឲ្យ ស.ច.ស ធ្វើការពិចារណាទៅលើលទ្ធភាពនៃចំណងទាក់ទងផ្ទាល់រវាងព្យសនកម្មដែលបានលើកឡើង និងឧក្រិដ្ឋកម្មទាំងឡាយដែលស្ថិតក្រោមកិច្ចស៊ើបសួរដែលត្រូវបានចោទប្រកាន់នោះឡើយ[៥៣]។ អង្គបុរេជំនុំជម្រះយល់ឃើញថា ក្នុងវិសាលភាពដែលវាមានការពាក់ព័ន្ធទៅនឹងជនរងគ្រោះ [redacted]05 នោះ ការសន្និដ្ឋាននេះមិនបានគាំទ្រដល់ហេតុផលដែលបានលើកឡើងខាងលើទេ ហើយអង្គបុរេជំនុំជម្រះយល់ឃើញថា ស.ច.ស មានការភ័ន្តច្រឡំលើអង្គហេតុនៅក្នុងការធ្វើសន្និដ្ឋានបែបនេះ។ ហេតុនេះហើយ ការសន្និដ្ឋាននេះត្រូវបដិសេធចោល រីឯពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ [redacted]05 ត្រូវបានទទួលយកនៅត្រឹមកម្រិតដែលថាវាមានចំណងទាក់ទងគ្នារវាងព្យសនកម្មដែលបានចោទប្រកាន់ជាមួយនឹងឧក្រិដ្ឋកម្មនានាដែលបានលើកឡើងខាងលើ ដូចបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

## ២. ការជម្លៀសមនុស្សចេញពីភូមិភាគបូព៌ា

៣៦. យោងតាមភាគីបណ្ដឹងឧទ្ធរណ៍ ដីកាទីពីរមានវិការៈ នៅពេលប្រកាសថា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះ [redacted]14, [redacted]15, [redacted]19, [redacted]20, [redacted]23 និង [redacted]24[៥៤] មិនអាចទទួលយកបានទេ ពីព្រោះពួកគាត់បានរងការឈឺចាប់ដោយសារជម្ងឺផ្លូវចិត្តផ្ទាល់ខ្លួនដែលជាផលវិបាកដោយផ្ទាល់កើតចេញពីការដឹងឮអំពី ឧក្រិដ្ឋកម្មទាំងឡាយដែល

---

[៥២] ដីកាទីពីរដែលត្រូវបានជំទាស់ កថាខណ្ឌ១៦ ពាក់ព័ន្ធទៅនឹងជនរងគ្រោះ [redacted]05 ជាពិសេសនៅទំព័រ៥។

[៥៣] ដីកាទីពីរដែលត្រូវបានជំទាស់ កថាខណ្ឌ១៩។

[៥៤] បណ្ដឹងឧទ្ធរណ៍ទីពីរ កថាខណ្ឌ១១-១៣ និងជើងទំព័រ២៥ ដោយយោងទៅលើទម្រង់ព័ត៌មានជនរងគ្រោះ និងសំបុត្របញ្ជាក់សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី [redacted]14 [redacted]15 [redacted]19 [redacted]20 [redacted], [redacted]23 [redacted]24 [redacted]



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

កើតមាននៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ស្របតាមវិធាន ២៣ នៃវិធានផ្ទៃក្នុង[55]។ ចំពោះមូលហេតុដែលបានលើកឡើងនៅត្រង់កថាខណ្ឌទី២២ខាងលើ ទឡ្ហីករណ៍នេះមិនបានបង្ហាញពីវិការៈរបស់ ស.ច.ស ឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ភាគីបណ្ដឹងឧទ្ធរណ៍ក៏បានលើកឡើងផងដែរថា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ជនជាតិខ្មែរក្រោម លើកឡើងអំពីព្យសនកម្មដែលជាប់ពាក់ព័ន្ធ ទៅនឹងការជម្លៀសប្រជាជនជាច្រើននាក់ដោយបង្ខំ ចេញពីភូមិភាគបូព៌ា ជាពិសេស ចេញពីខេត្តព្រៃវែង និងខេត្តស្វាយរៀង និងបានគូសបញ្ជាក់ថាការជម្លៀសដោយបង្ខំនេះ បង្កើតបានជាផ្នែកមួយនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ហើយ ការជម្លៀសដោយបង្ខំនេះមានបំណង "បំបែកប្រជាជន និងក្រុមទាំងឡាយដែលបក្សកុម្មុយនីស្តកម្ពុជាបានចាត់ទុកថាអាចមិនមានភាពស្មោះត្រង់ឱ្យខ្ចាត់ខ្ចាយ"[56]។

៣៧. បន្ថែមពីលើសេចក្ដីដកស្រង់ចេញពីកថាខណ្ឌទី៤២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលបានលើកឡើងខាងលើ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា កថាខណ្ឌដែលចោទជាបញ្ហាបានលើកឡើងថា នៅពាក់កណ្ដាលឆ្នាំ១៩៧៨ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានចេញបញ្ជាឱ្យជម្លៀសក្នុងកម្រិតធំលើកទីបី ដែលបានធ្វើឱ្យប្រជាជនរាប់ម៉ឺននាក់ដែលកំពុងរស់នៅភូមិភាគបូព៌ាត្រូវបានផ្លាស់ទីសាជាថ្មីដោយបង្ខំ ទៅកាន់ភូមិភាគកណ្ដាល ភូមិភាគបស្ចិម និងភូមិភាគពាយ័ព្យ រួមទាំងប្រជាជនដែលមកពីខេត្តព្រៃវែង និង ខេត្តស្វាយរៀងផងដែរ។ កថាខណ្ឌនេះជាផ្នែកមួយនៃឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់ក្រោមចំណងជើងថា "ការជម្លៀសប្រជាជនដោយបង្ខំចេញពីភូមិភាគបូព៌ា: ដំណាក់កាលទី៣ ហើយកថាខណ្ឌនេះក៏បានលើកឡើងបន្ថែមទៀតថា ប្រជាជនជាច្រើននាក់ ត្រូវបានសម្លាប់ដោយគិតទុកជាមុន ឬបានស្លាប់ដែលជាលទ្ធផលផ្ទាល់នៃការជម្លៀសដោយបង្ខំ។

៣៨. បន្ទាប់ពីបានពិនិត្យលើពាក្យសុំទាំងប្រាំមួយដែលបានលើកឡើងខាងលើ អង្គបុរេជំនុំជម្រះ កត់សម្គាល់ឃើញថា ការសន្និដ្ឋានរបស់ដីកាទីពីរថា អង្គហេតុទាំងឡាយដែលត្រូវបានរាយការណ៍

---

[55] បណ្ដឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ១៣។

[56] បណ្ដឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ១១ និងជើងទំព័រ២៤ យោងទៅដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤២។



E.C.C.C. • C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

មានភាពខុសប្លែកគ្នាទាំងស្រុងពីអង្គហេតុទាំងឡាយ ដែល ស.ច.ស កំពុងទទួលបាននាពេល បច្ចុប្បន្ន និងពុំមានកាលៈទេសៈណាមួយដែលត្រូវបានអនុញ្ញាតឲ្យ ស.ច.ស ធ្វើការពិចារណា អំពីលទ្ធភាពនៃចំណងទាក់ទងគ្នារវាងព្យសនកម្ម ដែលបានលើកឡើង និងឧក្រិដ្ឋកម្មទាំងឡាយ ដែលបានចោទប្រកាន់ដែលស្ថិតក្រោមការស៊ើបអង្កេតនោះ[៣៧] គឺពុំមានមូលដ្ឋានគាំទ្រឡើយ ទាក់ទិននឹង [redacted]15, [redacted]19, [redacted]20, [redacted]23 និង [redacted]24 ពីព្រោះនៅក្នុងទម្រង់បែបបទ ព័ត៌មានជនរងគ្រោះរបស់ពួកគាត់ម្នាក់ៗ ព្រឹត្តិការណ៍ទាំងឡាយដែលពួកគាត់បានរៀបរាប់ និងជាលទ្ធផលដែលពួកគាត់បានលើកឡើងថាជាការខូចខាតផ្នែកស្មារតីនោះ មានការជាប់ ពាក់ព័ន្ធទៅនឹងការផ្លាស់ប្តូរទីកន្លែងប្រជាជនដោយបង្ខំចេញពីភូមិភាគបូព៌ាទៅកាន់ភូមិភាគ កណ្តាល ភូមិភាគបស្ចិម និងភូមិភាគពាយ័ព្យ ដូចមានលើកឡើងដូចខាងក្រោម៖

- ជនរងគ្រោះ [redacted]15 ដែលកំពុងរស់នៅស្រុកភ្នំក្រវាញ មុនរបបខ្មែរក្រហមកើតឡើង បាន និយាយថា នៅឆ្នាំ១៩៧៨ រូបគាត់ និងកូនៗរបស់គាត់ត្រូវគេនាំយកទៅភូមិកំប្រាក់កូន ឃុំខ្នារទទឹង ស្រុកបាកាន ខេត្តពោធិសាត់ ជាកន្លែងដែលពួកគាត់ត្រូវបានចាត់តាំងឲ្យទៅ ធ្វើចំការ រនាស់ និងត្រូវបង្ខំឲ្យធ្វើការជាទម្ងន់។ គាត់បានលើកឡើងថា នៅក្នុងឆ្នាំដដែល ខ្មែរ ក្រហម បាននាំជនជាតិខ្មែរក្រោម និងជនជាតិវៀតណាម ដែលត្រូវបានចោទប្រកាន់ថាជា ខ្មាំងយកទៅទួលគ (ភូមិដំណាក់ធ្លង់ ឃុំខ្នារទទឹង ស្រុកបាកាន) និងទួលបែន (ភូមិ រូងតាកុក ឃុំរំលេច ស្រុកបាកាន) ដើម្បីសម្លាប់ចោល។ នៅខាងក្រោមសក្ខីកម្មដែលគាត់បានលើកឡើង នេះបន្ថិចមានប្រធានបទមួយដែលមានចំណងជើងថា “ជនរងគ្រោះភូមិភាគបូព៌ាដែលជា មុខសញ្ញា (sic)” គាត់បង្ហាញថា គាត់បានឃើញទាហានខ្មែរក្រហម*សម្លាប់ប្រជាជន ដែលមកពី ភូមិភាគបូព៌ា* ដោយប្រើចំពុះទង់ M16 អាករបស់ពួកគេ។ ដោយពុំមានព័ត៌មាន ផ្សេងពីនេះនៅលើទម្រង់ព័ត៌មានអំពីជនរងគ្រោះនោះ អង្គបុរេជំនុំជម្រះយល់ឃើញថា ជនរងគ្រោះ [redacted]15 បានចោទប្រកាន់ថា ព្រឹត្តិការណ៍ដែលគាត់បានឃើញក៏បានកើតឡើងនៅក្នុងឆ្នាំ១៩៧៨

---

[៣៧] ដីកាទីពីរដែលត្រូវបានជំទាស់ កថាខណ្ឌ១៩។



E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

ផងដែរ ខណៈពេលដែលគាត់ត្រូវបានបញ្ជូនទៅខេត្តពោធិសាត់រួចហើយនោះ[៩៨]។ លើសពីនេះទៀត ទោះបីជាជនរងគ្រោះ [redacted]15 បានលើកឡើងជាសំខាន់អំពីការខូចខាត ផ្នែកស្មារតីដោយសារការបាត់បង់កូនចំនួនពីរនាក់ និងប្រពន្ធរបស់គាត់យ៉ាងណាក៏ដោយ ដោយគិតពីអំពើហិង្សានៃព្រឹត្តិការណ៍ខាងលើដែលជនរងគ្រោះ [redacted]15 បញ្ជាក់ថាបាន ឃើញនោះ អង្គបុរេជំនុំជម្រះយល់ឃើញថា ជនរងគ្រោះក៏បានលើកឡើងផងដែរ អំពីការខូចខាតផ្នែកស្មារតីដែលកើតឡើងដោយសារព្រឹត្តិការណ៍ទាំងអស់នេះ។

- ជនរងគ្រោះ [redacted]19[៩៩] លើកឡើងថា នៅក្នុងចំណោមឧក្រិដ្ឋកម្មនានាពាក់ព័ន្ធនឹងការកំណត់មុខសញ្ញា ជនរងគ្រោះភូមិភាគបូព៌ា នៅឆ្នាំ១៩៧៨ គាត់បានឃើញប្រជាជនប្រហែលជា២០នាក់ *ដែលមកពីខេត្តស្វាយរៀង* ដោយដៃពួកគាត់ត្រូវគេចងស្លាបសេក បានដើរជាជួរពីភូមិ មួយនៃខេត្តបាត់ដំបងទៅភូមិមួយទៀតនៃខេត្តបាត់ដំបងដដែល។ គាត់ក៏បានឃើញរណ្ដៅសាកសព ជាច្រើនដែលមានសាកសពជនជាតិខ្មែរក្រោម និងសាកសពជនជាតិវៀតណាមដែលអាក្រាត ហើយគាត់ត្រូវបានប្រធានអង្គភាពរបស់គាត់បង្ខំឱ្យលុបរណ្ដៅសាកសព ទាំងអស់នេះ។ ក្នុងនោះ ជនរងគ្រោះ [redacted]19 ក៏បានលើកឡើងផងដែរអំពីការឈឺចាប់ផ្នែកស្មារតីដែលកើតឡើង ដោយសារឧក្រិដ្ឋកម្មទាំងឡាយដែលគាត់បានឃើញ។
- ជនរងគ្រោះ [redacted]20[១០០] ដែលត្រូវបានគេផ្លាស់ទីកន្លែងទៅស្រុកបាកាន នៅឆ្នាំ១៩៧៦ រហូតដល់ឆ្នាំ១៩៧៩ បាននិយាយថា ក្នុងចំណោមឧក្រិដ្ឋកម្មទាំងឡាយផ្សេងទៀត ពាក់ព័ន្ធនឹងគោលដៅជនរងគ្រោះភូមិភាគបូព៌ា នៅឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ គាត់បានឃើញខ្មែរក្រហមព្យាយាមសម្លាប់ជនជាតិខ្មែរក្រោមទាំងអស់ដែលកំពុងរស់នៅក្នុងសហគមន៍របស់គាត់ ក៏ដូចជា *នាំយកប្រជាជន*ខ្មែរក្រោម និងប្រជាជនផ្សេងទៀតដែលត្រូវបានចោទប្រកាន់ថាជាជនជាតិវៀតណាម*ដែលមកពីខេត្តស្វាយរៀង* ទៅសម្លាប់ចោលផងដែរ។ ក្នុងនោះ ជនរងគ្រោះ [redacted]20 បានលើកឡើងអំពីការឈឺចាប់ផ្នែកស្មារតីផងដែរ។

---

[៩៨] ទម្រង់ព័ត៌មានស្ដីពីជនរងគ្រោះ [redacted]15 [redacted]

[៩៩] ទម្រង់ព័ត៌មានស្ដីពីជនរងគ្រោះ [redacted]19 [redacted]

[១០០] ទម្រង់ព័ត៌មានស្ដីពីជនរងគ្រោះ [redacted]20 [redacted]



PRE-TRIAL CHAMBER • E.C.C.C • C.E.T.C • CHAMBRE PRÉLIMINAIRE

- ជនរងគ្រោះ [redacted]23 និយាយថា កម្មាភិបាលទាំងឡាយដែលមកពីភូមិភាគនិរតីដែលសម្រេចដោយ តាម៉ុក បានចាប់ផ្តើមចាប់ខ្លួនអតីតកម្មាភិបាល និងមេឃុំ ប្រធាន សហករណ៍ ចៅហ្វាយស្រុក និងប្រធានតំបន់នានានៅភូមិភាគបូព៌ា និងបានចាប់ពួកគាត់ ដាក់គុក ព្រមទាំងបានសម្លាប់ពួកគាត់អស់ជាច្រើននាក់ ហើយក៏បាន*បញ្ជូនជនជាតិខ្មែរ ក្រោមទៅកាន់សហករណ៍នៅខ្នារទទឹង* ផងដែរ[101]។ ជនរងគ្រោះ [redacted]23 ក៏ហាក់ដូចជា ប្រាប់អំពីកាលបរិច្ឆេទនៃការសម្លាប់ឪពុកម្ដាយរបស់គាត់ និងបងប្អូនរបស់គាត់ផងដែរថា នៅចន្លោះខែកក្កដា និងខែសីហា ឆ្នាំ១៩៧៨ ប៉ុន្តែវាមិនច្បាស់ថាតើគាត់បានលើកឡើង ថាពួកគេត្រូវបានបំលាស់ទីដោយបង្ខំដែរឬយ៉ាងណាទេ[102]។ ជនរងគ្រោះ [redacted]23 និយាយ អំពីការខូចខាតផ្នែកស្មារតី ជាសំខាន់ពាក់ព័ន្ធនឹងការសម្លាប់សមាជិកក្រុមគ្រួសាររបស់ គាត់ ទោះបីជាយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះយល់ឃើញតាមចម្លើយរបស់ ជនរងគ្រោះ [redacted]23 ថា ឆ្នាំ១៩៧៨ គឺជាឆ្នាំអាក្រក់ជាងគេបំផុតនៅក្នុងរបបខ្មែរក្រហម នៅពេលដែលកម្មាភិបាលទាំងឡាយដែលមកពីភូមិភាគនិរតី ដែលបានសម្រេចដោយ តាម៉ុក ត្រូវបានផ្លាស់ទីកន្លែង រីឯឧក្រិដ្ឋកម្មនានាដែលបានលើកឡើងខាងលើត្រូវបានប្រព្រឹត្តឡើង ដែលធ្វើឱ្យរូបគាត់រងការឈឺចាប់ដោយសារព្រឹត្តិការណ៍ទាំងអស់នេះផងដែរ។
- ជនរងគ្រោះ [redacted]24 និយាយថា ការសម្លាប់ប្រជាជនដែលមកពីខេត្តស្វាយរៀងបានរាលដាល នៅក្នុងស្រុកបាកាន ខេត្តពោធិសាត់ ជាកន្លែងដែលគាត់ត្រូវបានឃុំខ្លួននៅក្នុងភូមិ វាល ឃុំតាលោ។ គាត់បានបន្ថែមថា ខ្មែរក្រហមបានព្យាយាម និងបានសម្លាប់ប្រជាជនមួយផង ចំនួន ១០០ នាក់ ហើយថារូបគាត់ និងអ្នកផ្សេងទៀតត្រូវគេបញ្ជាឱ្យជីករណ្ដៅ និង កប់សាកសពទាំងនោះ។ ប្រហែលជានៅខែកក្កដា ឆ្នាំ១៩៧៨ គាត់បានឮពួកគេនិយាយថា ពួកគេបានសម្លាប់ខ្មាំងយួនអស់រាប់ពាន់នាក់ហើយនៅក្នុងសហករណ៍រំលេច និងខ្នារទទឹង[103]។ ក្នុង

[101] ខេត្តពោធិ៍សាត់។

[102] ទម្រង់ព័ត៌មានស្តីពីជនរងគ្រោះ [redacted]23 [redacted]។

[103] ទម្រង់ព័ត៌មានស្តីពីជនរងគ្រោះ [redacted]24 [redacted]។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

នោះគាត់ បានលើកឡើងអំពីការខូចខាតផ្នែកស្មារតីដែលកើតឡើងពីការធ្វើបាបមកលើរូបគាត់ និងប្រជាជនផ្សេងទៀត។

តាមរយៈហេតុផលដែលបានលើកឡើងខាងលើ ដីកាទីពីរត្រូវតែបដិសេធចោល ពាក់ព័ន្ធនឹងជនរងគ្រោះ [redacted]15, [redacted]19, [redacted]20, [redacted]23 និង [redacted]24 រីឯ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេម្នាក់ៗ ត្រូវបានទទួលយកក្នុងវិសាលភាព ដែលវាមានចំណងទាក់ទងគ្នារវាងព្យសនកម្មដែលបានចោទប្រកាន់ និងឧក្រិដ្ឋកម្មទាំងឡាយដែលបានលើកឡើងខាងលើ។

៣៩. ផ្ទុយទៅវិញ ការពិនិត្យទម្រង់បែបបទព័ត៌មានជនរងគ្រោះដែលបានដាក់ដោយជនរងគ្រោះ [redacted]14[១០៤] មិនគាំទ្រដល់ការលើកឡើងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលថា ការសន្និដ្ឋាន ដែលបានជជែកតវ៉ាមានការភ័ន្តច្រឡំពាក់ព័ន្ធនឹងពាក្យសុំរបស់ខ្លួននោះឡើយ។ ហេតុនេះ មូលដ្ឋានតូចនៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានបដិសេធចោល។ អង្គបុរេជំនុំជម្រះងាកទៅ ពិនិត្យលើមូលដ្ឋានតូចមួយទៀតនៃបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលយោងតាមមូលដ្ឋាននេះ ការកំណត់អំពីវិសាលភាពនៃកិច្ចស៊ើបសួររបស់ ក.ស.ច.ស មានភាពចង្អៀតហួសហេតុ។

[១០៤] ទម្រង់ព័ត៌មានស្តីពីជនរងគ្រោះ [redacted]14 [redacted]។ បណ្តឹងឧទ្ធរណ៍ទីពីរ ជើងទំព័រលេខ ២៦ គ្រាន់តែបកស្រាយអំពីចម្លើយរបស់ជនរងគ្រោះ [redacted]14 ដោយពន្យល់អំពីអត្ថន័យនៃពាក្យស្លោក ដែលបានប្រើប្រាស់នៅពេលខ្លះ "ញ៉ាំផ្លែស្វាយល្អជាងផ្លែអម្ពិល" ប៉ុណ្ណោះ ដែលការរៀបរាប់របស់គាត់អំពីការសម្លាប់សមាជិកក្រុមគ្រួសាររបស់ជនជាតិខ្មែរក្រោមនៅឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ មិនបានសំដៅលើការផ្លាស់ទីកន្លែងដោយបង្ខំ ឬការផ្លាស់ទីមនុស្សដែលត្រូវបានគេសម្លាប់នោះទេ។

## ៣. តើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបានរឹតត្បិតហួសហេតុចំពោះបទឧក្រិដ្ឋនានា ដែលបានចោទប្រកាន់ប្រឆាំងនឹងជនរងគ្រោះជនជាតិខ្មែរក្រោម និងជនជាតិវៀតណាមតែក្នុងទីតាំងដែលដីកានោះបានចែងដែរឬទេ?

៤០. ភាគីបណ្តឹងឧទ្ធរណ៍លើកឡើងថា ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត ដែលបានសំអាងលើធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញក្រុមមនុស្សដែលជាគោលដៅ ភស្តុតាងនៃឧក្រិដ្ឋកម្មទាំងឡាយដែលបានលើកឡើងមិនត្រូវបានកំណត់ចំពោះតំបន់ទាំងឡាយជាក់លាក់នោះទេ។ រីឯវិសាលភាពនៃកិច្ចស៊ើបសួរ ត្រូវបានដីកាទីពីរកំណត់ដោយភ័ន្តច្រឡំចំពោះខេត្តនានាដែលបានរាយឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[១០៥]។ ភាគីបណ្តឹងឧទ្ធរណ៍អះអាងថា សហព្រះរាជអាជ្ញាបានប្រើប្រាស់តែហេតុការណ៍ជាក់លាក់ទាំងឡាយដែលកើតមាននៅក្នុងឃុំ និងនៅក្នុងមន្ទីរសន្តិសុខ ដែលមានរាយឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរប៉ុណ្ណោះ មកធ្វើជាភស្តុតាងនៃគម្រោងការប្រព្រឹត្តបទឧក្រិដ្ឋដ៏ទូលំទូលាយមួយ[១០៦] ដែលវិសាលភាពរបស់វាលាតសន្ធឹងហួសពីទីតាំង និងហេតុការណ៍រៀងៗខ្លួនទាំងនេះទៅទៀត។ ដូចនេះ ហេតុការណ៍នៃឧក្រិដ្ឋកម្មនានាបន្ថែមទៀតដែលបានលើកឡើងតាមរយៈពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនជាតិខ្មែរក្រោម ស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ ពីព្រោះហេតុការណ៍ទាំងនោះ បង្កើតបានជាធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញ/អំពើប្រល័យពូជសាសន៍នៃគម្រោងការរបស់ជនត្រូវចោទ។ ចំណែកឯ ស.ច.ស មានការភ័ន្តច្រឡំក្នុងការប្រកាសថា ពាក្យសុំទាំងអស់នោះមិនអាចទទួលយកបាន[១០៧]។

៤១. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចោទប្រកាន់ប្រឆាំងនឹងជនត្រូវចោទអំពីអត្ថិភាពនៃផែនការប្រព្រឹត្តបទឧក្រិដ្ឋរួមពាក់ព័ន្ធនឹងការរើសអើង

---

[១០៥] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ១៤-១៧ យោងទៅលើដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ៩ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ១២២(ខ) និង(គ)។

[១០៦] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ១៧ យោងទៅលើ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ៦៩-៧០។

[១០៧] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ១៥។



PRE-TRIAL CHAMBER • E.C.C.C • C.E.T.C • CHAMBRE PRÉLIMINAIRE

មានលក្ខណៈជាប្រព័ន្ធប្រឆាំងនឹងក្រុមដែលជាគោលដៅនានា រួមទាំងជនជាតិភាគតិចវៀតណាម និងអ្នកកាន់សាសនាវៀតណាមផងដែរ[១០៨]។ ដីកានេះក៏បានចែងនូវ "សកម្មភាពឧក្រិដ្ឋ" មួយចំនួន ដែលបានបង្ហាញពីវិសាលភាពនៃការរើសអើង ដែលមានលក្ខណៈជាប្រព័ន្ធ ដែលលើកឡើងត្រង់ផ្នែកដែលពាក់ព័ន្ធថា:

> "បក្សកុម្មុយនីស្តកម្ពុជាបានបន្តធ្វើនយោបាយរើសអើងប្រឆាំង និងសម្លាប់ជនជាតិភាគតិចវៀតណាម។ ពីដំបូង បក្សកុម្មុយនីស្តកម្ពុជាបានអនុម័តនូវនយោបាយមួយក្នុងការបោសសំអាតជនទាំងនោះដែលត្រូវបានគេចាត់ទុកថាជាជនជាតិវៀតណាម ឬអ្នកដែលមានទំនាក់ទំនងជាមួយប្រទេសវៀតណាម។ យ៉ាងណាមិញ ទំនាក់ទំនងរបស់បក្សកុម្មុយនីស្តកម្ពុជាជាមួយប្រទេសវៀតណាមបានចុះដុនដាបជាលំដាប់ ហើយមានទស្សនៈដែលចេះតែកើនឡើងថា ប្រទេសវៀតណាមគឺជាខ្មាំង។ ទស្សនៈទាំងនេះវាស៊ីគ្នាទៅនឹងជំនឿដែលថាគិញវៀតណាមកំពុងព្យាយាមរំលំបក្សកុម្មុយនីស្តកម្ពុជា។ មកដល់ពាក់កណ្តាល និងចុងឆ្នាំ១៩៧៧ គោលនយោបាយបានវិវត្តទៅជាគោលនយោបាយមួយ ដែលលុបបំបាត់ប្រជាជនទាំងអស់ដែលមានទំនាក់ទំនងជាមួយប្រទេសវៀតណាម"[១០៩]។

ចំណុចនេះពិតជាគាំទ្រដល់ទឡ្ហីករណ៍ដែលថា ភស្តុតាងដែលបានមកពីភាគីបណ្តឹងឧទ្ធរណ៍អាចរួមចំណែកយ៉ាងល្អក្នុងការបង្កើតបាននូវអត្ថិភាពនៃគម្រោងការបទឧក្រិដ្ឋ កំណត់គោលដៅ និងលុបបំបាត់ប្រជាជនដែលខ្មែរក្រហមចាត់ទុកថាជាជនជាតិ វៀតណាម ឬជាប់ពាក់ព័ន្ធ ឬទាក់ទងជាមួយនឹងប្រទេសវៀតណាម។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលវាបង្កើតបាននូវវិសាលភាពនៃកិច្ចស៊ើបសួរពាក់ព័ន្ធនឹង ឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទប្រកាន់ដែលសំដៅជាពិសេសលើប្រជាជនវៀតណាម និងមានគោលបំណងលុបបំបាត់ប្រជាជនវៀតណាមនោះ កថាខណ្ឌទី១២២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ សម្រេចយ៉ាងច្បាស់លាស់បើកកិច្ចស៊ើបសួរលើ អង្គហេតុនានាដែលបានគូសបញ្ជាក់នៅក្នុងកថាខណ្ឌទី៣៧ ដល់ទី៧២ ពាក់ព័ន្ធទៅនឹង ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជនជាតិវៀតណាម (អនុកថាខណ្ឌ

[១០៨] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ១២។

[១០៩] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ១២(ច)។



PRE-TRIAL CHAMBER E.C.C.C. C.E.T.C. CHAMBRE PRELIMINAIRE

(ខ)) និងការធ្វើ ទុកបុកម្នេញ (ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ) លើមូលដ្ឋាននយោបាយ ពណ៌សម្បុរ និងសាសនារបស់ជនជាតិវៀតណាម (អនុកថាខណ្ឌ (គ)): ទាំងអស់នេះ គឺជាអង្គហេតុទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងការជម្លៀសមនុស្សចេញពីទីក្រុងភ្នំពេញដោយបង្ខំ៖ ដំណាក់កាលទីមួយ[១១០]។ ការជម្លៀសមនុស្សដោយបង្ខំទៅកាន់ភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ៖ ដំណាក់កាលទីពីរ[១១១]។ ការជម្លៀសប្រជាជនដោយបង្ខំចេញពីភូមិភាគបូព៌ា៖ ដំណាក់កាលទីបី[១១២]។ ការធ្វើការងារដោយបង្ខំ លក្ខខណ្ឌរស់នៅប្រកបដោយភាពអមនុស្សធម៌ និងការឃុំខ្លួនដោយខុសច្បាប់នៅតាមតំបន់ និងទីតាំងផ្សេងៗ[១១៣]។ ព្រមទាំងការសម្លាប់ ការធ្វើទារុណកម្ម និងការរំលោភបំពានផ្នែកស្មារតីនៅមន្ទីរស-២១[១១៤] និងនៅតាមភូមិភាគ និងតាមតំបន់ផ្សេងៗ[១១៥]។ នៅក្នុងផ្នែកចុងក្រោយនេះ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបានសំដៅជាពិសេសលើឧក្រិដ្ឋកម្ម ទាំងឡាយដែលបានកំណត់គោលដៅចំពោះប្រជាជនវៀតណាមទាំងមូល ដែលរស់នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង និងសំដៅលើគោលនយោបាយនៃការលុបបំបាត់ រូបកាយតាមរយៈការប្រហារជីវិត ការដកចេញ និងការប្រហារជីវិតឪពុកជនជាតិ វៀតណាមដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយម្តាយជាខ្មែរ ក៏ដូចជាការដកចេញ និង ការប្រហារជីវិតទាំងម្តាយ ទាំងកូន ប្រសិនបើម្តាយជាជនជាតិវៀតណាម[១១៦]។ បន្ថែមពីលើនេះទៀត ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរសំដៅលើការសម្លាប់ជនជាតិវៀតណាមនៅក្នុងអំឡុងពេលវាយលុកចូលប្រទេសវៀតណាម ក៏ដូចជា ការបំផ្លាញទ្រព្យ

---

[១១០] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ៣៧-៣៩។

[១១១] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ៤០-៤១។

[១១២] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ៤២។

[១១៣] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ៤៣-៤៨។

[១១៤] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ៤៩-៥៥។

[១១៥] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ៥៦-៧២។

[១១៦] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ៦៩។

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER • E.C.C.C • C.E.T.C • CHAMBRE PRÉLIMINAIRE

សម្បត្តិរបស់ប្រជាជនស៊ីវិលដោយឥតត្រាប្រណីនៅក្នុងទឹកដីប្រទេសវៀតណាម[១១៧]។ ចំពោះចំណុចនេះ ដីកាទីពីរ[១១៨]មានភាពត្រឹមត្រូវហើយនៅក្នុង ការកំណត់លក្ខខណ្ឌឲ្យភាគីបណ្ដឹងឧទ្ធរណ៍បង្ហាញនូវចំណងទាក់ទងផ្ទាល់ រវាងព្យសនកម្មរបស់ពួកគាត់រៀងៗខ្លួន ជាមួយនិងអង្គហេតុមួយក្នុងចំណោមអង្គហេតុទាំងឡាយ ដែលគួរសបញ្ជាក់អំពីឧក្រិដ្ឋកម្មនានាដែលបានកំណត់គោលដៅយ៉ាងពិសេសលើប្រជាជនវៀតណាម (កថាខណ្ឌទី៦៩ ដល់ទី៧០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ) ឬក៏យ៉ាងហោចណាស់អង្គហេតុមួយក្នុងចំណោមអង្គហេតុទាំងឡាយដែលគួរសបញ្ជាក់អំពីឧក្រិដ្ឋកម្មផ្សេងៗទៀតដែលស្ថិតក្រោមកិច្ចស៊ើបសួរ (កថាខណ្ឌទី៣៧ ដល់៦៨ និង/ឬ ទី៧១ ដល់៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ)។ ដូច្នេះ ទឡ្ហីករណ៍ចុងក្រោយ របស់ភាគីបណ្ដឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរសម្រាប់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការធ្វើទុក្ខបុកម្នេញ ត្រូវបានបដិសេធចោល។ ពេលនេះ អង្គបុរេជំនុំជម្រះងាកទៅពិនិត្យមើលមូលដ្ឋានបន្ទាប់នៃបណ្ដឹងឧទ្ធរណ៍របស់ភាគីបណ្ដឹងឧទ្ធរណ៍ ដែលយោងលើមូលដ្ឋាននេះ រាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជាជនជាតិវៀតណាមទាំងអស់ មិនស្ថិតនៅក្រោមវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរឡើយ។

## ៤. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជាជនជាតិវៀតណាមនានា មិនស្ថិតនៅក្រោមវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះទេ

៤២. ភាគីបណ្ដឹងឧទ្ធរណ៍គ្រាន់តែយោងលើកថាខណ្ឌទី៤១ ដល់៧៦ នៃសំណើសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីប៉ុណ្ណោះ និងលើកឡើងថា៖ (i) សកម្មភាពដែលចាត់ទុកថាជាអំពើប្រល័យពូជសាសន៍បានរួមបញ្ចូលនូវការនិរទេសអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលជាជនជាតិភាគតិចវៀតណាមទាំង ១៦ រូប ដោយបង្ខំចេញពីប្រទេសកម្ពុជាទៅកាន់ប្រទេសវៀតណាម ការធ្វើដោយ

[១១៧] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ៧០។

[១១៨] ដីកាទីពីរដែលត្រូវបានជំទាស់ កថាខណ្ឌ១១។



E.C.C.C. • C.E.T.C. • PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

ចេតនាឱ្យជនជាតិវៀតណាមទទួលរងនូវស្ថានភាពរស់នៅមួយដែលរៀបចំឡើង សម្រាប់បំផ្លិចបំផ្លាញជនជាតិវៀតណាម ព្រមទាំងវិធានការ ដែលបានធ្វើឡើងដើម្បីរារាំងកុំឱ្យមានការចាប់កំណើតនៅក្នុងក្រុម។ ចំណែកឯ (ii) សកម្មភាពដែលចាត់ទុកថាជាឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ រួមមានការផ្លាស់ប្តូរទីកន្លែងដោយបង្ខំទាំងក្នុង និងក្រៅប្រទេសកម្ពុជា ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ និងការធ្វើទុក្ខបុកម្នេញ។ ភាគីបណ្តឹងឧទ្ធរណ៍បានអះអាងដោយផ្អែកលើការកំណត់និយមន័យរបស់ ICTR អំពីក្រុមជាតិពន្ធុថាជា "ក្រុមដែលសមាជិករបស់ខ្លួនមានភាសា ឬវប្បធម៌រួមមួយ"[១១៥] ដែលថាជាតិពន្ធុមិនត្រូវបានកំណត់និយមន័យទៅតាមទីតាំងភូមិសាស្ត្រនោះទេ ហើយថាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ប្រឆាំងនឹងជនជាតិភាគតិចវៀតណាមមិនអាចត្រូវបានកំណត់ចំពោះតែទៅលើតំបន់ភូមិសាស្ត្រជាក់លាក់ណាមួយនោះឡើយ។ ដោយគ្មានយុត្តិកម្មផ្សេងទៀតនោះ ពួកគាត់អះអាងស្រដៀងគ្នាថា ការដាក់ការកំណត់ភូមិសាស្ត្រទៅលើតំបន់នានាដែលឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានប្រព្រឹត្តនោះជាការមិនអើពើទាល់តែសោះទៅលើលក្ខខណ្ឌកំណត់ដើម្បីបង្ហាញថា សកម្មភាពទាំងឡាយដែលចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនេះ ត្រូវបានប្រព្រឹត្តឡើងមានលក្ខណៈជាប្រព័ន្ធ និងនៅក្នុងលក្ខណៈទូទៅ ។

៤៣. អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះមិនមានភាពគ្រប់គ្រាន់ទេ ដោយក្នុងនោះវាគ្រាន់តែរាប់ទុកថា ជាការអះអាងដែលគ្មានការបញ្ជាក់ច្បាស់លាស់នូវ វិការៈជាក់លាក់ណាមួយឡើយ ឬដោយគ្មានការនិយាយអំពីសំអាងហេតុជាក់លាក់នៃដីកាទីពីរ ឬនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឡើយ។ ដូចនេះ មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះគ្មានសក្តានុពលធ្វើឱ្យមានការបដិសេធ ឬពិនិត្យឡើងវិញចំពោះសេចក្តីសម្រេចដែលត្រូវបានជំទាស់នេះទេ ហើយមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ នឹងត្រូវបានបដិសេធចោល ដោយមិនត្រូវបាន

---

[១១៥] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ៣៧ និងជើងទំព័រ៦៦ យោងទៅលើរឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Akayesu សាលក្រម* សំណុំរឿងលេខ ICTR-96-4-T "សាលក្រម" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ ទំព័រទី ៥១២-១៥។



* អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

យកមកពិចារណាដល់អង្គសេចក្តីឡើយ[១២០]។ ពេលនេះ អង្គបុរេជំនុំជម្រះងាកទៅពិនិត្យមើលមូលដ្ឋានបន្ទាប់ចុងក្រោយនៃបណ្តឹងឧទ្ធរណ៍របស់ភាគីបណ្តឹងឧទ្ធរណ៍ ដែលលើកឡើងថាកិច្ចស៊ើបសួរទាំងឡាយដែលធ្វើឡើងដោយ ស.ច.ស នៅខេត្តកំពង់ឆ្នាំង បានធ្វើឲ្យជនរងគ្រោះជាជនជាតិភាគតិចវៀតណាមស្ថិតនៅក្រោមវិសាលភាពនៃអង្គហេតុនានាដែលស្ថិតក្រោមកិច្ចស៊ើបសួរ។

## ៥. ថាតើកិច្ចស៊ើបសួរដែលត្រូវបានបំពេញនៅខេត្តកំពង់ឆ្នាំង បានដាក់ជនរងគ្រោះជាជនជាតិវៀតណាមនៅក្នុងវិសាលភាពនៃអង្គហេតុដែលកំពុងស៊ើបអង្កេតដែរឬយ៉ាងណា

៤៤. យោងតាមមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ ភាគីបណ្តឹងឧទ្ធរណ៍អះអាងជាដំបូងថា បន្ទាប់ពី ស.ច.ស បានផ្សាយចេញនូវព័ត៌មានពីវិសាលភាពនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០២ កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៩ អ្នកស៊ើបអង្កេតបានស្តាប់យកចម្លើយដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់មកពីខេត្តកំពង់ឆ្នាំង អំពីការបំបែកជនជាតិវៀតណាមចេញពីជនជាតិខ្មែរ ដែលធ្វើឡើងដោយខ្មែរក្រហម អំពីប្រព្រឹត្តិកម្មមកលើជនជាតិវៀតណាម ព្រមទាំងហេតុការណ៍ដែលនាំទៅដល់ការជម្លៀសពួកគេដោយបង្ខំទៅកាន់ប្រទេសវៀតណាម អំពីលក្ខណៈនៃការជម្លៀសដោយបង្ខំនៅទីនោះ អំពីករណីថាតើមានជនរងគ្រោះជនជាតិវៀតណាមនៅសេសសល់នៅកម្ពុជាដែរឬទេ អំពីរបៀបកំណត់អត្តសញ្ញាណជនជាតិវៀតណាម និងអំពីការបំបែកជនជាតិខ្មែរពីជនជាតិវៀតណាមក្នុងពេលមានការជម្លៀស ក្នុងនោះរួមមានការបំបែកគ្រួសារនៅក្នុងសម្ព័ន្ធអាពាហ៍ពិពាហ៍ចម្រុះ[១២១]។ យោងតាមភាគីបណ្តឹងឧទ្ធរណ៍ ការស្តាប់ចម្លើយនេះគឺជាកិច្ចស៊ើបសួរនៅខេត្តកំពង់ឆ្នាំងអំពីទីកន្លែងកកើតឧក្រិដ្ឋកម្ម ដែលរាប់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងក្រុមជនជាតិវៀតណាម ហើយចម្លើយនេះគាំទ្រពីករណីដែលថា ស.ច.ស បានផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីទៅឲ្យអ្នកដែល

---

[១២០] សូមមើល កថាខណ្ឌ ២២ ខាងលើ។

[១២១] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ ៤១។



E.C.C.C * C.E.T.C.
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ត្រូវបានស្តាប់យកចម្លើយម្នាក់ ក្នុងថ្ងៃស្តាប់យកចម្លើយ ពោលគឺមួយថ្ងៃមុនការចោទប្រកាន់អំពីបទប្រល័យពូជសាសន៍ដែលត្រូវបាន ស.ច.ស ដាក់បញ្ចូលនៅក្នុងសំណុំរឿង ០០២[១២២]។

៤៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថាភាគីបណ្តឹងឧទ្ធរណ៍ ខកខានពុំបានចង្អុលបង្ហាញថា កិច្ចស៊ើបសួរដែលបានរៀបរាប់ពីខាងលើ ហួសពីវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឡើយ ហើយក្នុងករណីដែលកិច្ចស៊ើបសួរនេះមានកម្រិតហួសពីវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ អវត្តមាននៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា នឹងផ្ទុយពីលក្ខខណ្ឌ ដែលវិធាន ៥៥(៣)បានដាក់កម្រិតទៅលើ ស.ច.ស ហើយវានឹងពុំមានផលប៉ះពាល់ទៅលើលទ្ធភាពអាចទទួលយកបាននៃពាក្យសុំតាំង ខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលពាក្យសុំទាំងនេះត្រូវបានកម្រិតដោយវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដូចគ្នា។

៤៦. ជាចុងក្រោយ ភាគីបណ្តឹងឧទ្ធរណ៍លើកទឡ្ហីករណ៍ថាការបដិសេធ *ជារួម* នូវអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជនជាតិភាគតិចវៀតណាមចំនួន១៦រូប មានផលប៉ះពាល់ដល់ជនរងគ្រោះទាំងនេះ ហើយវាផ្ទុយពីគោលការណ៍ទី ៤ នៃសេចក្តីប្រកាសអំពីជនរងគ្រោះ (Victims Declaration) ឆ្នាំ១៩៨៥ ដែលចែងថាជនរងគ្រោះគួរត្រូវទទួលបានមេត្តាធម៌ និងការគោរពសេចក្តីថ្លៃថ្នូររបស់ពួកគាត់[១២៣]។ អង្គបុរេជំនុំជម្រះយល់ឃើញថា គេពុំអាចនិយាយថាដីកាទី២ បង្ហាញអំពីការខ្វះមេត្តាធម៌ ឬការមិនគោរពចំពោះជនរងគ្រោះឡើយ ប្រសិនបើដីកានេះផ្តល់ហេតុផលទៅលើការសម្រេចរបស់ខ្លួន ក្នុងការបដិសេធមិនទទួលយកដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ និងប្រសិនបើដីកានេះនិយាយយោងទៅដល់វិសាលភាពនៃកិច្ចស៊ើបសួរ និងពាក្យសុំទាំងនោះ។ ដូច្នេះ យើងសូមជំទាស់ទៅនឹងទឡ្ហីករណ៍ចុងក្រោយនេះ ហើយអង្គបុរេជំនុំជម្រះសូមងាកទៅពិនិត្យមើលមូលដ្ឋានបន្ទាប់នៃបណ្តឹងឧទ្ធរណ៍របស់ភាគីបណ្តឹងឧទ្ធរណ៍ ដែលចោទប្រកាន់ថា ដីកាទី២ បានចេញមុនពេលកំណត់។

---

[១២២] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ ៤២។

[១២៣] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ ៤៣។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00504351



## គ. តើដីកាទី២នេះបានចេញមុនពេលកំណត់ដែរឬទេ?

៤៧. តាមមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ភាគីបណ្តឹងឧទ្ធរណ៍បានលើកឡើងនូវទឡ្ហីករណ៍មួយចំនួនដែលអង្គបុរេជំនុំជម្រះពុំចាំបាច់ពិចារណាលម្អិត ដោយហេតុថាទឡ្ហីករណ៍ទាំងនោះ មានភាពពុំច្បាស់លាស់ មិនពេញលេញ និងពុំកំណត់ឱ្យបានច្បាស់លាស់នូវកំហុសឆ្គងណាមួយជាក់លាក់[១២៤]។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះនឹងពិចារណាតែទៅលើ ទឡ្ហីករណ៍របស់ភាគីបណ្តឹងឧទ្ធរណ៍ដែលថា៖ (i) ស.ច.ស បានសម្រេចដោយឆាប់រហ័សពេកលើលទ្ធភាពអាចទទួលយកបាននូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគាត់ ជំនួសឱ្យការអនុញ្ញាតឱ្យពួកគាត់ចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី ដែលរង់ចាំការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលរហូតដល់ពេលនោះ វិសាលភាពនៃកិច្ចស៊ើបសួរនៅតែពុំទាន់ត្រូវបានកំណត់នៅឡើយ និង[១២៥] (ii) ប្រសិនបើ ស.ច.ស យល់ថាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ភាគីបណ្តឹងឧទ្ធរណ៍ បានលើកឡើងនូវ "អង្គហេតុថ្មី" ស.ច.ស គួរតែបញ្ជូនអង្គហេតុទាំងនោះ ទៅកាន់សហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន ៥៥(៣) នៃវិធានផ្ទៃក្នុង ឱ្យបានឆាប់បំផុតដើម្បីឱ្យសហព្រះរាជអាជ្ញាប្រញាប់ចាត់វិធានការជាបន្ទាន់[១២៦]។

៤៨. ជាបឋម អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថាវិធាន ២៣*ស្ទួន* (២) នៃវិធានផ្ទៃក្នុង ចែងជាពិសេសថា ស.ច.ស "អាចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងពេលណាមួយរហូតដល់ថ្ងៃចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ[១២៧]"។ គេពុំអាចនិយាយថាដីកាទី២បានធ្វើឡើងមុនពេលកំណត់ឡើយ ដោយហេតុថាផ្អែកទៅតាមការវាយតម្លៃរបស់ ស.ច.ស ភាគីបណ្តឹងឧទ្ធរណ៍ពុំបានបញ្ជាក់ថាព្យសនកម្មរបស់ពួកគាត់ដែលត្រូវបានចោទប្រកាន់ គឺជាផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ឡើយ និងដោយគិតដល់ការពុំដាក់សេចក្តី

---

[១២៤] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ ៤៣។

[១២៥] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ ២៣។

[១២៦] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ ២២។

[១២៧] វិធាន ២៣ ស្ទួន (៣) ក៏ចែងផងដែរថា នៅពេលចេញដីកាដំណោះស្រាយ ស.ច.ស ត្រូវសម្រេចលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈដីកាសម្រេចមួយ[ចុងក្រោយ]។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

សន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាទាក់ទិននឹងអង្គហេតុថ្មី ដែលពាក្យសុំបានលើកឡើង។ ជាគោលការណ៍ ទោះបីសហព្រះរាជអាជ្ញាអាចដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរហូតដល់ពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងអាចពង្រីកវិសាលភាពនៃកិច្ចស៊ើបសួរ ដូចដែលត្រូវបានកំណត់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពីដំបូង ប្រសិនបើមានក៏ដោយ ក៏គេពុំអាចនិយាយថាវិសាលភាពនៃកិច្ចស៊ើបសួរ "ពុំត្រូវបានកំណត់" រហូតដល់ពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ។ វិសាលភាពនៃកិច្ចស៊ើបសួរត្រូវបានកំណត់រហូតដល់ពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅពេលមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា។ នៅពេលងាកមកពិនិត្យមើលទឡ្ហីករណ៍ទី២ ដែលបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសូមរម្លឹកអំពីការយល់ឃើញដំបូងរបស់ខ្លួនថា វិធាន ៥៥(៣) ដែលបានដាក់កំហិតទៅលើ ស.ច.ស ឲ្យស៊ើបសួរបានត្រឹមតែអំពីអង្គហេតុថ្មីៗ ដែលកំណត់ត្រឹមតែជាស្ថានទម្ងន់ទោសដូចមានចែងស្រាប់នៅក្នុងដីកាសន្និដ្ឋាន ឬ អង្គហេតុដែលសហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម គឺអាចយកមកអនុវត្តបានដូចគ្នាចំពោះដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកសុំតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណីអាចប្រាប់ឲ្យ ស.ច.ស ឬ សហព្រះរាជអាជ្ញាបានដឹងអំពីអង្គហេតុថ្មីៗ ប៉ុន្តែពុំមានតួនាទីណាមួយដើម្បីសុំបំពេញកិច្ចស៊ើបសួរអំពីអង្គហេតុទាំងនេះឡើយ លើកលែងតែអង្គហេតុទាំងនេះត្រូវបានសហព្រះរាជអាជ្ញាដាក់បញ្ចូលទៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ នៅក្នុងករណីនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វាពុំហាក់បីដូចជាថា "អង្គហេតុថ្មីៗ"[១២៨] ដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ៣ ដល់ ៦ នៃសំណើសុំទី១ របស់សហព្រះរាជអាជ្ញាត្រូវបាន ស.ច.ស បញ្ជូនទៅឲ្យសហព្រះរាជអាជ្ញាឡើយ។ បើទោះបីជាយ៉ាងដូច្នេះក្តី ពាក្យពេចន៍នៅក្នុងសំណើសុំលើកទី១ បង្ហាញថាសហព្រះរាជអាជ្ញាបានដឹងអំពីអង្គហេតុថ្មីៗនោះ

[១២៨] សំណើសុំទីមួយរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១។



E.C.C.C. ● C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00504353



ហើយបើកលទ្ធភាពឲ្យខ្លួនដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ទាក់ទិននឹងអង្គហេតុទាំងនោះ។ ដូច្នេះ មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះត្រូវបានបដិសេធចោល ហើយអង្គបុរេជំនុំជម្រះសូមងាកពិនិត្យមើលមូលដ្ឋានបន្ទាប់នៃបណ្តឹងឧទ្ធរណ៍នេះ ដែលបានចោទប្រកាន់ថា ដីកាទី២ គឺផ្ទុយទៅនឹងគោលការណ៍ស្នូលទាក់ទិននឹងការចូលរួមរបស់ជនរងគ្រោះ ដែលបង្កើតឡើងដោយ អ.វ.ត.ក ហើយដីកានេះបានរំលោភសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី ដែលបានទទួលស្គាល់រួចហើយ ដោយគ្មានមូលហេតុ។

**ឃ. តើដីកាទី២បានរំលោភគោលការណ៍ស្នូលរបស់ អ.វ.ត.ក ឬ តើដីកានេះគ្មានមូលហេតុដែរឬទេ?**

**១. <u>ការចោទប្រកាន់លើការរំលោភគោលការណ៍ស្នូលរបស់ អ.វ.ត.ក ទាក់ទិននឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី</u>**

៤៩. ភាគីបណ្តឹងឧទ្ធរណ៍លើកទឡ្ហីករណ៍តាមមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះថា ដីកាទី២ ផ្ទុយនឹងគោលបំណងចម្បងរបស់ អ.វ.ត.ក ពោលគឺការស្វែងរក"យុត្តិធម៌ និងការផ្សះផ្សាជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខ ហើយវាផ្ទុយនឹងដំណើរការនីតិវិធីរដ្ឋប្បវេណី។ ដំណើរការនេះត្រូវបានបង្កើតឡើងដើម្បីឲ្យជនរងគ្រោះ អាចចូលរួមដោយសកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ[១២៩]"។ បណ្តឹងឧទ្ធរណ៍ក៏បានលើកទឡ្ហីករណ៍ថា ស.ច.ស បានរំលោភសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានទទួលស្គាល់រួចហើយ តាមរយៈការប្រកាសមិនទទួលស្គាល់ពួកគេ ដោយគ្មានមូលហេតុ[១៣០]។

៥០. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ច្បាប់ អ.វ.ត.ក មានគោលបំណងនាំយកមកជំនុំជម្រះនូវមេដឹកនាំជាន់ខ្ពស់របបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងការរំលោភធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់ និងទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិ និងអនុសញ្ញាអន្តរជាតិដែលកម្ពុជាបានទទួលស្គាល់ ដែលត្រូវបានប្រព្រឹត្តក្នុង

---

[១២៩] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ ២៨-២៩។

[១៣០] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ ៣២-៣៣។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

អំឡុងរយៈកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[១៣១]។ ច្បាប់នេះ ក៏ទទួលស្គាល់ដោយប្រយោលផងដែរនូវការចូលរួមរបស់ជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធី ដោយហេតុថាច្បាប់នេះទទួលស្គាល់នូវលទ្ធភាពរបស់ជនរងគ្រោះក្នុងការប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក[១៣២]។

៥១. ប្រព័ន្ធនីតិវិធីដែលអនុវត្តនៅ អ.វ.ត.ក ដែលកើតចេញមកពីច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង បានចែងថាសហព្រះរាជអាជ្ញាត្រូវទទួលខុសត្រូវតែម្យ៉ាងគត់លើការដាក់បណ្តឹងអាជ្ញាចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក តាមឆន្ទានុសិទ្ធិរបស់ខ្លួន ឬតាមមូលដ្ឋាននៃពាក្យបណ្តឹង[១៣៣] ដោយត្រូវបំពេញកិច្ចស៊ើបសួរបឋម និង[១៣៤] បើកកិច្ចស៊ើបសួរតាមរយៈការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅឲ្យ ស.ច.ស ប្រសិនបើខ្លួនមានហេតុផលនាំឲ្យជឿជាក់ថា ឧក្រិដ្ឋកម្មក្រោមយុត្តាធិការរបស់ អ.វ.ត.ក ពិតជាត្រូវបានប្រព្រឹត្ត[១៣៥]។ ដូចដែលបានបញ្ជាក់បង្ហាញរួចហើយនៅក្នុងសាលដីកានេះ ស.ច.ស ដែលជាអ្នកមានភារៈទទួលខុសត្រូវក្នុងការបំពេញកិច្ចស៊ើបសួរ ពុំត្រឹមតែកម្រិតឱ្យស៊ើបអង្កេតលើឧក្រិដ្ឋកម្មក្រោមយុត្តាធិការរបស់ អ.វ.ត.ក ប៉ុណ្ណោះទេ ប៉ុន្តែត្រូវស៊ើបសួរអំពីអង្គហេតុដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និង/ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ទៀតផង[១៣៦]។ លក្ខខណ្ឌកំហិតដូចគ្នានេះ ត្រូវយកមកអនុវត្តចំពោះអ្នកដាក់ពាក្យ

---

[១៣១] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ អ.វ.ត.ក" និង "កម្ពុជាប្រជាធិបតេយ្យ") កថាខណ្ឌ ១ និង២។

[១៣២] ច្បាប់ អ.វ.ត.ក កថាខណ្ឌ ៣៦(ថ្មី)។

[១៣៣] វិធាន៤៩(១) នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ ច្បាប់ អ.វ.ត.ក កថាខណ្ឌ ១៦ ទទួលស្គាល់ការទទួលខុសត្រូវរបស់សហព្រះរាជអាជ្ញាទាំងពីរសម្រាប់ធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់។

[១៣៤] វិធាន៥០ នៃវិធានផ្ទៃក្នុង។

[១៣៥] វិធាន៥៣(១) នៃវិធានផ្ទៃក្នុង។

[១៣៦] វិធាន៥៥(១) នៃវិធានផ្ទៃក្នុង។

ស្នើសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានបំណងចង់ចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ដើម្បីគាំទ្រការចោទប្រកាន់ និងស្វែងរកសំណងរួមជាសមូហភាព[១៣៧]។ ក្នុងអំឡុងកិច្ចស៊ើបសួរ និងក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ អ្នកទាំងនេះអាចស្នើសុំឱ្យចេញដីកាសន្និដ្ឋានទាំងនេះ និងស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរទាំងឡាយណា ដែលខ្លួនចាត់ទុកថាមានប្រយោជន៍ដល់ការស៊ើបអង្កេត[១៣៨]។ ការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ គឺវាអាស្រ័យទៅលើលទ្ធភាពរបស់អ្នកពាក្យសុំនោះនៅក្នុងការបង្ហាញថា ព្យសនកម្មរបស់ខ្លួនគឺជាផលវិបាកផ្ទាល់ពីឧក្រិដ្ឋកម្មមួយឬច្រើន ដែលសហព្រះរាជអាជ្ញាបានចោទប្រកាន់ទៅលើជនត្រូវចោទ[១៣៩]។ ប្រសិនបើមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយដីកានោះចូលជាស្ថាពរ ហើយប្រសិនបើមានការសម្រេចរួចរាល់លើការតវ៉ាចំពោះសេចក្ដីសម្រេចរបស់ ស.ច.ស លើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នោះដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានគេទទួលស្គាល់រួចហើយនឹងបង្កើតបានជាបណ្ដុំដើមបណ្ដឹងរដ្ឋប្បវេណីដែលបានរួមគ្នាជាក្រុមតែមួយនៅដំណាក់ជំនុំជម្រះ និងនៅដំណាក់កាលបន្ទាប់[១៤០]។ នៅក្នុងការអនុវត្តសិទ្ធិដែលបានរៀបរាប់ពីខាងលើរបស់ "ជនរងគ្រោះ" ក្នុងការប្ដឹងឧទ្ធរណ៍ ដែលគេបានចែងទុកនៅក្នុងច្បាប់ អ.វ.ត.ក វិធានផ្ទៃក្នុងបានផ្ដល់ឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងដើមបណ្ដឹងរដ្ឋប្បវេណីនូវសិទ្ធិប្ដឹងឧទ្ធរណ៍ចំពោះសេចក្ដីសម្រេចមួយចំនួនតូចរបស់ ស.ច.ស[១៤១] និងសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការប្ដឹងសាទុក្ខចំពោះសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងផលប្រយោជន៍រដ្ឋប្បវេណី ក្នុងករណីមានបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា[១៤២]។

---

[១៣៧] សូមមើល កថាខណ្ឌ១៦ ខាងលើ។

[១៣៨] វិធាន៥៥(១០) នៃវិធានផ្ទៃក្នុង។

[១៣៩] វិធាន២៣(១) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៤) និងវិធាន២៣ ស្ទួន ១ នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៥)។

[១៤០] វិធាន២៣(៥) នៃវិធានផ្ទៃក្នុង។

[១៤១] វិធាន៧៤(៤) នៃវិធានផ្ទៃក្នុង។

[១៤២] វិធាន១០៥(១) នៃវិធានផ្ទៃក្នុង។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00504356



៤២. ការចូលរួមរបស់ជនរងគ្រោះនៅចំពោះមុខ អ.វ.ត.ក មិនមែនគ្មានការកម្រិតនោះទេ។ ការចូលរួមនេះផ្ដល់លទ្ធភាពឱ្យជនរងគ្រោះដែលបានចោទប្រកាន់ថាបានទទួលរងព្យសនកម្មដែលជាផលវិបាកផ្ទាល់ពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងជនត្រូវចោទ អាចក្លាយខ្លួនជាភាគីមួយប្រកបដោយប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី អ.វ.ត.ក ក្នុងដំណាក់កាលស៊ើបសួរ និងដំណាក់កាលបន្តបន្ទាប់។ ការចូលរួមនេះមានភាពតិចជាងការចូលរួម តាមច្បាប់កម្ពុជា ដោយហេតុថាជនរងគ្រោះដែលមានបំណងចង់ចូលរួមជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះ អ.វ.ត.ក អាចធ្វើដូច្នេះបានតែតាមរយៈមធ្យោបាយនៃការអន្តរាគមន៍ នៅក្នុងកិច្ចដំណើរការនីតិវិធីបណ្ដឹងអាជ្ញា[១៤៣] និងក្នុងវិសាលភាពដែលបានកំណត់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាប៉ុណ្ណោះ។ ការចូលរួមនេះមានលើសពីការចូលរួមតាមប្រព័ន្ធដែលមាន ជាក់ស្ដែងដូចជានៅតុលាការអន្តរជាតិមិនអចិន្ត្រៃយ៍ ដែលនៅទីនោះ ការចូលរួមរបស់ជនរងគ្រោះត្រូវបានកំណត់ត្រឹមតែជាការផ្ដល់សក្ខីកម្មប៉ុណ្ណោះ។ ចំពោះក្របខណ្ឌច្បាប់នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា តាមមូលដ្ឋាននេះនៃបណ្ដឹងឧទ្ធរណ៍ ភាគីបណ្ដឹងឧទ្ធរណ៍ពុំបានបង្ហាញថាដីកាទី២គឺមិនស្របនឹងគោលការណ៍ដែលបង្កើតឡើងដោយ អ.វ.ត.ក ឬប្រព័ន្ធខាងលើ ឬពុំបានបង្ហាញថាដីកាទី២ "គ្មានហេតុផល"នោះទេ។

៤៣. ទាក់ទិននឹងការលើកឡើងករណីបន្ថែមរបស់ភាគីបណ្ដឹងឧទ្ធរណ៍ដែលថា ប្រសិនបើត្រូវបានផាត់ចេញពីកិច្ចដំណើរការនីតិវិធីជាដើមបណ្ដឹងរដ្ឋប្បវេណី ពួកគេនឹងមិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការកំណត់អង្គហេតុ និងការកំណត់អត្តសញ្ញាណអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មក្រោមយុត្តាធិការរបស់ អ.វ.ត.ក ដែលឧក្រិដ្ឋកម្មទាំងនេះបានធ្វើឱ្យពួកគាត់ក្លាយជាជនរងគ្រោះ[១៤៤] អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដូចដែលភាគីបណ្ដឹងឧទ្ធរណ៍បានចង្អុលបង្ហាញយ៉ាងត្រឹមត្រូវរួចមកហើយថា ភស្ដុតាងរបស់ពួកគាត់អាចគាំទ្រអំពីការបង្កើតផែនការ

---

[១៤៣] ដីកាទីពីរដែលត្រូវបានជំទាស់ កថាខណ្ឌ ៨។

[១៤៤] បណ្ដឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ ២៨។



E.C.C.C * C.E.T.C
TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬអំពី *ចេតនាឧក្រិដ្ឋ* នៃឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងជនត្រូវចោទ។ ហើយភាគីបណ្ដឹងឧទ្ធរណ៍មួយចំនួន មិនអាចថានឹងមិនត្រូវបានកោះហៅឱ្យមកផ្ដល់សក្ខីកម្មប្រឆាំងនឹងជនត្រូវចោទនៅក្នុងការជំនុំជម្រះលើសំណុំរឿង០០២ឡើយ។ ទាក់ទិននឹងទឡ្ហីករណ៍ចុងក្រោយតាមមូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍នេះដែលថា ដីកាទី២បានបំបិទសូនឈឹងនូវប្រវត្តិសាស្ត្រ និងការចងចាំរឿងរ៉ាវនៅក្នុងសង្គមរបស់ប្រជាជនខ្មែរក្រោម ហើយមិនទទួលស្គាល់ទុក្ខវេទនារបស់ពួកគាត់ជាក្រុម កាលអំឡុងរយៈកាលសម័យកម្ពុជាប្រជាធិបតេយ្យ[១៤៥] ទឡ្ហីករណ៍នេះមិនមានមូលដ្ឋាន។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដីកាទី២ បានទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន១០ ដែលពាក់ព័ន្ធតាមរយៈសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយ អង្គបុរេជំនុំជម្រះបានសម្រេចទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៥ បន្ថែមទៀត។ អង្គបុរេជំនុំជម្រះសូមងាកមកពិនិត្យមើលផ្នែកទី២ នៃមូលដ្ឋាននេះនៃបណ្ដឹងឧទ្ធរណ៍ដែលបានចោទប្រកាន់ថា ដីកាទី២ មិនមានហេតុផល។

## ២. ការចោទប្រកាន់ថា ការប្រកាសមិនទទួលយកដើមបណ្ដឹងរដ្ឋប្បវេណីដែលបានទទួលស្គាល់រួចហើយធ្វើឡើងដោយគ្មានមូលហេតុ

៥៤. ភាគីបណ្ដឹងឧទ្ធរណ៍ចោទប្រកាន់ថា ស.ច.ស មានកំហុសឆ្គងផ្នែកច្បាប់ និងអង្គហេតុលើការរំលោភសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន៤រូប ដែលបានទទួលស្គាល់រួចហើយ នៅពេលខ្លួនប្រកាសមិនទទួលស្គាល់អ្នកទាំងនេះ ដោយគ្មានមូលហេតុហើយ អ្នកទាំងនេះ គួរត្រូវទទួលបានសិទ្ធិរបស់គាត់វិញ[១៤៦]។ ជាពិសេស ភាគីបណ្ដឹងឧទ្ធរណ៍លើកទឡ្ហីករណ៍ថា នៅពេលដែល ស.ច.ស បានទទួលស្គាល់ជាផ្លូវការនូវពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់

---

[១៤៥] បណ្ដឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ ៣០។

[១៤៦] បណ្ដឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ ៣២-៣៣។ សូមមើលផងដែរ កថាខណ្ឌ ៣៩-៤០ ចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជនជាតិវៀតណាម។



E.C.C.C * C.E.T.C PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ខ្មែរក្រោម [redacted] ជនរងគ្រោះទាំងនេះបានក្លាយខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីពេញសិទ្ធិ ហើយ ស.ច.ស ពុំមានសិទ្ធិអំណាចបដិសេធពាក្យសុំរបស់ពួកគាត់ឡើយ ដោយអនុលោមតាមវិធាន២៣(៣) នៃវិធានផ្ទៃក្នុង[១៤៧]។ ភាគីបណ្ដឹងឧទ្ធរណ៍ក៏បានលើកឡើងករណីថា យើងអាចបកស្រាយបានពីរបែបតែប៉ុណ្ណោះ ចំពោះករណីដ៏សំខាន់មួយពោលគឺ ដើមបណ្ដឹង រដ្ឋប្បវេណីដែលបានការទទួលស្គាល់ទាំងនេះ ត្រូវបានអ្នកស៊ើបអង្កេតស្ដាប់ចម្លើយ តាមអំណាចនៃដីកាចាត់ឱ្យស៊ើបសួរជំនួសពី ស.ច.ស[១៤៨]៖ (i) ស.ច.ស បានចាត់ទុកពួកគាត់ពីដំបូងជាជនរងគ្រោះនៃឧក្រិដ្ឋកម្មក្រោមយុត្តាធិការ អ.វ.ត.ក និងកិច្ចស៊ើបសួរ ប៉ុន្តែបន្ទាប់មក ស.ច.ស បានកែប្រែគោលការណ៍របស់ខ្លួនដោយពុំបានជូនដំណឹងជាសាធារណៈ, ឬ (ii) ស.ច.ស បានចាត់ទុកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងនេះថាស្ថិតនៅក្រោមវិសាលភាពនៃ "អង្គហេតុ" ដែលបានបង្កើតជាផ្នែកមួយនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ក្នុងករណីណាក៏ដោយ យោងតាមភាគីបណ្ដឹងឧទ្ធរណ៍ ស.ច.ស បានខកខានពុំបានបំពេញកាតព្វកិច្ចរបស់ខ្លួនតាមវិធាន ២១ នៃវិធានផ្ទៃក្នុង "ក្នុងការធានាឱ្យមានភាពច្បាស់លាស់ និងតម្លាភាព" និងដើម្បីឱ្យជនរងគ្រោះ "បានដឹងព័ត៌មាន និងដើម្បីធានាថាសិទ្ធិរបស់ពួក គាត់ត្រូវបានគោរពនៅគ្រប់កិច្ចដំណើរការនីតិវិធី[១៤៩]"។

[១៤៧] ដីកាទីពីរដែលត្រូវបានជំទាស់ ផ្នែក III កថាខណ្ឌ៣២។

[១៤៨] បណ្ដឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ៣៣ ដោយយោងទៅលើ ដីកាចាត់ឱ្យស៊ើបសួរជំនួសរបស់សហចៅក្រមស៊ើបអង្កេត ផ្ញើជូនទៅអ្នកស៊ើបអង្កេតរបស់ អ.វ.ត.ក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩, ១, ឯកសារ D246។

[១៤៩] បណ្ដឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ៣៣ ជើងទំព័រ៦៥ យោងសេចក្ដីសម្រេចលើភាពដែលអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើការប្រើភស្តុតាង ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើការប្រើភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D130/9/1 កថាខណ្ឌ២៤ ដែលគ្រាន់តែដកស្រង់ផ្នែករបស់វិធាន២១ នៃវិធានផ្ទៃក្នុងដែលជាប់ពាក់ព័ន្ធទៅនឹងសិទ្ធិរបស់ជនរងគ្រោះតែប៉ុណ្ណោះ។

៩៥. ភាគីបណ្តឹងឧទ្ធរណ៍ប្រើប្រាស់ទឡ្ហីករណ៍ដដែលនេះ និងស្នើសុំឱ្យផ្តល់ឡើងវិញនូវឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ទៅឱ្យជនរងគ្រោះជនជាតិវៀតណាមចំនួន៩រូប ដែលកន្លងមកត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី[redacted][150]។

៩៦. បន្ទាប់ពីការប្រជុំពិភាក្សាសម្រេចយ៉ាងល្អិតល្អន់ អង្គបុរេជំនុំជម្រះពុំទាន់បានទទួលសំឡេងលើសលប់ទៅលើអង្គសេចក្តីនៃមូលដ្ឋាននេះនៃបណ្តឹងឧទ្ធរណ៍នេះទេ។ ដូច្នេះ អនុលោមតាមវិធាន ៧៧(១៣)(ក) យើងបានសម្រេចជាឯកច្ឆន្ទតម្កល់ដីកាទី២ ដោយគ្មានការកែប្រែ ត្រង់មូលដ្ឋាននេះ។ ក្នុងគោលបំណងដើម្បីធានាតម្លាភាព អង្គបុរេជំនុំជម្រះយល់ឃើញថា វាជាការចាំបាច់ក្នុងការបង្ហាញមតិយោបល់របស់ចៅក្រម ហើយដាក់ភ្ជាប់មកជាមួយនឹងសាលដីកានេះ។

### ង. ការចោទប្រកាន់ថា ដីកាទី២ មិនបានពិចារណាទៅលើរាល់គ្រប់ព័ត៌មានទាំងអស់

៩៧. តាមមូលដ្ឋាននេះនៃបណ្តឹងឧទ្ធរណ៍ ភាគីបណ្តឹងឧទ្ធរណ៍ចោទប្រកាន់ថា ដីកាទី២ បានខកខានពុំបានពិចារណាទៅលើរាល់គ្រប់ព័ត៌មានទាំងអស់ដែលពាក់ព័ន្ធ និងបានបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនជាតិវៀតណាមជារួម[151]។ ភាគីបណ្តឹងឧទ្ធរណ៍គ្រាន់តែចង្អុលបង្ហាញកំណត់ហេតុបន្ថែម ដែលសហមេធាវីតំណាងអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានឆ្លើយថាបានដាក់ទៅឱ្យអង្គភាពជនរងគ្រោះ ទាក់ទិននឹងអ្នកដាក់ពាក្យសុំ[redacted] និងចង្អុលទៅលើកង្វះឯកសារភ្ជាប់ និងសេចក្តីបញ្ជាក់សំខាន់ៗ ដែលផ្តល់ដោយសហមេធាវីតំណាងអ្នកដាក់ពាក្យសុំ[redacted][152]។

---

[150] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ៣៩-៤០ និង៤៤។

[151] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក II ផ្នែក៣(ច)។

[152] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ៤៥-៤៨។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

00504360



៥៨. បណ្ដឹងឧទ្ធរណ៍ទី២ ខកខានពុំបានចង្អុលទៅកាន់ព័ត៌មានបន្ថែមណាមួយជាក់លាក់ ដែលមាននៅក្នុងឯកសារទាំងនេះឡើយ ហើយថែមទាំងពុំបានលើកឡើងករណីបង្ហាញថាតើព័ត៌មានទាំងនោះអាចមានផលប៉ះពាល់ទៅលើដីកាទី២ ដោយរបៀបណា ចំពោះភាគីបណ្ដឹងឧទ្ធរណ៍ទាំង៣រូបនេះ ប្រសិនបើ ស.ច.ស យកព័ត៌មានទាំងនោះមកធ្វើការពិចារណា។ ជាពិសេស អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ចំពោះភាគីបណ្ដឹងឧទ្ធរណ៍ពីរចុងក្រោយ ដើម្បី"បញ្ជាក់បំភ្លឺអំពីអត្តសញ្ញាណ" ឯកសារតែមួយគត់នៅក្នុងបណ្ដឹងឧទ្ធរណ៍ទីពីរដែលយោងលើខ្លឹមសារឯកសារទាំងនោះ គឺពាក់ព័ន្ធនឹងបញ្ហាមួយដែលមិនមែនជាចំណុចវិវាទនៅក្នុងរឿងក្ដីនេះ ដោយហេតុថាដីកាទី២បានទទួលស្គាល់ថាអ្នកដាក់ពាក្យសុំទាំងអស់បានផ្ដល់ភស្តុតាងបញ្ជាក់រួចរាល់ហើយអំពីអត្តសញ្ញាណរបស់ខ្លួន[១៥៣]។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសូមបដិសេធមូលដ្ឋាននេះនៃបណ្ដឹងឧទ្ធរណ៍ ហើយអង្គបុរេជំនុំជម្រះសូមងាកមក ពិនិត្យមូលដ្ឋានចុងក្រោយនៃបណ្ដឹងឧទ្ធរណ៍ ទាក់ទិននឹងអង្គហេតុដែលថាដីកាដែលត្រូវបានជំទាស់ធ្វើឱ្យប៉ះពាល់ទៅដល់សំណុំរឿងរបស់ អ.វ.ត.ក ទាំងមូល ស្ដីពីអំពើប្រល័យពូជសាសន៍ ប្រឆាំងនឹងជនជាតិវៀតណាម ។

## ច. តើដីកាទី២ដែលមានការជំទាស់ ធ្វើឱ្យប៉ះពាល់ដល់សំណុំរឿងរបស់ អ.វ.ត.ក ទាំងមូលស្ដីពីអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម ដែរឬទេ?

៥៩. មូលដ្ឋានចុងក្រោយនេះនៃបណ្ដឹងឧទ្ធរណ៍របស់ភាគីបណ្ដឹងឧទ្ធរណ៍ ចោទប្រកាន់ថាដីកាទី២បានធ្វើឱ្យប៉ះពាល់ទៅដល់សំណុំរឿងរបស់ អ.វ.ត.ក ទាំងមូលស្ដីពីអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម[១៥៤]។

៦០. អង្គបុរេជំនុំជម្រះបានជ្រាបអំពីការពិតដែលថា វិសាលភាពនៃកិច្ចស៊ើបសួរនាពេលបច្ចុប្បន្នដូចដែលត្រូវបានកំណត់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូន

[១៥៣] ដីកាទីពីរដែលត្រូវបានជំទាស់ កថាខណ្ឌ១៥។

[១៥៤] បណ្ដឹងឧទ្ធរណ៍ទីពីរ ផ្នែក III ផ្នែក៣(ឆ)។



ECCC • CETC PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

រឿងឲ្យស៊ើបសួរបន្ថែម គឺពុំអាចឆ្លុះបញ្ចាំងឲ្យបានពេញលេញនូវវិសាលភាពនៃឧក្រិដ្ឋកម្ម ដែលខ្មែរក្រហមបានប្រព្រឹត្តប្រឆាំងនឹងជនជាតិវៀតណាម ក្នុងអំឡុងរយៈកាលពាក់ព័ន្ធឡើយ។ ដូចដែលយើងបានបង្ហាញពីខាងដើម តាមច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក សហព្រះរាជអាជ្ញាមានភារៈទទួលខុសត្រូវតែម្យ៉ាងគត់ ក្នុងការកំណត់វិសាលភាពនៃកិច្ចស៊ើបសួរ ហើយអង្គបុរេជំនុំជម្រះពុំអាចបញ្ចេញមតិយោបល់ណាមួយអំពីថាតើសេចក្តីសម្រេចរបស់សហព្រះរាជអាជ្ញាត្រង់ប្រការនេះ អាចមានផលប៉ះពាល់ដល់លទ្ធភាពរបស់ខ្លួនក្នុងការបង្ហាញភស្តុតាង ទាក់ទិននឹងការចោទប្រកាន់លើជនត្រូវចោទអំពីបទអំពើប្រល័យពូជសាសន៍ ដែលប្រព្រឹត្តសំដៅលើក្រុមជនជាតិវៀតណាមដែរឬយ៉ាងណានោះទេ។

## ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច÷

១) មិនទទួលយកបណ្តឹងឧទ្ធរណ៍ទី១។

២) ទទួលយកបណ្តឹងឧទ្ធរណ៍ទី២។

៣) បដិសេធដីកាទី២ ដោយហេតុថាដីកានេះប្រកាសមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី [redacted] [redacted]05, [redacted]15, [redacted]19, [redacted]20, [redacted]23, និង [redacted]24។ ដោយសារហេតុនេះ ប្រកាសទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី [redacted] ដោយសារពាក្យសុំនេះបញ្ជាក់អំពីទំនាក់ទំនងរវាងព្យសនកម្ម និងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ត្រង់កថាខណ្ឌ ៤៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ប្រកាសទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី [redacted] ដោយសារពាក្យសុំទាំងនេះបញ្ជាក់អំពីទំនាក់ទំនងរវាងព្យសនកម្ម និងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ត្រង់កថាខណ្ឌ ៤២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

៤) ប្រកាសថា៖ (i) អង្គបុរេជំនុំជម្រះពុំទទួលបានសំឡេងគាំទ្រយ៉ាងតិចពីចៅក្រមចំនួន៤រូបទៅលើមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ដែលបានចោទប្រកាន់ថា ស.ច.ស មានកំហុសអង្គច្បាប់

និងអង្គហេតុ ដោយបានរំលោភសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៨រូប ដែលបានការទទួលស្គាល់រួចហើយ ជាពិសេសនៅពេលប្រកាសមិនទទួលយកពាក្យសុំ ដោយពុំមានមូលហេតុ និង(ii) តម្កល់ដីកាទី២ដោយគ្មានការការកែប្រែត្រង់មូលដ្ឋាននេះ។

**៥)** បដិសេធបណ្តឹងឧទ្ធរណ៍ទី២ នៅត្រង់ប្រការផ្សេងៗទាំងអស់។

សាលដីកានេះបិទផ្លូវតវ៉ា អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង។

**ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ ២៧ ខែ មេសា ឆ្នាំ ២០១០**

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

Rowan DOWNING **ន៉ី ថុល** Catherine MARCHI-UHEL **ហួត វុទ្ធី** **ប្រាក់ គឹមសាន**

00504363



## មតិយោបល់របស់ចៅក្រម ន័យ ថុល ចៅក្រម MARCHI-UHEL និងចៅក្រម ហួត វុទ្ធី ស្តីពីការប្រកាសមិនទទួលយកពាក្យសុំតាំខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលស្គាល់រួចហើយ

១. ដោយសារមានការចោទប្រកាន់ពីភាគីបណ្តឹងឧទ្ធរណ៍ យើងសូមបង្ហាញនូវមតិលើបញ្ហាចោទមួយគឺថាតើសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") មានកំហុសអង្គច្បាប់ និងកំហុសអង្គហេតុលើការរំលោភសិទ្ធិទាំងឡាយរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំបីដែលបានទទួលស្គាល់ ដែរឬទេ នៅពេលខ្លួនប្រកាសមិនទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះវិញដោយគ្មានហេតុផល[១៥៥]។

២. នៅក្នុងរឿងក្តីនេះ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនជាតិវៀតណាម និងខ្មែរក្រោមចំនួនប្រាំបីនាក់ គឺ [redacted]21, [redacted]22, [redacted]23, [redacted]24, [redacted]01, [redacted]02, [redacted]04 និង [redacted]10 បានទទួលលិខិតម្នាក់មួយច្បាប់ៗ[១៥៦]ពីក្រឡាបញ្ជីរបស់ ស.ច.ស ដែលលិខិតនោះបញ្ជាក់ថាបានទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយបានជូនដំណឹងថា (១) ពាក្យសុំទាំងនេះបានដាក់ចូលទៅក្នុងសំណុំរឿងរួចហើយ ដូច្នេះហើយ "លើក

---

[១៥៥] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ ៣២-៣៣ កថាខណ្ឌ ៣៩-៤០ និងកថាខណ្ឌ ៤៤។ សូមអាន កថាខណ្ឌ ៤៩-៥០ នៃសាលដីកាបច្ចុប្បន្ន ដែលសង្ខេបទឡ្ហីករណ៍របស់ដើមបណ្តឹងឧទ្ធរណ៍ក្នុងការគាំទ្រដល់មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ។

[១៥៦] លិខិតចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២00៩ ទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី [redacted]23 [redacted] និង [redacted]24 [redacted]។ លិខិតចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២00៩ ទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី [redacted]21 [redacted] និង [redacted]22 [redacted]។ លិខិតចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២00៩ ទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី [redacted]01 [redacted]។ លិខិតចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២00៩ ទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី [redacted]02 [redacted]។ លិខិតចុះថ្ងៃទី២ ខែតុលា ឆ្នាំ២00៩ ទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី [redacted]04 [redacted]។ និងលិខិតចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២00៩ ទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី [redacted]10 [redacted] ("លិខិតពីក្រឡាបញ្ជី")។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C C.E.T.C

លែងតែមានសេចក្តីសម្រេចផ្លាស់ប្តូរពីនៅពេលក្រោយរបស់ ស.ចៅ.ស លោក នៅពេលនេះត្រូវបានចាត់ទុកថាជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការស៊ើបអង្កេតលើសំណុំរឿង" លេខ ០០២។ (២) ស.ចៅ.ស អាច "នៅគ្រប់ពេលនៃដំណើរការស៊ើបអង្កេតរបស់ខ្លួន ធ្វើសេចក្តីសម្រេចជាផ្លូវការមួយទាក់ទិននឹងពាក្យសុំរបស់លោក ដែលអាច "ជាការសម្រេចយល់ព្រម ឬបដិសេធ ប្រសិនបើ ស.ចៅ.ស ពិចារណាឃើញថា លក្ខណៈវិនិច្ឆ័យទាំងឡាយដែលកំណត់ដោយវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះមិនត្រូវបានបំពេញ" (៣) សេចក្តីសម្រេចបែបនេះគឺបើកឱ្យធ្វើបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះបាន[១៥៧]។

៣. ដូចដែលភាគីបណ្តឹងឧទ្ធរណ៍បានចោទប្រកាន់ បញ្ហាចោទនៅចំពោះមុខយើងគឺថាតើលិខិតនេះជាការទទួលស្គាល់ជាផ្លូវការលើបុគ្គលខាងលើជាដើមបណ្តឹងរដ្ឋប្បវេណីដែរឬទេ។ ប្រសិនបើជាការទទួលស្គាល់ជាផ្លូវការមែននោះ តើ ស.ចៅ.ស មានអំណាចបដិសេធដើមបណ្តឹងរដ្ឋប្បវេណី "ពេញសិទ្ធិ" ដែរឬទេ អនុលោមតាមវិធាន ២៣(៣) នៃវិធានផ្ទៃក្នុង។

៤. យើងកត់សម្គាល់ឃើញថា ខប្បញ្ញត្តិនៅក្នុងវិធាន ២៣(៣) នៃវិធានផ្ទៃក្នុងបានធ្វើវិសោធនកម្មក្នុងអំឡុងពេល ដែលក្រឡាបញ្ជីបានបញ្ជូនលិខិតទៅអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្រាំបីនាក់ ម្នាក់មួយច្បាប់ៗ។

៥. នៅក្នុងអំឡុងពេលដែលពាក់ព័ន្ធនឹងលិខិតនីមួយៗ ដែលបានបញ្ជូនទៅ [redacted]21, [redacted]22, [redacted]23, [redacted]24, [redacted]01, និង [redacted]02 វិធាន ២៣ នៃវិធានផ្ទៃក្នុងចែងថា៖

> "នៅពេលណាក៏ដោយក្នុងអំឡុងពេលស៊ើបសួរ ជនរងគ្រោះដែលមានបំណងចង់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ត្រូវដាក់ពាក្យសុំនោះជាលាយលក្ខណ៍អក្សរដោយអនុលោមទៅតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ។ អនុលោមទៅតាមបទប្បញ្ញត្តិស្តីពីការការពារជនរងគ្រោះ ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះសហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងនេះទៅសហព្រះរាជអាជ្ញា និងជនត្រូវចោទ។ សហចៅក្រមស៊ើបអង្កេត អាចសម្រេចចេញដីកា ដោយមាន

[១៥៧] ដូចខាងលើ។



E.C.C.C • C.E.T.C PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

សំអាងហេតុ បដិសេធពាក្យបណ្ដឹងតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបាន។ ដីកានេះត្រូវបើកផ្លូវប្ដឹងឧទ្ធរណ៍ដល់ជនរងគ្រោះ។”[១៥៨]

បន្ទាប់មក វិធាន ២៣(៤) នៃវិធានផ្ទៃក្នុងចែងអំពីលទ្ធភាពរបស់ជនរងគ្រោះក្នុងការចូលរួមជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ នីតិវិធីនេះលែងអនុវត្តទៅបានទៀតហើយ អនុលោមតាមប្រព័ន្ធថ្មី ដែលបានអនុម័តនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ ប៉ុន្តែនីតិវិធីនេះអនុវត្តទៅបាននៅក្នុងពេលដែលបញ្ជូនលិខិតទៅ [redacted]04 និង [redacted]10។

៦. យើងកត់សម្គាល់ឃើញថា ប្រព័ន្ធចាស់មិនបានចែងថា ស.ច.ស ត្រូវធ្វើសេចក្ដីសម្រេចដើម្បីប្រកាសទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីឡើយ។ ផ្ទុយមកវិញ វាបានបើកលទ្ធភាពដល់ ស.ច.ស ក្នុងការប្រកាសមិនទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ទោះបីជាមានស្ថានភាពបែបនេះក៏ដោយ វិធានផ្ទៃក្នុងផ្ដល់សិទ្ធិជាច្រើនដល់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងដំណាក់កាលស៊ើបអង្កេត។ ចំនុចនេះជាក្របខណ្ឌច្បាប់ ដែលក្រឡាបញ្ជីបានចេញលិខិតទាំងប្រាំមួយច្បាប់។ ប្រសិនបើប្រៀបធៀបវិញ អនុលោមតាមតាមច្បាប់ជាតិ ទោះបីជាមាត្រា ១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ[១៥៩]ចែងថា ចៅក្រមស៊ើបសួរធ្វើការកត់សម្គាល់នូវការដាក់ពាក្យប្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមដីកាក៏ដោយ ក្រមនីតិវិធីព្រហ្មទណ្ឌមិនតម្រូវឱ្យមានការធ្វើសេចក្ដីសម្រេចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីឡើយ ដែលវាដូចនឹងប្រព័ន្ធចាស់របស់ អ.វ.ត.ក។

៧. ដូចដែលបានលើកឡើងខាងលើ អនុលោមតាមប្រព័ន្ធថ្មី ដែលនៅជាធរមាននៅពេលបញ្ជូនលិខិតទៅ [redacted]04 និង [redacted]10 វិធាន ២៣(៣) និងវិធាន ២៣(៤) នៃវិធានផ្ទៃក្នុងចែងថា៖

“៣. ជនរងគ្រោះដែលមានបំណងចង់តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរយ៉ាងយូរ (១៥) ថ្ងៃ បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតជូនដំណឹងដល់ភាគីទាំងអស់ អំពីការបញ្ចប់កិច្ចស៊ើបសួរ តាមផ្លូវតុលាការដោយអនុលោមតាមវិធាន៦៦(១)។ អនុលោមតាមបទប្បញ្ញត្តិ ស្ដីពីវិធានការការពារជនរងគ្រោះ ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះ

---

[១៥៨] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៣) ថ្ងៃទី៦ ខែមីនា ឆ្នាំ២០០៩។

[១៥៩] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះខែកញ្ញា ឆ្នាំ២០០៧ មាត្រា ១៣៩។



PRE-TRIAL CHAMBER • E.C.C.C • C.E.T.C • CHAMBRE PRELIMINAIRE

សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងនេះទៅសហព្រះរាជអាជ្ញា និងជនត្រូវចោទ។ សហចៅក្រមស៊ើបអង្កេតអាចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរហូតដល់កាលបរិច្ឆេទចេញដីកាដំណោះស្រាយ។ ដីកានេះត្រូវបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍ ដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលមានចែងក្នុងសេចក្តីណែនាំអនុវត្ត។

៤. នៅពេលចេញដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតត្រូវសម្រេចអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលនៅសេសសល់ទាំងអស់ ដោយដីកាដោយឡែក។ ដីកានេះត្រូវបើកផ្លូវប្តឹងឧទ្ធរណ៍សង្ខេប ដោយភាគី ឬ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ បណ្តឹងឧទ្ធរណ៍នេះមិនផ្អាកដំណើរការនីតិវិធីទេ។"[១៦០]

៨. នៅពេលពិនិត្យឡើងវិញយ៉ាងប្រុងប្រយ័ត្ននូវពាក្យពេចន៍នៅក្នុងលិខិតទាំងឡាយរបស់ក្រឡាបញ្ជី ហើយនៅពេលពិចារណាលិខិតទាំងនេះ យោងតាមក្រមខណ្ឌច្បាប់ដែលបានលើកឡើងខាងលើ យើងយល់អំពីហេតុផលនៃវិធីសាស្ត្រដែល ស.ច.ស បានអនុវត្ត ដោយមានគោលបំណងធានាសិទ្ធិទាំងឡាយរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរហូតដល់ពេលសម្រេចលើឋានៈរបស់អ្នកទាំងនេះជាចុងក្រោយ[១៦១]។ នៅពេលយល់ថាអ្នកដាក់ពាក្យសុំជា"ដើមបណ្តឹងរដ្ឋប្បវេណី" និងក្នុងខណៈធានានូវសិទ្ធិដែលបានកំណត់នៅក្នុងវិធាន ២៣(៣)នៃវិធានផ្ទៃក្នុង ក្នុងការប្រកាសមិនទទួលស្គាល់ពាក្យសុំទាំងនេះ ស.ច.ស មានគោលបំណងផ្តល់ជូនអ្នកទាំងនេះ និងមេធាវីរបស់ពួក[១៦២]គេនូវសិទ្ធិពិនិត្យព័ត៌មានសម្ងាត់

[១៦០] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៤) ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩។

[១៦១] យើងកត់សម្គាល់ឃើញថា វិធាន ២៣ ស្ទួន (២) នៃវិធានផ្ទៃក្នុង (វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៥) ដែលចែងថា លើកលែងតែ និងរហូតដល់ពេលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចអនុវត្តសិទ្ធិទាំងឡាយរបស់ដើមបណ្តឹងរដ្ឋប្បវេណីបាន វិធាននេះយកតាមហេតុផលដូចគ្នា។

[១៦២] យើងកត់សម្គាល់ឃើញថា ដោយឈរលើមូលដ្ឋាននៃការទទួលស្គាល់បណ្តោះអាសន្ននេះ សចស បានស្នើសុំអ្នកស៊ើបអង្កេតរបស់ អ.វ.ត.ក នៅក្នុងដីកាចាត់ឱ្យសួរជំនួសចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឱ្យអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះឱ្យយល់ព្រមមកផ្តល់ចម្លើយ ដោយមិនមានវត្តមានរបស់មេធាវី និងជាពិសេស បញ្ជាក់អំពីអង្គហេតុដែលខ្លួនបានដឹងដោយផ្ទាល់។ សចស ទទួលដំណឹងអំពី និងបានរកឃើញអំពីអង្គហេតុដែលស្ថិតនៅក្រោមការស៊ើបអង្កេត តាមមធ្យោបាយផ្សេងទៀត ហើយជាពិសេសអំពីតួនាទីរបស់ជនត្រូវចោទ។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

នៅក្នុងសំណុំរឿង[១៦៣] និងមានគោលបំណងផ្តល់សិទ្ធិទាំងឡាយរបស់ដើមបណ្តឹងរដ្ឋប្បវេណី តាមបទប្បញ្ញត្តិនៃវិធានផ្ទៃក្នុង នៅក្នុងពេលស៊ើបអង្កេត ក្នុងនោះរួមមានសិទ្ធិស្នើសុំបំពេញកិច្ចស៊ើបសួរ (វិធាន ៥៥(១០)នៃវិធានផ្ទៃក្នុង និងសិទ្ធិទាំងឡាយដែលទទួលបាននៅពេលស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី (វិធាន ៥៩ នៃវិធានផ្ទៃក្នុង))។

៩. យើងយល់ថា ចៅក្រមដទៃទៀតបានចាត់ទុកលិខិតទាំងឡាយរបស់ក្រឡាបញ្ជីជាសេចក្តីសម្រេចរបស់ ស.ច.ស ដែលប្រកាសទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ យើងមិនយល់ស្របនឹងការវិភាគដូច្នេះទេ។ ប្រសិនបើពិចារណាលើពាក្យពេចន៍នៅក្នុងលិខិតទាំងនេះ យើងយល់ឃើញថា សេចក្តីសម្រេចណាមួយក៏ដោយរបស់ ស.ច.ស លើករណីនេះមិនទំនងជាការសម្រេចលើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ ប៉ុន្តែវាគ្រាន់តែផ្តល់នូវសិទ្ធិទាំងឡាយដែលដើមបណ្តឹងរដ្ឋប្បវេណីមានដល់អ្នកដាក់ពាក្យសុំជា*បណ្តោះអាសន្ន*តែប៉ុណ្ណោះ ឬក៏ វាជាការ*យល់ថា* អ្នកដាក់ពាក្យសុំ*ជា* ដើមបណ្តឹងរដ្ឋប្បវេណីរហូតដល់ពេលដែលសម្រេចលើឋានៈរបស់ពួកគេនៅពេលចុងក្រោយតែប៉ុណ្ណោះ។ យើងទទួលស្គាល់ថា លិខិតផ្ញើរទៅទាំងនេះមិនបានប្រើពាក្យ "ជាបណ្តោះអាសន្ន" ឬ "យល់ថាជា"ឡើយ។ លិខិតទាំងនេះបានប្រើពាក្យ "ចាត់ទុកជា" ដើមបណ្តឹងរដ្ឋប្បវេណី។ យើងយល់ឃើញទៀតថា ការនិយាយយោងលើ"សេចក្តីសម្រេចផ្លាស់ប្តូរនៅពេលក្រោយ" និងករណីដែលថា "នៅគ្រប់ពេល" ស.ច.ស អាច"ធ្វើសេចក្តីសម្រេចជាផ្លូវការមួយទាក់ទិននឹងពាក្យសុំរបស់លោក ដែលអាចជាការសម្រេចយល់ព្រម" គឺមានភាពច្បាស់លាស់ចំពោះករណីស្ថានភាពបណ្តោះអាសន្នបែបនេះ ទោះបីជាវាមិនអាចមានភាពច្បាស់លាស់ដូច្នេះចំពោះអ្នកដាក់ពាក្យសុំដែលមិនមែនជាមេធាវីក៏ដោយ។ យើងកត់សម្គាល់ឃើញថា អនុលោមតាមការអនុវត្តនៅក្នុងប្រទេសកម្ពុជា ចៅក្រមស៊ើបសួរមិនបង្គាប់ក្រឡាបញ្ជីរបស់ខ្លួនឱ្យបញ្ជូនលិខិតទាំងនេះទៅអ្នកដាក់ពាក្យសុំដើម្បីជូនដំណឹងដល់ពួកគេថា ពួកគេនឹងត្រូវយល់ថាជាដើមបណ្តឹងរដ្ឋប្បវេណី រហូតដល់ពេលចេញសេចក្តីសម្រេចផ្លូវការទាក់ទិននឹងការទទួលស្គាល់

---

[១៦៣] លិខិតពីក្រឡាបញ្ជី កថាខណ្ឌ ៣។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C C.E.T.C

00504368



ពាក្យសុំ បែបនេះឡើយ។ ប៉ុន្តែ តាមជាក់ស្តែង ចៅក្រមស៊ើបសួរចាត់ទុកអ្នកដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងពេលស៊ើបអង្កេត លើកលែងតែពាក្យសុំរបស់ពួកគេត្រូវបានប្រកាសមិនទទួលស្គាល់ជាផ្លូវការ។

១០. វិធាន ២១(១) នៃវិធានផ្ទៃក្នុងត្រង់ផ្នែកដែលពាក់ព័ន្ធចែងថា

"ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមានត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង"[១៦៤]។

វិធាន ២១(១)(ក) នេះវិធានផ្ទៃក្នុងចែងបន្ថែមទៀតថា "ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និង ត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"។

១១. យើងទទួលស្គាល់ថា ឋានៈបណ្តោះអាសន្នមិនអាចបំពេញលក្ខខណ្ឌនៃសច្ចភាព ដូចមានចែងនៅក្នុងវិធាន ២១(១) នៃវិធានផ្ទៃក្នុងឡើយ ប៉ុន្តែឋានៈនេះមានប្រយោជន៍សម្រាប់ជនរងគ្រោះជាងសេចក្តីសម្រេចតឹងរ៉ឹង ដែលបដិសេធអ្នកដាក់ពាក្យសុំនូវសិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី រហូតដល់ពេលធ្វើការសម្រេចអំពីឋានៈរបស់ពួកគេ ដូចដែលវិធានផ្ទៃក្នុងបានបញ្ញត្តិដែល នៅក្នុងប្រព័ន្ធច្បាប់នៅពេលនោះ ការសម្រេចដូច្នេះគួរត្រូវពន្យាររហូតដល់ដំណាក់កាលជំនុំជម្រះ[១៦៥] ឬ រហូតដល់ពេលណាមួយដែល ស.ច.ស ប្រកាសទទួលស្គាល់ពួកគេជាផ្លូវការ

---

[១៦៤] វិធាន ២១(១) នៃវិធានផ្ទៃក្នុង

[១៦៥] ចំពោះករណីនេះ យើងកត់សម្គាល់ឃើញថា អនុលោមតាមប្រព័ន្ធច្បាប់ មិនមានការដាក់កាតព្វកិច្ចដល់អង្គជំនុំជម្រះសាលាដំបូង ក្នុងការប្រកាសការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី មុនពេលខ្លួនចេញសេចក្តីសម្រេច។ នៅក្នុងដំណាក់ការស៊ើបអង្កេត វិធាន ២៣ (៤) នៃវិធានផ្ទៃក្នុង (វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៣) ផ្តល់លទ្ធភាពដល់អង្គជំនុំជម្រះសាលាដំបូងត្រឹមតែការប្រកាសមិនទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C • C.E.T.C

និងជាវិជ្ជមាន តែម្តង ដោយមិនចាំបាច់មានមូលដ្ឋានគតិយុត្តិនៅក្នុងវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញទៀតថា វិធីសាស្ត្រនេះត្រូវតែពិចារណាដោយផ្អែកលើកាលៈទេសៈពិសេសរបស់ អ.វ.ត.ក និងវិសាលភាពជាក់លាក់នៃសំណុំរឿងលេខ ០០២ ពោលគឺដោយសារវិសាលភាពទូលំទូលាយនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងចំនួនអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីច្រើន។ ដោយពិចារណាឃើញដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា វិធីសាស្ត្រដែលត្រូវបានគេជំទាស់នេះមិនស្របនឹងធានផ្ទៃក្នុងឡើយ។ អង្គបុរេជំនុំជម្រះយល់ឃើញថា វិធីសាស្ត្រនេះជួយឱ្យការចូលរួមរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីកាន់តែមានតម្លៃជាងវិធីសាស្ត្រតឹងរ៉ឹង ដោយមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិទាំងឡាយរបស់ជនត្រូវចោទ។ យ៉ាងហោចណាស់ អង្គបុរេជំនុំជម្រះមិនបានដឹងថា ជនត្រូវចោទបានតវ៉ាលើវិធីសាស្ត្រដែលគេជំទាស់នេះឡើយ។ ទោះក្នុងករណីណាក៏ដោយ អង្គបុរេជំនុំជម្រះជឿថា ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីបណ្តោះអាសន្នមិនបានផ្តល់ដល់សិទ្ធិវ័ន្តនូវសិទ្ធិដែលមិនទាន់គ្រប់លក្ខខណ្ឌ។ ចាប់តាំងពីពេលនោះមក ស.ច.ស បានបញ្ចប់ការវិភាគរបស់ខ្លួនថាតើដើមបណ្តឹងឧទ្ធរណ៍បានបង្ហាញថាព្យសនកម្មដែលខ្លួនចោទប្រកាន់នោះជាផលវិបាកដោយផ្ទាល់ចេញពីឧក្រិដ្ឋកម្មយ៉ាងហោចណាស់មួយករណីដែរឬយ៉ាងណា។ នៅក្នុងន័យអវិជ្ជមាន ស.ច.ស មានកាតព្វកិច្ចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីការពារសិទ្ធិទាំងឡាយរបស់ជនត្រូវចោទ។

១២. យើងកត់សម្គាល់ឃើញថា យោងតាមប្រព័ន្ធចាស់ ស.ច.ស មិនមានកាតព្វកិច្ចសម្រេចលើឋានៈរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ដូចដែលបានលើកឡើងខាងលើ យើងពិចារណាឃើញថា យោងតាមប្រព័ន្ធច្បាប់ចាស់ លិខិតប្រាំមួយច្បាប់ ដែលក្រឡាបញ្ជីបានបញ្ជូនពីដំបូងមិនមែន ជាសេចក្តីសម្រេចប្រកាសទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណីឡើយ។ ហេតុដូច្នេះ លិខិតទាំងនេះអាចយល់ឃើញថាជាការផ្តល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាបណ្តោះអាសន្ន ដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រហូតដល់ពេលមានការសម្រេចលើឋានៈនេះជាលើកចុងក្រោយ។ យើងក៏កត់សម្គាល់ឃើញដែរថា អនុលោមតាមប្រព័ន្ធចាស់ ស.ច.ស អាចបដិសេធមិនទទួលស្គាល់



អង្គបុរេជំនុំជម្រះ E.C.C.C. C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ប៉ុន្តែ ស.ច.ស មិនមានកាតព្វកិច្ច បដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទេ រហូតដល់ពេលចេញដីកាដំណោះស្រាយ។ យើងយល់ឃើញថា លិខិតពីរច្បាប់ចុងក្រោយដែលក្រឡាបញ្ជីបញ្ជូនចេញ មិនមែនជាការសម្រេចលើ ការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយលិខិតទាំងនេះ អាចយល់ឃើញថាជាការផ្តល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាបណ្តោះអាសន្ន ដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រហូតដល់ពេលមានការសម្រេចលើឋានៈនេះជាលើកចុងក្រោយ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០

ន័យ ផុល　　Catherine MARCHI-UHEL　　ហួត វុធី

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៤៧ និងអបជ ៤៨)
លេខ/No.D250/3/2/1/5

**មតិយោបល់របស់ចៅក្រម ប្រាក់ គឹមសាន និងចៅក្រម ROWAN DOWNING ស្តីពីការប្រកាសមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលស្គាល់រួចហើយ**

១. យើងយល់ស្របជាមួយនឹងមតិរបស់ចៅក្រម ន័យ ថុល ចៅក្រម ហួត វុទ្ធី និង ចៅក្រម Marchi-Uhel លើគ្រប់មូលដ្ឋានទាំងអស់ដែលបានលើកឡើងនៅក្នុងសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នេះ លើកលែងតែមូលដ្ឋានមួយចំនួនដូចជា "ក.ស.ច.ស បានរំលោភលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់រួចហើយ នៅពេលខ្លួនបានប្រកាសមិនទទួលស្គាល់ពួកគេវិញ ដោយគ្មានមូលហេតុ" ដូចបានលើកឡើងនៅក្នុងកថាខណ្ឌទី៣២ និងកថាខណ្ឌទី៣៣ នៃបណ្តឹងឧទ្ធរណ៍[១៦៦] និងមូលដ្ឋានថា "កសចស បានទទួលស្គាល់កាលពីលើកមុនថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជនជាតិវៀតណាម ស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក" ដូចបានលើកឡើងនៅក្នុងកថាខណ្ឌទី៣៩ និងកថាខណ្ឌទី៤០ នៃបណ្តឹងឧទ្ធរណ៍[១៦៧]។ ចៅក្រម ន័យ ថុល ចៅក្រម ហួត វុទ្ធី និងចៅក្រម Marchi-Uhel យល់ឃើញថា ការទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចូលទៅក្នុងសំណុំរឿង ធ្វើឡើងពីដំបូងដោយសហចៅក្រមស៊ើបអង្កេត តាមរយៈការចេញសេចក្តីសម្រេចជាបណ្តោះអាសន្នមួយ ហើយសេចក្តីសម្រេចបដិសេធពាក្យសុំរបស់អ្នកទាំងនេះនឹងធ្វើឡើងជាចុងក្រោយមួយទៀត។ យើងយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីសម្រេចមួយទទួលស្គាល់អ្នកដាក់ពាក្យសុំទាំងនេះជាដើមបណ្តឹងរដ្ឋប្បវេណី ដោយក្នុងនោះបានផ្តល់សិទ្ធិដល់អ្នកទាំងនេះមកជាមួយផង ហើយក្រោយមក

---

[១៦៦] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ៣២-៣៣។

[១៦៧] បណ្តឹងឧទ្ធរណ៍ទីពីរ ផ្នែក III កថាខណ្ឌ៣៩-៤០។

សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីសម្រេចមួយ ដកអ្នកទាំងនេះចេញពីសំណុំរឿងវិញ។ សេចក្តីសម្រេចក្រោយនេះមិនត្រឹមត្រូវតាមផ្លូវច្បាប់ ហើយមានភាពអយុត្តិធម៌ (ក្នុងអត្ថន័យនៃមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ) ហេតុដូច្នេះគួរចាត់ទុកជាមោឃៈ។ យើងចេញមតិដោយឡែកនេះរួមគ្នាទាក់ទងនឹងមូលដ្ឋានទាំងនេះ។

២. យើងកត់សម្គាល់ឃើញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជនជាតិវៀតណាម និងខ្មែរក្រោមប្រាំបីនាក់គឺ [redacted]21, [redacted]22, [redacted]23, [redacted]24, [redacted]01, [redacted]02, [redacted] 04 និង [redacted]10 បានទទួលលិខិតម្នាក់មួយច្បាប់ៗពីក្រឡាបញ្ជីរបស់ សចស (លិខិត) ដោយក្នុងនោះលើកឡើងថា៖

> “ទំរង់បែបបទសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក-លោកស្រី ត្រូវបានទទួលដោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ហើយតាមការណែនាំរបស់លោកសហចៅក្រមស៊ើបអង្កេតត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងព្រហ្មទណ្ឌដូចបានបញ្ជាក់ខាងលើ។ ដូច្នេះ លើកលែងតែមានសេចក្តីសម្រេចផ្លាស់ប្តូរពីនៅពេលក្រោយរបស់សហចៅក្រមស៊ើបអង្កេត លោក-លោកស្រី នៅពេលនេះ ត្រូវបានចាត់ទុកថាជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក-កសចស។
>
> សហចៅក្រមស៊ើបអង្កេតអាច “នៅគ្រប់ពេលនៃដំណើរការស៊ើបអង្កេតរបស់ខ្លួន ធ្វើសេចក្តីសម្រេចជាផ្លូវការមួយទាក់ទិននឹងពាក្យសុំរបស់លោក ដែលអាចជាការសម្រេចយល់ព្រមឬបដិសេធ ប្រសិនបើ សចស ពិចារណាឃើញថា លក្ខណៈវិនិច្ឆ័យទាំងឡាយដែលកំណត់ដោយវិធានផ្ទៃក្នុង ' និងសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះមិនត្រូវបានបំពេញ។ សេចក្តីសម្រេចបែបនេះគឺបើកឱ្យធ្វើបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះបាន។
>
> លោក-លោកស្រី ក៏ត្រូវដឹងផងដែរថា តាមរយៈការចូលរួមក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី លោក-លោកស្រី និងមេធាវី អាចដឹងអំពីព័ត៌មានសម្ងាត់នានា ដែលមាននៅក្នុងសំណុំរឿងព្រហ្មទណ្ឌនេះបាន។ ប៉ុន្តែ ដោយសារឯកសារសំណុំរឿងមានភាពសម្ងាត់ លោក-លោក



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ស្រី មិនត្រូវលាតត្រដាងព័ត៌មានសម្ងាត់ទាំងនោះឡើយ។ មានតែចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាប៉ុណ្ណោះ ដែលអាចសម្រេចផ្តល់ព័ត៌មានទាំងនោះជាសាធារណៈ”[១៦៨]។

៣. វិធាន ២៣(៣) និងវិធាន ២៣(៥) ចែងអំពីពាក្យសុំទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងរឿងក្តីនេះ។ យើងកត់សម្គាល់ឃើញថា វិធានផ្ទៃក្នុងបានធ្វើវិសោធនកម្ម ក្រោយពេលដាក់បណ្តឹងឧទ្ធរណ៍នេះ ពោលគឺមានន័យថា បណ្តឹងឧទ្ធរណ៍នេះត្រូវយកមកពិចារណា ដោយអនុលោមទៅតាមវិធានផ្ទៃក្នុងជាធរមានមុនពេលវិសោធនកម្ម។ រហូតដល់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ អនុវិធានទាំងពីរនេះចែងថា៖

**“វិធាន ២៣៖ បណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយជនរងគ្រោះ**

នៅពេលណាក៏ដោយក្នុងអំឡុងពេលស៊ើបសួរ ជនរងគ្រោះដែលមានបំណងចង់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ត្រូវដាក់ពាក្យសុំនោះជាលាយលក្ខណ៍អក្សរដោយអនុលោមទៅតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ។ អនុលោមទៅតាមបទប្បញ្ញត្តិស្តីពីការការពារជនរងគ្រោះ ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះសហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងនេះទៅសហព្រះរាជអាជ្ញា និងជនត្រូវចោទ។ សហចៅក្រមស៊ើបអង្កេត អាចសម្រេចចេញដីកា ដោយមានសំអាងហេតុ បដិសេធពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន ។ ដីកានេះត្រូវបើកផ្លូវប្តឹងឧទ្ធរណ៍ដល់ជនរងគ្រោះ។

---

[១៦៨] លិខិតចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៩ ស្តីពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ [redacted] 23 [redacted] និង [redacted] 24 [redacted]។ លិខិតចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ស្តីពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ [redacted] 21 [redacted] និង [redacted] 22 [redacted]។ លិខិតចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ស្តីពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ [redacted] 01 [redacted]។ លិខិតចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ [redacted] 02 [redacted]។ លិខិតចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០០៩ ស្តីពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ [redacted] 09 [redacted]។ លិខិតចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ [redacted] 10 [redacted] (“លិខិត”)។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

[...]

៥. គ្រប់ពាក្យបណ្ដឹងតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ត្រូវមានព័ត៌មានគ្រប់គ្រាន់ដើម្បីអនុញ្ញាតឱ្យ ពិនិត្យបញ្ជាក់អំពីភាពសមស្របរបស់ពាក្យបណ្ដឹងជាមួយនឹងវិធានផ្ទៃក្នុងនេះ។ ជាពិសេស ពាក្យបណ្ដឹងត្រូវផ្ដល់ព័ត៌មានលម្អិតអំពីឋានៈជាជនរងគ្រោះ បញ្ជាក់អំពីប្រភេទឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់ និងភ្ជាប់មកជាមួយនូវភស្តុតាងបញ្ជាក់អំពីព្យសនកម្មដែលទទួលរង ឬ ការបង្ហាញអំពីពិរុទ្ធភាពរបស់ឧក្រិដ្ឋជន ដែលត្រូវចោទប្រកាន់។ ពាក្យបណ្ដឹងត្រូវតែមានការបញ្ជាក់ ឱ្យបានត្រឹមត្រូវអំពីលំនៅដ្ឋានរបស់ជនរងគ្រោះ ការិយាល័យចុះបញ្ជីរបស់សមាគមជនរងគ្រោះដែលខ្លួនជាសមាជិក ឬ អាសយដ្ឋានរបស់មេធាវី ដើម្បីងាយស្រួលដល់ការបញ្ជូន និង ការជូនដំណឹង។ នៅពេលដែលអាសយដ្ឋាននេះស្ថិតនៅក្រៅប្រទេសកម្ពុជា អ្នកប្ដឹងត្រូវតែផ្ដល់អាសយដ្ឋានមួយនៅក្នុងប្រទេសកម្ពុជា[១៦៩]"។

៤. នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ អនុវិធាន ៣ នៃវិធាននេះបានធ្វើវិសោធនកម្មដោយចែងថា៖

"៣. ជនរងគ្រោះដែលមានបំណងចង់តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរយ៉ាងយូរ (១៥) ថ្ងៃ បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតជូនដំណឹងដល់ភាគីទាំងអស់ អំពីការបញ្ចប់កិច្ចស៊ើបសួរ តាមផ្លូវតុលាការដោយអនុលោមតាមវិធាន៦៦(១)។ អនុលោមតាមបទប្បញ្ញត្តិ ស្ដីពីវិធានការការពារជនរងគ្រោះ ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងនេះទៅសហព្រះរាជអាជ្ញា និងជនត្រូវចោទ។ សហចៅក្រមស៊ើបអង្កេតអាចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរហូតដល់កាលបរិច្ឆេទចេញដីកាដំណោះស្រាយ។ ដីកានេះត្រូវបើកផ្លូវឱ្យប្ដឹងឧទ្ធរណ៍ ដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដូចដែលមានចែងក្នុងសេចក្ដីណែនាំអនុវត្ត"[១៧០]។

៥. នៅពេលខ្លួនដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ភាគីបណ្ដឹងឧទ្ធរណ៍បានដាក់ពាក្យសុំរបស់ខ្លួន ដោយអនុលោមតាមវិធានផ្ទៃក្នុង និងសេចក្ដីណែនាំអនុវត្តទាំងឡាយដែលមានចែង។ ដើមបណ្ដឹងរដ្ឋប្បវេណី [redacted]21, [redacted]22, [redacted]23, [redacted]24, [redacted]01, និង [redacted]02 បានដាក់ពាក្យសុំរបស់ខ្លួនមុនថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ ហើយដើមបណ្ដឹងរដ្ឋប្បវេណី [redacted]

---

[១៦៩] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៣) ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០០៨។

[១៧០] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៤) ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨។



E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00504375



04 និង [redacted]10 បានដាក់ពាក្យសុំ ក្រោយថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ និង មុនថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០។ ដូច្នេះ អនុវិធាន ៣ មិនមានភាពខុសគ្នាធំធេងលើខ្លឹមសារឡើយ នៅមុន និង ក្រោយថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩។

៦. យោងតាមលិខិត យើងកត់សម្គាល់ឃើញថា កឡាបញ្ជីរបស់ ស.ច.ស បានបំពេញការងាររបស់ខ្លួនតាម"សេចក្តីបង្គាប់របស់សហចៅក្រមស៊ើបអង្កេត" ឱ្យដាក់ពាក្យសុំចូលទៅក្នុងសំណុំរឿង។ នៅពេលពាក្យសុំបានដាក់ចូលទៅក្នុងសំណុំរឿង លិខិតនេះបានលើកឡើងបន្តទៀតថា "ដូច្នេះ លើកលែងតែមានសេចក្តីសម្រេចផ្លាស់ប្តូរពីនៅពេលក្រោយរបស់សហចៅក្រមស៊ើបអង្កេត លោក-លោកស្រី នៅពេលនេះ ត្រូវបានចាត់ទុកថាជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក-កសចស"។ សេចក្តីសម្រេចនេះធ្វើឡើងដោយអនុលោមតាមវិធាន ២៣(៣) នៃវិធានផ្ទៃក្នុង ហើយវាបានបង្ហាញយ៉ាងច្បាស់ត្រង់ខប្បញ្ញត្តិរក្សាសិទ្ធិទុកចេញ"សេចក្តីសម្រេចផ្លាស់ប្តូរនៅពេលក្រោយ"។ ដោយសារលិខិតនេះបានចេញក្រោមសិទ្ធិអំណាចរបស់ ស.ច.ស ដូច្នេះគ្រប់ចំនុចនៅក្នុងលិខិតនេះជាសេចក្តីសម្រេច។ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចលើកមុនថា អនុស្សរណៈរបស់សហចៅក្រមស៊ើបអង្កេត គឺជាសេចក្តីសម្រេចដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត។

៧. ខប្បញ្ញត្តិនៅក្នុងវិធាន ២៣(៣)នៃវិធានផ្ទៃក្នុងតម្រូវឱ្យមានការចេញសេចក្តីសម្រេច។ នៅពេលមានសេចក្តីសម្រេចទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីហើយនោះ ដើមបណ្តឹងរដ្ឋប្បវេណីទទួលបាននូវសិទ្ធិជាច្រើន អនុលោមតាមវិធានផ្ទៃក្នុង ដោយក្នុងនោះរួមមាន៖

i. ក្លាយជាភាគីក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ - វិធាន ២៣(៣)(ក)។

ii. អាចទទួលបានវិធានការការពារ - វិធាន ២៣(៣)(ខ)។

iii. អាចមានមេធាវីតំណាង - វិធាន ២៣(៤)។

iv. អាចផ្តល់ចម្លើយដោយមានវត្តមានមេធាវី - វិធាន ២៣(៣)(ក)។

v. អាចស្នើសុំបំពេញកិច្ចស៊ើបសួរ - វិធាន ៥៥(១០)។

vi. អាចដាក់បណ្តឹងឧទ្ធរណ៍ - វិធាន ៧៤(៤)។

vii. ជាគោលការណ៍ អាចចូលរួមជាភាគីនៅក្នុងបណ្តឹងឧទ្ធរណ៍។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00504376



viii. អាចគាំទ្រដល់ការចោទប្រកាន់ - វិធាន ២៣(១)(ក)។ និង

ix. អាចស្វែងរកសំណងផ្លូវចិត្ត និងសម្ភារភាព - វិធាន ២៣(១)(ខ)។

ការផ្តល់សិទ្ធិចូលរួមបែបនេះជាបញ្ហាមួយធំធេងណាស់ នៅពេលយើងពិចារណាអំពីអានុភាពនៃការចូលរួមនៅក្នុងដំណាក់កាលស៊ើបអង្កេត និងនៅពេលយើងពិចារណាលើតួនាទីគាំទ្រដល់ការចោទប្រកាន់ ដែលផ្តល់ជូនដល់ដើមបណ្តឹងរដ្ឋប្បវេណី ដូចមានចែងនៅក្នុងវិធាន ២៣(១)(ក)នៃវិធានផ្ទៃក្នុង។ នៅពេលពិចារណាលើផលប៉ះពាល់លើបញ្ហាសមភាពរវាងគូរភាគីក្តី ការគាំទ្រដល់ការចោទប្រកាន់បែបនេះអាចមានផលប៉ះពាល់ ហើយនៅពេលពិចារណាលើអានុភាពអាចស្នើសុំបំពេញកិច្ចស៊ើបសួរ សេចក្តីសម្រេចទទួលស្គាល់បុគ្គលណាម្នាក់ដាក់ចូលទៅក្នុងសំណុំរឿង មិនអាចយកធ្វើឡើងដោយមិនពិចារណាឱ្យបានដិតដល់នោះទេ។ បន្ថែមលើចំនុចនេះ កថាខណ្ឌទី៣ នៅក្នុងលិខិតបានលើកឡើងយ៉ាងច្បាស់ថា ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ខ្លួនមិនត្រូវលាតត្រដាងព័ត៌មានសម្ងាត់ណាមួយ ដែលលេចចេញតាមរយៈការស៊ើបអង្កេត។ ពិនិត្យជារួម លិខិតនេះផ្តល់អ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនូវសិទ្ធិពេញលេញទាំងស្រុង និងកាតព្វកិច្ចដែលដើមបណ្តឹងរដ្ឋប្បវេណីមាន។ ហេតុដូច្នេះ លិខិតនេះជាសេចក្តីសម្រេចរបស់ ស.ច.ស។

៨. ខប្បញ្ញត្តិនៅក្នុងវិធាន ២៣(៣)នៃវិធានផ្ទៃក្នុង ផ្តល់សិទ្ធិអំណាចដល់ ស.ច.ស ឱ្យចេញសេចក្តីសម្រេចតែម្តងគត់ ហើយប្រសិនបើវាជាសេចក្តីសម្រេចបដិសេធនោះ សេចក្តីសម្រេចនេះត្រូវផ្តល់សម្អាងហេតុ។ ប្រសិនបើមានករណីបែបនេះ សេចក្តីសម្រេចបដិសេធនេះបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍។ វិធានផ្ទៃក្នុងមិនបានអនុញ្ញាតឱ្យមាននីតិវិធីចេញសេចក្តីសម្រេចពីរដាច់ដោយឡែកពីគ្នាបែបនេះឡើយ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវដាក់ពាក្យសុំរបស់ខ្លួនដោយផ្តល់នូវព័ត៌មានលម្អិត ដូចមានចែងនៅក្នុងវិធាន២៣(៥)នៃវិធានផ្ទៃក្នុង។ ដើមបណ្តឹងរដ្ឋប្បវេណីមិនមានឱកាសដាក់ឯកសារផ្សេងទៀតឡើយ ហេតុដូច្នេះ ពាក្យសុំរបស់ខ្លួន ត្រូវដាក់បញ្ចូលនូវឯកសារទាំងឡាយដែលខ្លួនមាន។ ដូច្នេះ ឯកសារទាំងនេះជាការបញ្ជាក់នូវសិទ្ធិដាក់សារណា ឬ សិទ្ធិផ្តល់ចម្លើយនៅក្នុងតុលាការរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធនឹងពាក្យសុំ។ មូលហេតុដែលមានការជូនដំណឹងអំពីពាក្យសុំទាំងនេះដល់



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

សហព្រះរាជអាជ្ញា និងជនត្រូវចោទ គឺដើម្បីឱ្យសហព្រះរាជអាជ្ញា និងជនត្រូវចោទមានលទ្ធភាពឆ្លើយតបទៅនឹងពាក្យសុំ នៅពេលខ្លួនបង្គាប់ឱ្យឆ្លើយតប។

៩. នៅពេលចេញសេចក្តីសម្រេច អនុលោមតាមវិធាន ២៣ នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេត *បំពេញតួនាទីរបស់ខ្លួនចប់សព្វគ្រប់* ពោលគឺ ខ្លួនបានប្រើប្រាស់អស់អំណាចរបស់ខ្លួនលើករណីនេះរួចហើយ។ សហចៅក្រមស៊ើបអង្កេតមិនអនុញ្ញាតឱ្យចេញសម្រេចជាលើកទីពីរឡើយ ហើយក៏មិនអនុញ្ញាតឱ្យពិចារណា និងសើរើសេចក្តីសម្រេចរបស់ខ្លួនឡើងវិញដែរ។ ខរក្សាសិទ្ធិនៅក្នុងកថាខណ្ឌទីពីរនៃលិខិតនេះ គឺ *ហួសដែនអំណាចរបស់ខ្លួន* បានន័យថា វាហួសពីដែនអំណាចដែលសហចៅក្រមស៊ើបអង្កេតមាន។

១០. យោងតាមលិខិតនេះ សហចៅក្រមស៊ើបអង្កេត បានបង្កើតការផ្លាស់ប្តូរលើនីតិវិធីដែលមានចែង ដោយផ្តល់ខ្លួនឯងនូវសិទ្ធិចេញ "សេចក្តីសម្រេចផ្លាស់ប្តូរនៅពេលក្រោយ" ដើម្បីបញ្ចប់សិទ្ធិដាក់ពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលសិទ្ធិនេះទំនងជាទទួលបានដោយផ្អែកលើខ្លឹមសារឯកសារដើមរបស់ខ្លួន និងដើម្បីបញ្ចប់ការស៊ើបអង្កេត តាមការយល់ឃើញរបស់ខ្លួននៅពេលចេញសេចក្តីសម្រេចផ្លាស់ប្តូរលើកក្រោយនេះ។ បើសិនមានករណីនេះមែន ដើមបណ្តឹងរដ្ឋប្បវេណីមិនទទួលបានការជូនដំណឹងអំពីការយល់ឃើញរបស់ ស.ច.ស លើការស៊ើបអង្កេត អំពីពេលវេលាណាដែលសេចក្តីសម្រេចនាពេលក្រោយនឹងធ្វើឡើង ឬ ដើមបណ្តឹងរដ្ឋប្បវេណីមិនទទួលបានឱកាសដាក់ឯកសារបន្ថែមចំពោះបញ្ហាទាំងឡាយនេះ ដូចដែលខ្លួនធ្លាប់ទទួលបានឱកាសដូច្នេះពីមុន។ ប្រសិនបើមានការអនុញ្ញាតឱ្យចេញសេចក្តីសម្រេចផ្លាស់ប្តូរនៅពេលក្រោយបែបនេះ ការបដិសេធមិនផ្តល់ឱកាសដល់បុគ្គលណាម្នាក់ដាក់ឯកសារនៅមុនចេញសេចក្តីសម្រេចជាមូលដ្ឋាន ដែលបដិសេធចោលសិទ្ធិដែលបានផ្តល់ឱ្យនោះ វាជាការបដិសេធយ៉ាងច្បាស់លើសិទ្ធិទទួលបានការនូវការចេញសេចក្តីសម្រេចមួយដ៏យុត្តិធម៌ និយាយឱ្យជាក់លាក់ជាងនេះគឺសិទ្ធិដឹងអំពីអង្គហេតុ និងអង្គច្បាប់ដែលចោទប្រកាន់ចំពោះខ្លួននៅក្នុងអំឡុងពេលដែលពាក់ព័ន្ធ និងសិទ្ធិដាក់សារណា ឬ ផ្តល់ចម្លើយនៅក្នុងតុលាការ។ សិទ្ធិទាំងនេះអាចសម្តែងចេញតាមរយៈសិទ្ធិដាក់ឯកសារបន្ថែម។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C C.E.T.C

១១. វាបង្ហាញយ៉ាងច្បាស់ថា ទោះបីវាជារឿងក្តីព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ឬក្នុងករណីនេះ វាជារឿងក្តីរដ្ឋប្បវេណីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ សិទ្ធិទទួលបានការចេញសេចក្តីសម្រេចលើបញ្ហាណាមួយដ៏យុត្តិធម៌ គឺសិទ្ធិ ដូចមានចែងនៅក្នុងមាត្រា ១៤.១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលក្នុងនោះចែងថា៖

"ជនគ្រប់រូបត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី។ ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួនក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីយកិច្ចក្នុងវិស័យរដ្ឋប្បវេណី"[១៧១]។

១២. ជាពិសេស មាត្រា ១៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា[១៧២] ស្តីពីការបង្កើត អ.វ.ត.ក និង មាត្រា ៣៣(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា[១៧៣] បង្គាប់ឱ្យអង្គបុរេជំនុំជម្រះពិចារណាលើមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ នៅក្នុងរឿងក្តីនេះ យើងឃើញមានការចេញសេចក្តីសម្រេចលើសិទ្ធិរបស់ភាគីបណ្តឹងឧទ្ធរណ៍ដែលជាដើមបណ្តឹងរដ្ឋប្បវេណីឱ្យនៅជាភាគីនៃដំណើរការនីតិវិធី។ នេះជាសេចក្តីសម្រេចជាមូលដ្ឋានលើសិទ្ធិដែលទទួលបាននៅក្នុងកិច្ចដំណើរការនីតិវិធី។ នីតិវិធី និងសេចក្តីសម្រេចនេះត្រូវតែមានភាពយុត្តិធម៌។ ដំណើរការទាំងឡាយត្រូវឱ្យមានភាពច្បាស់លាស់ ហើយវិធានដែលបានលើកឡើងត្រូវយកមកអនុវត្ត។ មាត្រា ១៤.១ នៃ កតិកាសញ្ញាអន្តរជាតិ នឹងយកមកអនុវត្តនៅក្នុងករណីដែលមានការសម្រេចលើសិទ្ធិ និងកាតព្វកិច្ចដែលពាក់ព័ន្ធ "នឹងបណ្តឹងណាមួយ"។ យើងសូមយោង

[១៧១] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សេចក្តីសម្រេចមហាសន្និបាតអង្គការសហប្រជាជាតិលេខ 2200A [XX1] ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ មាត្រា ១៤.១។

[១៧២] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាស្តីពីការកាត់សេចក្តីក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ចុះឆ្នាំ២០០៣ មាត្រា ១៣។

[១៧៣] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចំពោះការកាត់សេចក្តីក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ មាត្រា ៣៣ ថ្មី។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

លើរឿងក្តី *Ringeuseu ទល់នឹង អូទ្រីស* A13[១៧៤] (1971) រឿងក្តី *Le Compte, Van Leuven និង De Meyene ទល់នឹង បែលហ្ស៊ិក* A43 (1981)[១៧៥]។ សេចក្តីសម្រេចលើរឿងក្តីទាំងពីរនេះធ្វើឡើងដោយអនុលោមតាមមាត្រា ៦(១)នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស[១៧៦] ដែលអនុសញ្ញានេះមានខប្បញ្ញត្តិដូចគ្នាទៅនឹងមាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិដែរ។ ទោះបីជាវាបង្ហាញយ៉ាងច្បាស់ថា សេចក្តីសម្រេចនៅក្នុងរឿងក្តីយើងនេះ មិនមែនជាការសម្រេចចុងក្រោយលើសិទ្ធិទទួលបានសំណងក៏ដោយ វាជាសេចក្តីសម្រេចលើសិទ្ធិទាមទារសំណងរបស់បុគ្គលម្នាក់ ពោលគឺសិទ្ធិនៅជាដើមបណ្តឹងរដ្ឋប្បវេណី។ ចំពោះបណ្តឹងរដ្ឋប្បវេណី សិទ្ធិនេះជាសិទ្ធិដាក់បណ្តឹងជាសិទ្ធិមូលដ្ឋាន ហើយសិទ្ធិនេះត្រូវពិចារណា ដោយគោរពទៅតាមលក្ខណៈពិសេសនៃសិទ្ធិទាមទារសំណងរដ្ឋប្បវេណី ដែលធ្វើឡើងចំពោះមុខ អ.វ.ត.ក។ រឿងក្តី *Obermeieu ទល់នឹង អូទ្រីស* A179 (1990)[១៧៧] គាំទ្រដល់ការយល់ឃើញដូច្នេះ ដែលរឿងក្តីនេះបានសម្រេចថា សេចក្តីសម្រេចបឋមលើសិទ្ធិ និងកាតព្វកិច្ច ដែលមានសារៈសំខាន់ចំពោះបណ្តឹងទាមទារសំណងរបស់អ្នកដាក់ពាក្យសុំ ត្រូវយកមកពិចារណាតាមមាត្រា ៦ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស។ ហេតុដូច្នេះ មាត្រានេះអាចយកមកធ្វើជាបទដ្ឋានណែនាំនៅក្នុងការបកស្រាយមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិ។ សូមអាន Golder *ទល់នឹង* UK A18 (1975)[១៧៨]។

១៣. សវនាការ ឬ សេចក្តីសម្រេចដ៏យុត្តិធម៌មួយ នឹងមិនត្រឹមតែពាក់ព័ន្ធនឹងសិទ្ធិដឹងអំពីអង្គហេតុ និង អង្គច្បាប់ដែលចោទប្រកាន់ចំពោះខ្លួន និងសិទ្ធិដាក់សារណា ឬ សិទ្ធិផ្តល់ចម្លើយក្នុងតុលាការប៉ុណ្ណោះទេ វានឹងរួមទាំងសិទ្ធិទទួលបានភាពយុត្តិធម៌លើនីតិវិធីផងដែរ។

---

[១៧៤] *Ringeisen ទល់នឹង អូទ្រីស* (១៩៧១) EHRR 455។

[១៧៥] *Le Compte, Van Leuven និង De Meyere ទល់នឹង បែលហ្ស៊ិក* (១៩៨៣) EHRR 183។

[១៧៦] អនុសញ្ញាស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត ដែលបានធ្វើវិសោធនកម្មតាមរយៈពិធីសារលេខ ១១ ទីក្រុងរ៉ូម ៤ XI 1950។

[១៧៧] *Obermeier ទល់នឹង អូទ្រីស* (១៩៩១) EHRR 290។

[១៧៨] *Golder ទល់នឹង ចក្រភពអង់គ្លេស* (១៩៧៩) ១ EHRR 524។

នៅក្នុងន័យនេះ ភាពយុត្តិធម៌លើនីតិវិធីនឹងរួមបញ្ចូលនីតិវិធីដែលមានតម្លាភាព និងស្របច្បាប់ ដែលសិទ្ធិ និងកាតព្វកិច្ច ត្រូវបានផ្តល់ជូន សម្តែងចេញ និងអនុវត្តបានយ៉ាងសមស្រប។ នៅក្នុងវិធីនេះ យើងសង្ឃឹមទុកយ៉ាងជាក់ច្បាស់ថា បញ្ហានេះនឹងត្រូវដោះស្រាយ ក្នុងវិធីមួយជាក់លាក់ សមស្រប និងពិតប្រាកដ។ ប្រសិនបើតុលាការមិនទទួលបានសិទ្ធិអំណាច នោះតុលាការ ឬ ចៅក្រមមិនមានអំណាចកែប្រែនីតិវិធីដែលបានចែងទុក ជាផ្លូវនៃការពន្លឿននីតិវិធី ឬដើម្បីហេតុផលណាមួយផ្សេង ដែលខុសច្បាប់ឡើយ។ ករណីនេះវាធ្វើឱ្យនីតិវិធីមានភាពអយុត្តិធម៌យ៉ាងខ្លាំង ហើយរាល់កិច្ចទាំងឡាយណាដែលបានធ្វើឡើងក្នុងនីតិវិធីមិនត្រឹមត្រូវតាមផ្លូវច្បាប់ដូច្នេះ វានឹងនាំឱ្យមានមោឃភាព។

១៤. ប្រសិនបើយើងចាត់ទុកថា សេចក្តីសម្រេចចេញលើកទីពីរមានសុពលភាព វាទាល់តែមានវិធាន និងច្បាប់ជាធរមានចែងជាក់លាក់។ ប៉ុន្តែ វិធាន និងច្បាប់ជាធរមានមិនបានបញ្ញត្តិទុកឡើយ។ ប្រសិនបើច្បាប់អនុញ្ញាតឱ្យធ្វើដូច្នេះ វានឹងមិនគោរពសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានការចេញសេចក្តីសម្រេចមួយដ៏យុត្តិធម៌។

១៥. យើងកត់សម្គាល់ឃើញថា មាត្រា ១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចែងថា ចៅក្រមស៊ើបសួរធ្វើការកត់សម្គាល់នូវការដាក់ពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី"តាមដីកា"។ មាត្រា ១៣៩ ក៏តម្រូវឱ្យចៅក្រមស៊ើបសួរ "ត្រូវចេញដីកាសម្រេចដោយមានសម្អាងហេតុភ្លាមៗតែម្តង" នៅក្នុងកាលៈទេសៈដែលខ្លួនចេញសេចក្តីសម្រេចឱ្យធ្វើការស៊ើបសួរ ឬ មិនឱ្យធ្វើការស៊ើបសួរ ប្រសិនបើសេចក្តីសម្រេចនោះវាផ្ទុយនឹងសំណើសុំរបស់ព្រះរាជអាជ្ញា[១៧៥]។ យើងយល់ឃើញថា មាត្រា ១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌអនុញ្ញាតឱ្យចៅក្រមស៊ើបអង្កេតកត់សម្គាល់នូវការដាក់ពាក្យប្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និង បន្ទាប់មក ចេញដីកាសម្រេចទទួលស្គាល់ ឬបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើការស៊ើបអង្កេត។ ដូច្នេះ ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺនីតិវិធីដំបូងនៃការដាក់បណ្តឹងចំពោះអំពើល្មើសព្រហ្មទណ្ឌ

---

[១៧៥] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះខែកញ្ញា ឆ្នាំ២០០៧ មាត្រា ១៣៩។



* PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

ដែលបានចោទប្រកាន់។ នីតិវិធីនេះខុសពីនីតិវិធីដែលអនុវត្តចំពោះដើមបណ្តឹងរដ្ឋប្បវេណីនៅមុខ អ.វ.ត.ក ដែលដើមបណ្តឹងរដ្ឋប្បវេណីមានបំណងចូលរួមនៅក្នុងការស៊ើបអង្កេតដែលកំពុងធ្វើឡើង។ នៅក្នុងករណីនៃរឿងក្តីនេះ លិខិតដែលបានបញ្ជូនដោយក្រឡាបញ្ជីរបស់ ក.ស.ច.ស មិនត្រឹមតែការកត់សម្គាល់ទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះទេ វាក៏ជាសេចក្តីសម្រេចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាដើមបណ្តឹងរដ្ឋប្បវេណីដោយប្រយោលផងដែរ។

១៦. ដូច្នេះ យើងយល់ឃើញថា សេចក្តីសម្រេចបដិសេធដើមបណ្តឹងរដ្ឋប្បវេណី ដែលបានទទួលស្គាល់នៅក្នុងរឿងក្តីនេះរួចហើយនោះ មិនអាចយកមកពិចារណាសារជាថ្មី ឬ មិនអាចអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតចេញសេចក្តីសម្រេចមួយទៀតឡើយ។ ដើមបណ្តឹងរដ្ឋប្បវេណីគួរតែនៅទទួលបានឋានៈរបស់ខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដដែលនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ ហើយក្នុងករណីមានដីកាបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ យើងគួរទុកឱ្យអង្គជំនុំជម្រះសាលាដំបូងជាអ្នកសម្រេចចុងក្រោយថាតើគួរចេញដីកាតម្កល់ ឬ ដីកាបដិសេធឋានៈអ្នកទាំងនេះ ដោយផ្អែកលើមូលដ្ឋាននៃការរកឃើញរបស់ខ្លួននៅពេលជំនុំជម្រះ។

១៧. យើងដឹងថា អនុលោមតាមវិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុង ការរកសម្លេងលើសលប់មិនបានលើអង្គសេចក្តីនៃមូលដ្ឋានបណ្តឹងឧទ្ធរណ៍នេះ នឹងបង្កើតជាសេចក្តីសម្រេចថា ដីកាដែលត្រូវបានជំទាស់ទីពីរនេះនៅមានសុពលភាពដដែល ត្រង់មូលដ្ឋានមួយនេះ។ ដូច្នេះ យើងកត់សម្គាល់ថា បទប្បញ្ញត្តិនៅក្នុងវិធានផ្ទៃក្នុង មិនបានរារាំងអ្នកដាក់ពាក្យសុំមិនឱ្យដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសារជាថ្មីឡើយប្រសិនបើអ្នកដាក់ពាក្យសុំជឿថា ខ្លួនបានបញ្ជាក់យ៉ាងត្រឹមត្រូវពីដំបូងអំពីហេតុការណ៍ និងការអះអាងទាំងឡាយថាស្ថិតនៅក្នុងវិសាលភាពនៃការស៊ើបអង្កេត។ យើងកត់សម្គាល់ឃើញថា អនុស្សរណៈអន្តរការិយាល័យ ដែលផ្ញើរចេញជាសាធារណៈពី ស.ច.ស ទៅអង្គភាពគាំពារជនរងគ្រោះរបស់តុលាការនៅថ្ងៃទី២៦



E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ខែមីនា ឆ្នាំ២០១០ បានជូនដំណឹងថា កាលបរិច្ឆេទកំណត់នៃការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានពន្យារពេលរហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០[១៨០]។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០

Rowan DOWNING

ប្រាក់ គឹមសាន

---

[១៨០] អនុស្សារណៈអន្តរការិយាល័យរបស់សហចៅក្រម យូ ប៊ុនឡេង និង Marcel Lemonde ផ្ញើរ ទៅបណ្ឌិត Helen Jarvis ប្រធានអង្គភាពគាំពារជនរងគ្រោះ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១០ D337/1។